# មាតិកា

## I- ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ

១១-០១-២០០០ - ព្រះរាជក្រឹត្យ នស/រកត/០១០០/០០៤ តំលើងឋានន្តរសក្តិថ្នាក់ឧត្តមសេនិយឯក ជូននាយទាហានជាន់ខ្ពស់ កងយោធពលខេមរភូមិន្ទ ២០

១១-០១-២០០០ - ព្រះរាជក្រឹត្យ នស/រកត/០១០០/០០៥ តំលើងឋានៈស្មើអនុរដ្ឋលេខាធិការ ជូនលោក មាន គុនុម , លោកស្រី ជេត ចណ្ណលី ២១

១៣-០១-២០០០ - ព្រះរាជក្រឹត្យ នស/រកត/០១០០/០០៧ បង្កើតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ២២

## II- រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ

០៦-០១-២០០០ - អនុក្រឹត្យ លេខ ០៥ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២៣

១០-០១-២០០០ - អនុក្រឹត្យ លេខ ០៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៥

១០-០១-២០០០ - អនុក្រឹត្យ លេខ ០៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៦

១០-០១-២០០០ -អនុក្រឹត្យ លេខ ០៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៧

១០-០១-២០០០ -អនុក្រឹត្យ លេខ ០៩ អនក្រ.តត ស្តីពីការជូនមេដាយការងារ ២៨

១០-០១-២០០០ -អនុក្រឹត្យ លេខ ១០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៩

១០-០១-២០០០ -អនុក្រឹត្យ លេខ ១១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតី ៣០

១០-០១-២០០០ -អនុក្រឹត្យ លេខ ១២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣១

១០-០១-២០០០ -អនុក្រឹត្យ លេខ ១៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣២

១៤-០១-២០០០ -អនុក្រឹត្យ លេខ ១៤ អនក្រ. តតស្តីពីការតែងតាំងសមាសភាពតំណាងអោយ មជ្ឈដ្ឋានឧត្តមសិក្សា ក្នុងក្រុមប្រឹក្សាភិបាលធនាគារជាតីនៃកម្ពុជា ៣៣

### ២-សេចក្តីសំរេច

១០-០១-២០០០ -សេចក្តីសំរេច លេខ ០១ សសរ ស្តីពីការរៀបចំកិច្ចប្រជុំនៃក្រុមពិគ្រោះយោបល់ លើកទី៤ ៣៤

# III- ការងារបណ្ដាក្រសួង

## ១-ធនាគារជាតិ នៃកម្ពុជា

### ប្រកាស


១០-០១-២០០០ - ប្រកាស លេខ ធ ៧០០.០៤ ប្រក ស្ដីពីការផ្ដល់អាជ្ញាប័ណ្ណចំពោះធនាគារ ពាណិជ្ជកម្ម ៣៥

១១-០១-២០០០ -ប្រកាស លេខ ធ ៧ ០០-០៥ ប្រក ស្ដីពីការផ្ដល់អាជ្ញាប័ណ្ណចំពោះធនាគារ ឯកទេសឥណទានជនបទ ៥៧

១១-០១-២០០០ -ប្រកាស លេខ ធ ៧ ០០-០៦ ប្រក ស្ដីពីការផ្ដល់អាជ្ញាប័ណ្ណចំពោះគ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ ៦៦


## ២-នីស្ដីការរដ្ឋមន្ត្រីក្រសួងពត៌មាន

### ប្រកាស


១១-០១-២០០០ - ប្រកាសលេខ ០២០/០០ ពម.ប្រក ស្ដីពីការតែងតាំងមន្ត្រីរាជការ ៨១

១២-០១-២០០០ - ប្រកាសលេខ ០២១/០០ ពម.ប្រក ស្ដីពីការតែងតាំងមន្ត្រីរាជការ ៨៣

១៣-០១-២០០០ - ប្រកាសលេខ ០២៤/០០ ពម.ប្រក ស្ដីពីការតែងតាំងមន្ត្រីរាជការ ៨៥


## ៣-នីស្ដីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

### ប្រកាស


១០-០១-២០០០ - ប្រកាសលេខ ០៨ អយក.ប្រក ស្ដីពីការផ្ដាច់សាលាឧបសម្ព័ន្ធ "ទិពាដើមរ" មកជាសាលាបឋមសិក្សាពេញលក្ខណៈ ៨៦

១០-០១-២០០០ - ប្រកាសលេខ ០៩ អយក.ប្រក ស្ដីពីការផ្ដាច់សាលាឧបសម្ព័ន្ធ "ព្រៃប្រេង" មកជាសាលាបឋមសិក្សាពេញលក្ខណៈ ៨៧

១០-០១-២០០០ - ប្រកាសលេខ ១០ អយក.ប្រក ស្ដីពីការផ្ដាច់សាលាឧបសម្ព័ន្ធ "សាអគ្គីរតនមុនី" មកជាសាលាបឋមសិក្សាពេញលក្ខណៈ ៨៨

១០-០១-២០០០ - ប្រកាសលេខ ១១ អយក.ប្រក ស្ដីពីការផ្ដាច់សាលាឧបសម្ព័ន្ធ "ត្រពាំងក្រាវ" មកជាសាលាបឋមសិក្សាពេញលក្ខណៈ ៩០

១០-០១-២០០០ - ប្រកាសលេខ ១២ អយក.ប្រក ស្ដីពីការផ្ដាច់សាលាឧបសម្ព័ន្ធ "ភ្លុកត្នោត" មកជាសាលាបឋមសិក្សាពេញលក្ខណៈ ៩១

១០-០១-២០០០ - ប្រកាសលេខ ១៣ អយក.ប្រក ស្ដីពីការផ្ដាច់សាលាឧបសម្ព័ន្ធ "បាវិតកណ្ដាល" មកជាសាលាបឋមសិក្សាពេញលក្ខណៈ ៩២

១០-០១-២០០០ - ប្រកាសលេខ ១៤ អយក.ប្រក ស្តីពីការផ្តាច់សាលាឧបសម្ព័ន្ធ "ឧត្តមមានជ័យ" មកជាសាលាបឋមសិក្សាពេញលក្ខណៈ ៩៣

១០-០១-២០០០ - ប្រកាសលេខ ១៥ អយក.ប្រក ស្តីពីការផ្តាច់សាលាឧបសម្ព័ន្ធ "វាលព្រៅ" មកជាសាលាបឋមសិក្សាពេញលក្ខណៈ ៩៥

១០-០១-២០០០ - ប្រកាសលេខ ១៦ អយក.ប្រក ស្តីពីការផ្តាច់សាលាឧបសម្ព័ន្ធ "ទ័ពស្តេច" មកជាសាលាបឋមសិក្សាពេញលក្ខណៈ ៩៦

១៤-០១-២០០០ - ប្រកាសលេខ ៣៧ អយក.ប្រក ស្តីពីការប្តូរឈ្មោះសាលាបឋមសិក្សា បែកចាន មកជាសាលាបឋមសិក្សា "កែវមុំងួនមុត" បែកចាន វិញ ៩៧

១៤-០១-២០០០ - ប្រកាសលេខ ៣៨ អយក.ប្រក ស្តីពីការប្តូរឈ្មោះសាលាបឋមសិក្សា ស្រះចក មកជាសាលាបឋមសិក្សា "ហេង ង៉ោ ស្រះចក" វិញ ៩៨

## ៤-នីតិការរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា

### ប្រកាស

១៣-០១-២០០០ - ប្រកាសលេខ ០១៩ សកបយ. ស្តីពីការអនុញ្ញាតឲ្យក្រុមហ៊ុន ខេមបូឌាលេប័រ សាប់ប្លាយ ភីធីអ៊ី អិលធីឌី (Cambodia Labour Supply Pty. Ltd ) ធ្វើការជ្រើសរើសបញ្ជូនពលករខ្មែរទៅធ្វើការនៅ ប្រទេសម៉ាឡេស៊ី សិង្ហបុរី និង ព្រុយណេ ៩៩

# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រឹត្យ

### ព្រះរាជក្រឹត្យ នស/រកត/០១០០/០០៤

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់ទតរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់ទតព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់ទតព្រះរាជក្រម នស/រកម/៩៤/០២ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់ទតព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់ទតអនុក្រឹត្យលេខ ៣៧/អនក្រ/តត ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៩ ស្តីពីការកែសម្រួលរចនាសម្ព័ន្ធថ្នាក់ដឹកនាំ នៃក្រសួងការពារជាតិ
- បានទ្រង់ទតសំណើសុំរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ .-** ត្រូវបានតំឡើងឋានន្តរសក្តិថ្នាក់ **ឧត្តមសេនីយ៍ឯក** ជូននាយទាហានជាន់ខ្ពស់ កងយោធពលខេមរភូមិន្ទ នៃក្រសួងការពារជាតិ ដូចមានរាយនាមខាងក្រោម ៖

១- ឧត្តមសេនីយ៍ទោ **មឹុង សំផន** អត្តលេខ ០០០០៧១ បច្ចុប្បន្ន អគ្គនាយក អគ្គនាយកដ្ឋានភស្តុភារ ហិរញ្ញវត្ថុនៃក្រសួងការពារជាតិ ។

២- ឧត្តមសេនីយ៍ទោ **នាង ផាត** អត្តលេខ ០០០០៨០ បច្ចុប្បន្ន អគ្គនាយក អគ្គនាយកដ្ឋានយោធសេវានៃក្រសួងការពារជាតិ។

៣- ឧត្តមសេនីយ៍ទោ ចៅ តិរុណ អត្តលេខ ០០០០៧៥ បច្ចុប្បន្ន អគ្គនាយក អគ្គនាយកដ្ឋានគាំពារ:បច្ចេកទេស នៃក្រសួងការពារជាតិ ។

មាត្រា ២ .- បទបញ្ញត្តិទាំងឡាយ ដែលមានខ្លឹមសារផ្ទុយ នឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ .- នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឲ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ។

មាត្រា ៤ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០០០

ព្រះហស្តលេខា

**នរោត្តម សីហនុ**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
ហត្ថលេខា
**ហ៊ុន សែន**

បានជំរាបជូនសម្ដេចនាយករដ្ឋមន្ត្រី
សហរដ្ឋមន្ត្រីក្រសួងការពារជាតិ
ព្រះហស្តលេខា និង ហត្ថលេខា
អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរីរ័ត្ន ទៀ បាញ់

***

## ព្រះរាជក្រឹត្យ នស/រកត/០១០០/០០៥

### យើង

### ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ

### រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

### ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

### ព្រះចៅក្រុងកម្ពុជាធិបតី

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់ប្រកាសឲ្យប្រើជាផ្លូវការនូវច្បាប់រដ្ឋធម្មនុញ្ញ ស្ដីពីវិសោធនកម្មមាត្រា ១១ , ១២ , ១៣ , ១៨ , ២២ , ២៤ , ២៦ , ២៨ , ៣០ , ៣៤ , ៥១ , ៩០ , ៩១ , ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានទ្រង់ជ្រាបព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៩ ដែលប្រកាសបញ្ជាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់ជ្រាបបទបញ្ជាផ្ទៃក្នុងនៃព្រឹទ្ធសភា ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៩
- យោងតាមសំណើរបស់សម្តេចប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០០០

## ត្រាស់បង្គាប់

**មាត្រា ១ .-** តម្លើងឋានៈស្មើ អនុរដ្ឋលេខាធិការ ជូន ៖

១- លោក **មាន សុខុម** ជាប្រធានអគ្គាធិការ ។

២- លោកស្រី **ជេត ទណ្ណលី** ជាប្រធានក្រុមប្រឹក្សាអ្នកច្បាប់ ។

**មាត្រា ២ .-** ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ .-** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០០០

ព្រះហស្តលេខា

**នរោត្តម សីហនុ**

★★★

## ព្រះរាជក្រឹត្យ នស/រកត/០១០០/០០៧

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់ជ្រាបរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់ជ្រាបព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់ជ្រាបព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ .- បង្កើតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលមានសមាសភាពដូចតទៅ ៖

១- ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសុខាភិបាល ជាប្រធាន

២- ឯកឧត្តម ឌី ណារ៉ុងរិទ្ធិ ជាអនុប្រធានប្រចាំការ មានឋានៈស្មើរដ្ឋមន្ត្រី

៣- ឯកឧត្តម លី ម៉ូរ ជាអនុប្រធាន មានឋានៈស្មើរដ្ឋលេខាធិការ

៤- ឯកឧត្តម មាន ជីវុន ជាអគ្គលេខាធិការ មានឋានៈស្មើអគ្គនាយក

និងទីប្រឹក្សាដែលមានសមាសភាព

៥- ឯកឧត្តម អ៊ឹង ឧត្តី ជាទីប្រឹក្សា មានឋានៈស្មើអនុរដ្ឋលេខាធិការ

៦- ឯកឧត្តម ថៃ ហ្វា ជាទីប្រឹក្សា មានឋានៈស្មើអនុរដ្ឋលេខាធិការ

៧- ឯកឧត្តម ងួន ចំរុង ជាទីប្រឹក្សា មានឋានៈស្មើអគ្គនាយក

មាត្រា ២.- ប្រធានប្រគល់សិទ្ធិគ្រប់គ្រងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឲ្យអនុប្រធានប្រចាំការ ។

មាត្រា ៣.- ការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៤.- អាជ្ញាធរនេះអាចមានសមាជិកពីក្រសួងពាក់ព័ន្ធ ។

មាត្រា ៥.- ព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/០១ ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ១៩៩៩ និងរាល់បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៦ .- នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៧ .- ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០០០

ព្រះហស្តលេខា

នរោត្តម សីហនុ

★★★

# II- រាជរដ្ឋាភិបាល

## ១.អនុក្រឹត្យ

### អនុក្រឹត្យលេខ ០៥ អនក្រ.តត

### ស្ដីពីការតែងតាំងមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញ ព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រម នស/៩៤/០២ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ៧៦/អនក្រ/បក/ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមតម្រូវការចាំបាច់ ការងាររបស់រាជរដ្ឋាភិបាល

## សំរេច

**មាត្រា ១ .-** ត្រូវបានតែងតាំងជា ជំនួយការសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ដូចមានរាយនាមខាងក្រោម ៖

១- លោក ទឌ្សី វិសុត មានឋានៈស្មើ អគ្គនាយករង បន្ថែមលើមុខងារបច្ចុប្បន្ន ។

២- លោក ហង់ ជួន ណារ៉ុន មានឋានៈស្មើ អគ្គនាយករង បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ០៦ អនក្រ.តត

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញ ព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រម នស/៩៤/០២ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តបាត់ដំបង

**សំរេច**

**មាត្រា ១ .-** ត្រូវបានប្រគល់ មេដាយស្ថាបនាជាតិ តាមលំដាប់ថ្នាក់ ប្រគេន និងជូនសប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិក ដែលបានបរិច្ចាគថវិកា និងសំភារៈជួយកសាងសមិទ្ធផលនានា និងសង្គ្រោះប្រជាពលរដ្ឋក្រីក្រនៅក្នុងស្រុកឯកភ្នំ ស្រុកស្វាយប៉ោ និងស្រុកសង្កែ ខេត្តបាត់ដំបង ដូចមានរាយព្រះនាម និងនាមខាងក្រោមនេះ ៖

**ក-មេដាយប្រាក់ ស្ថាបនាជាតិ :**

១- អ្នកស្រី **ហេង ឈាម** ទឹកប្រាក់ចំនួន ៩.៦៨០ ដុល្លារអាមេរិក

**ខ-មេដាយសំរិទ្ធ ស្ថាបនាជាតិ :**

១- លោក **ការ៉ែ ហាក់** និងអ្នកស្រី **គា ហឺង** ទឹកប្រាក់ ៣.២០០ ដុល្លារអាមេរិក

២- លោក **ថោង ជឿម** និងអ្នកស្រី **ឌួន សារិន** ទឹកប្រាក់ ៣.២០០ ដុល្លារអាមេរិក

៣- លោក **ឌួន សួម** និងអ្នកស្រី **មាស យ៉ែម** ទឹកប្រាក់ ៣.២០០ ដុល្លារអាមេរិក

៤- លោក **ញ៉ើម សារុន** និងអ្នកស្រី **សម្បត្តិ** ទឹកប្រាក់ ៣.២០០ ដុល្លារអាមេរិក

៥- លោក **ឡៅ ចាយ** និងអ្នកស្រី **ង៉ាច ម៉ុន** ទឹកប្រាក់ ៣.២០០ ដុល្លារអាមេរិក

៦- លោកស្រី **គីម ចាន់** ទឹកប្រាក់ ៣.២០០ ដុល្លារអាមេរិក

៧- លោក **ថន នាលី** និងអ្នកស្រី **ឃុន ដារី** ទឹកប្រាក់ ៣.២០០ ដុល្លារអាមេរិក

៨- លោកស្រី **មួន គីមឡាយ** ទឹកប្រាក់ ៣.៣៦០ ដុល្លារអាមេរិក

៩- លោក **សោ ម៉ូទ** និងអ្នកស្រី **អំ បូផល** ទឹកប្រាក់ ៣.៣៦០ ដុល្លារអាមេរិក

១០- លោក **សយ សារ៉ា** និងអ្នកស្រី **រ៉ាស៊ី** ទឹកប្រាក់ ២.០០០ ដុល្លារអាមេរិក

១១- ឧបាសិកា **លី ស៊ុយលេន** ទឹកប្រាក់ ២.៣០០ ដុល្លារអាមេរិក

១២- ឧបាសិកា **ឡេន សាយ** ទឹកប្រាក់ ២.០០០ ដុល្លារអាមេរិក

១៣- ឧបាសិកា **ស៊ុន ខូចគៀវ** ទឹកប្រាក់ ២.០០០ ដុល្លារអាមេរិក

១៤- ព្រះភិក្ខុ កិត្តិក ធម្មោ សាំង យ៉ុន ទឹកប្រាក់ ២.៤០០ ដុល្លារអាមេរិក

១៥- ឧបាសក ចំរើន សម្បត្តិ និងឧបាសិកា អេង លឿម ទឹកប្រាក់ ២.៤០០ ដុល្លារអាមេរិក

១៦- លោក ម៉ែន សុខុម និងអ្នកស្រី គឹម ផល្លី ទឹកប្រាក់ ២.១៣០ ដុល្លារអាមេរិក

១៧- លោក អ៊ំ ម៉ិនយឿន និងអ្នកស្រី សយ សាម៉ុន ទឹកប្រាក់ ២.១៣០ ដុល្លារអាមេរិក

១៨- ឧបាសក ស៊ី មួន និងឧបាសិកា ស៊្វី យ៉ង់ ទឹកប្រាក់ ២.១៣០ ដុល្លារអាមេរិក

១៩- ឧបាសក នួច មៀច និងឧបាសិកា ពិន ផាត ទឹកប្រាក់ ២.១៣០ ដុល្លារអាមេរិក

២០- អ្នកស្រី ផន មន្ថា ទឹកប្រាក់ ២.១២៩ ដុល្លារអាមេរិក

២១- ព្រះតេជគុណ នំ ហុក ចៅអធិការវត្តឈរី ទឹកប្រាក់ ២.០៦០ ដុល្លារអាមេរិក

២២- ឧបាសក តឿក ឡាង និងឧបាសិកា សៅ ចាំង ទឹកប្រាក់ ២.០៦០ ដុល្លារអាមេរិក

២៣- ឧបាសក ថៃ ឆៀន និងឧបាសិកា ចាន់ សាន ទឹកប្រាក់ ២.០៦០ ដុល្លារអាមេរិក

២៤- លោក ញ៉ៀម ស៊ុន និងអ្នកស្រី ឃឹម ឧន ទឹកប្រាក់ ២.០៦០ ដុល្លារអាមេរិក

២៥- លោក កែប គង់ និងអ្នកស្រី វៀល អ៊ុច ទឹកប្រាក់ ២.០៦០ ដុល្លារអាមេរិក

២៦- លោក ណុប កុយ និងអ្នកស្រី អោក យួម ទឹកប្រាក់ ២.០០០ ដុល្លារអាមេរិក

២៧- លោក កួច ទឿន និងអ្នកស្រី ឈិន ឈូ ទឹកប្រាក់ ២.០០០ ដុល្លារអាមេរិក

២៨- ឧបាសិកា ផា យួន ទឹកប្រាក់ ១.៦០០ ដុល្លារអាមេរិក

២៩- អ្នកស្រី ញ៉ៀម ស៊ី ទឹកប្រាក់ ១.៦០០ ដុល្លារអាមេរិក

មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ០៧ អនក្រ.តត

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញ ព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រម នស/៩៤/០២ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តស្វាយរៀង

**សំរេច**

**មាត្រា ១ .-** ត្រូវបានប្រគល់ មេដាយប្រាក់ស្ថាបនាជាតិ ជូនលោក សោម តា និងអ្នកស្រី អ៊ី សុផុន ជនជាតិខ្មែរ រស់នៅសហរដ្ឋអាមេរិក ដែលបានបរិច្ចាគថវិកាចំនួន ៥.០៣៣ ដុល្លារអាមេរិក សំរាប់ជួយកសាងកុដិ ០២ខ្នង បន្ទប់អនាម័យ អណ្ដូងទឹក មួយកន្លែង និងពុតថ្ម ក្នុងវត្តកញ្ចប់ សាលារៀន ក្នុងវត្តគ្រញាំងព្រឹង ភូមិព្រៃភ្លៀត ឃុំសំឡី ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តស្វាយរៀង ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

★★★

**អនុក្រឹត្យលេខ ០៨ អនក្រ.តត**

**ស្ដីពីការជូនមេដាយស្ថាបនាជាតិ**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រម នស/៩៤/០២ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា

សំរេច

មាត្រា ១ .- ត្រូវបានប្រគល់ មេដាយមាសស្ថាបនាជាតិ ជូនលោកយោម Muy Chhaku Toky នៃសមាគមស្ម័គ្រចិត្ត វត្ត សុតូស៊ីហ្សូតីសាំនជិ ប្រទេសជប៉ុន ដែលបានកសាង បណ្ណាល័យមួយខ្នងព្រមទាំងបរិក្ខារសំភារៈ ផ្សេងៗផង ជូនសាលាបឋមសិក្សា ស្វាយរមៀត ក្នុងស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ចំណាយអស់ ទឹកប្រាក់ចំនួន ៣៥.០០០USD ។

មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

***

## អនុក្រឹត្យលេខ ០៩ អនក្រ.តត

## ស្តីពីការជូនមេដាយការងារ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រម នស/៩៤/០២ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ

**សំរេច**

**មាត្រា ១ .-** ត្រូវបានប្រគល់ **មេដាយមាសការងារ** ជូនអ្នកជំនាញការបារាំង ០២ រូប មកពីទីក្រុងប៉ារីស ដែលមានស្នាដៃល្អ ក្នុងការជួយពិគ្រោះ និងរៀបចំអភិវឌ្ឍន៍ ទីក្រុងភ្នំពេញលើគ្រប់វិស័យ ដូចមាននាមខាងក្រោមនេះ ៖

១- លោក François LEGRAND

២- អ្នកស្រី Christiane BLANCOT

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យមានប្រសិទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

★★★

**អនុក្រឹត្យលេខ ១០ អនក្រ.តត**

**ស្តីពីការជូនមេដាយស្ថាបនាជាតិ**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រម នស/៩៤/០២ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តពោធិសាត់

**សំរេច**

**មាត្រា ១ .-** ត្រូវបានប្រគល់ **មេដាយសិរីស្ថាបនាជាតិ** ជូនសប្បុរសជនខ្មែរ នៅសហរដ្ឋអាមេរិក ០៥ រូប ដែលបានធ្វើអំណោយ ជាគ្រែ សំរាប់អ្នកជំងឺសំរាក ដល់មន្ទីរពេទ្យខេត្តពោធិសាត់ មានតំលៃ ជាទឹកប្រាក់ចំនួន ១១.២៧០ ដុល្លារអាមេរិក ដូចមានរាយនាមខាងក្រោមនេះ ៖

១- ឧបាសិកា ស៊ិន គីមឡេង

២- លោក ពៅ សុខខេន និងអ្នកស្រី ធារី

៣- ឧបាសក ឈុន ស៊ុ និងឧបាសិកា គី ឈីវអ៊ី

៤- ឧបាសិកា ម៉េង លី

៥- ឧបាសិកា នន ធីយ៉ោ

មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តពោធិសាត់ ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ១១ អនក្រ.តត

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រម នស/៩៤/០២ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពង់ឆ្នាំង

## សំរេច

មាត្រា ១ .- ត្រូវបានប្រគល់ **មេដាយមាសស្ថាបនាជាតិ** ជូនអង្គការ រ៉េដបាណា កម្ពុជា (REDD BARNA CAMBODIA) ដែលធ្វើអំណោយជាថវិកា ក្នុងការជួសជុលអាគារសិក្សា ១ ខ្នង មាន ៧ បន្ទប់ នៅសាលាឡាមម្យច័ន្ទលាភ និងផ្តល់សង្ហារឹម សំភារៈបណ្ណាល័យ វចនានុក្រម សៀវភៅសិក្សា ស្រាវជ្រាវដល់សាលាបឋមសិក្សាគំរូក្រុង និងសាលាបឋមសិក្សាឡាមម្យច័ន្ទលាភ មានតំលៃ ជាទឹកប្រាក់ ចំនួន ១៨.៥០១ $US ៦៩ ។

មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តកំពង់ធ្នាំង ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០០
នាយករដ្ឋមន្ត្រី
ហត្ថលេខានិងត្រា
ហ៊ុន សែន

★★★

# អនុក្រឹត្យលេខ ១២ អនក្រ.តត
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រម នស/៩៤/០២ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពង់ចាម

## សំរេច

មាត្រា ១ .- ត្រូវបានប្រគល់ មេដាយមាសស្ថាបនាជាតិ ជូនសប្បុរសជន ០៤រូប ដែលបានបរិច្ចាគថវិកាជួយកសាង សមិទ្ធផលសាធារណៈនានា នៅក្នុងខេត្តកំពង់ចាម ដូចមានរាយនាមខាងក្រោម ៖

ក-មេដាយមាសស្ថាបនាជាតិ ៖

១- ឯកឧត្តម ជៀង អំ បរិច្ចាគប្រាក់ ១០.០០០ដុល្លារអាមេរិក កសាងក្លោងទ្វារវត្តភ្នំប្រុស

២- ឯកឧត្តម ម៉ៅ តិរុណា បរិច្ចាគប្រាក់ ១០.៥០០ដុល្លារអាមេរិក កសាងក្លោងទ្វារវត្តភ្នំប្រុស

៣- លោកស្រី សេង គាង បរិច្ចាគប្រាក់ ១០.០០០ដុល្លារអាមេរិក កសាងផ្លូវក្នុងក្រុងកំពង់ចាម

ខ-មេដាយប្រាក់ស្ថាបនាជាតិ :

- លោក គឹម ភៅ បរិច្ចាគប្រាក់ ៦.០០០ដុល្លារអាមេរិក កសាងចិញ្ចើមផ្លូវក្នុងក្រុងកំពង់ចាម

មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

***

## អនុក្រឹត្យលេខ ១៣ អនក្រ.តត
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រម នស/៩៤/០២ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពង់ឆ្នាំង

## សំរេច

មាត្រា ១ .- ត្រូវបានប្រគល់ មេដាយមាសស្ថាបនាជាតិ ជូនសប្បុរសជន ០២រូប ដែលបានបរិច្ចាគថវិកាចូលរួមក្នុងការកសាងអាគារសិក្សា ១ខ្នង មាន ០៥ បន្ទប់ និងព្រះវិហារនៅក្នុងវត្តពានីឃុំពានី ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ដូចមានរាយនាមខាងក្រោមនេះ ៖

១- លោក ឯក សុនចាន់ នាយករដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ថវិកា ចំនួន ១៣.៩៣០ ដុល្លារអាមេរិក ។

២- លោកជំទាវ ឆន និច្ចរី សប្បុរសជននៅភ្នំពេញ ថវិកា ចំនួន ១០.៥៣៦ ដុល្លារ អាមេរិក ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

***

## អនុក្រឹត្យលេខ ១៨ អនក្រ.តត
## ស្តីពីការតែងតាំងសមាសភាពតំណាងឲ្យមជ្ឈដ្ឋានឧត្តមសិក្សា ក្នុងក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រម នស/៩៤/៧២ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃធនាគារជាតិនៃកម្ពុជា
- យោងតាមសំណើរបស់ទេសាភិបាលធនាគារជាតិនៃកម្ពុជា

## សំរេច

**មាត្រា ១ .-** ត្រូវបានតែងតាំងឯកឧត្តម អ៊ីវ ថុង ព្រឹទ្ធបុរសវិទ្យាស្ថានជាតិគ្រប់គ្រងជា **សមាជិកក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា** ជាថ្មីម្តងទៀត បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យមាន ប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

★★★

## ២- សេចក្តីសំរេច

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០០

### សេចក្តីសំរេចលេខ ០១ សសរ

### ស្តីពីការរៀបចំកិច្ចប្រជុំនៃក្រុមពិគ្រោះយោបល់លើកទី ៤

***

### រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/៩៤/០២ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ២០/អនក្រ/បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៥១/អនក្រ/បក ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៨/អនក្រ/បក ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៩៩ ស្តីពីការកែតំរូវអនុក្រឹត្យលេខ ៥១/អនក្រ/បក ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩៥
- តាមសំណើរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងជាអនុប្រធានទី១ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

### សំរេច

ប្រការ ១ : ប្រគល់ភារកិច្ចជូនឯកឧត្តម គាត ឈន់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានទី១ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងការដឹកនាំនិងសំរបសំរួលការងារត្រៀម

រៀបចំសំរាប់កិច្ចប្រជុំនៃក្រុមពិគ្រោះយោបល់លើកទី៤ ដែលនឹងប្រព្រឹត្តទៅក្នុងឆ្នាំ ២០០០ នេះ ។

**ប្រការ ២ :** ក្នុងក្របខ័ណ្ឌ នៃការដឹកនាំ និងសំរបសំរួលការងាររៀបចំសំរាប់កិច្ចប្រជុំនេះ ឯកឧត្តម គាត ឈន់ ត្រូវសហការជាមួយប្រធាន នៃបណ្តាក្រសួងនិងស្ថាប័នទាំងអស់របស់រាជរដ្ឋាភិបាល និង មានសិទ្ធិអញ្ជើញមន្ត្រីជាន់ខ្ពស់ ឲ្យចូលរួមប្រជុំអន្តរក្រសួង និងមានសិទ្ធិចាត់ចែងធ្វើការពិគ្រោះយោបល់ជាមួយតំណាងប្រទេស និង អង្គការអន្តរជាតិ ម្ចាស់ជំនួយទ្វេភាគី និងពហុភាគី ដើម្បីសំរបសំរួលការងារ និងដើម្បីរៀបចំសេចក្តីព្រាងឯកសារចាំបាច់នានា ។

**ប្រការ ៣ :** ឯកឧត្តម គាត ឈន់ ត្រូវរាយការណ៍ជាបន្តបន្ទាប់ជូនសម្តេចនាយករដ្ឋមន្ត្រី អំពីលទ្ធផលនៃការងារដែលបានបំពេញ ហើយត្រូវរៀបចំឯកសារចាំបាច់នានា សំរាប់កិច្ចប្រជុំលើកទី ៤ នេះ ដើម្បីដាក់ជូនសម្តេចនាយករដ្ឋមន្ត្រី ពិនិត្យផ្តល់យោបល់ណែនាំ និង អនុម័តមុននឹងយកទៅប្រើប្រាស់ជាផ្លូវការ ។

**ប្រការ ៤ :** ក្នុងការបំពេញកិច្ចការនេះ ឯកឧត្តម គាត ឈន់ ប្រើប្រាស់រចនាសម្ព័ន្ធរបស់គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា (គអក/គជនា) សំរាប់ជាជំនួយការងារប្រចាំថ្ងៃ ។

**ប្រការ ៥ :** សេចក្តីសំរេចនេះមានប្រសិទ្ធភាពរហូតដល់កិច្ចប្រជុំលើកទី ៤ នៃក្រុមពិគ្រោះយោបល់បានប្រព្រឹត្តទៅចប់សព្វគ្រប់ ។

**ប្រការ ៦ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័នដែលពាក់ព័ន្ធ និងឯកឧត្តម គាត ឈន់ ត្រូវអនុវត្តសេចក្តីសំរេចនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១
ហត្ថលេខានិងត្រា
**ហ៊ុន សែន**

★★★

## III- ការងារបណ្តាក្រសួង

## ១.ធនាគារជាតិ នៃកម្ពុជា

### ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០០

**ប្រកាសលេខ ធ ៧០០-០៤ ប្រក**
**ស្តីពីការផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារពាណិជ្ជ**

***

**ទេសាភិបាលធនាគារជាតិនៃកម្ពុជា**

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣៩៨/៩៥ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង ឯកឧត្តម ជា ចាន់តូ ជាអគ្គទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា
- យោងតាមសំណើរបស់នាយកដ្ឋានត្រួតពិនិត្យ

**សំរេច**

**ជំពូក ទី ១**

**បទប្បញ្ញត្តិទូទៅ**

ប្រការ ១ : ធនាគារពាណិជ្ជ តទៅនេះហៅថាធនាគារ ដូចមានកំណត់និយមន័យក្នុងជំពូកទី ១ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា មុនពេលចាប់ផ្តើមធ្វើប្រតិបត្តិការ អនុលោមតាមមាត្រា ១៤ នៃច្បាប់ដដែលនេះ ។

ប្រការ ២ : អ្នកដាក់ពាក្យសុំអាជ្ញាប័ណ្ណធនាគារត្រូវប្រកាន់យកនូវរូបភាពគតិយុត្តណាមួយ ក្នុងចំណោមរូបភាពគតិយុត្តដែលមានចែងក្នុងជំពូកទី ៣ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិង ហិរញ្ញវត្ថុ ។

ប្រការ ៣ : មុនពេលទទួលអាជ្ញាប័ណ្ណ អ្នកដាក់ពាក្យសុំត្រូវមានដើមទុនអប្បបរមាចុះក្នុងលក្ខន្តិកៈតាមចំនួនទឹកប្រាក់ ដែលនឹងត្រូវកំណត់ក្នុងប្រកាសរបស់ធនាគារជាតិនៃកម្ពុជាស្តីពីដើមទុនអប្បបរមា ។

**ជំពូក ទី ២**

**នីតិវិធីនៃការដាក់ពាក្យសុំអាជ្ញាប័ណ្ណ**

ប្រការ ៤ : ពាក្យសុំអាជ្ញាប័ណ្ណ[១] ត្រូវស្នើដោយបុគ្គល ដែលបានទទួលការអនុញ្ញាតត្រឹមត្រូវ (អ្នកចាត់ការឬជនដែលបានទទួលសិទ្ធិជាលាយលក្ខអក្សរ) ស្របតាមបទប្បញ្ញត្តិដែលមានរៀបរាប់ខាងក្រោមនេះ ៖

ក- នាម ឬ នាមករណ៍អាជីវកម្មរបស់គ្រឹះស្ថាន

---

កំណត់សំគាល់

[១] ត្រូវផ្ញើជូននូវលិខិតស្នើសំរាប់សុំអាជ្ញាប័ណ្ណ (មាត្រា ១៤ នៃច្បាប់ស្តីពីគ្រឹះស្ថាន ធនាគារ និងហិរញ្ញវត្ថុ) សំរាប់ប្រតិវេទន៍ (មាត្រា ២៣) ឬសំរាប់អនុញ្ញាត (មាត្រា២៤) ស្របតាម គំរូលិខិតដែលមានក្នុងឧបសម្ព័ន្ធទី ១ ។

ខ- អាសយដ្ឋាននៃទីស្នាក់ការកណ្តាល ឬសាខានៅកម្ពុជាក្នុងករណីជាក្រុមហ៊ុនបរទេស

គ- រូបភាពគតិយុត្តនិងលក្ខន្តិកៈ ឬឯកសារបង្កើតផ្សេងៗទៀត

ឃ-ប្រភេទមូលប័ត្រតំណាងឲ្យដើមទុន និងចំណងទាក់ទងរវាងការកាន់កាប់មូលប័ត្រ
ទាំងនោះនិងការអនុវត្តន៍សិទ្ធិបោះឆ្នោត

ង- ចំនួនដើមទុនដែលមានគ្រប់ឬដើមទុនដែលបានព្រោង ឬចំនួនដើមទុនដែលត្រូវបង់
ក្នុងករណីជាសាខាក្រុមហ៊ុនបរទេស ។ ចំនួននេះយ៉ាងតិចបំផុតត្រូវស្មើនឹងចំនួនដើម
ទុនដែលមានចែងក្នុងប្រការ ៣ នៃប្រកាសនេះ

ច- ការបែងចែកភាគហ៊ុន និងសិទ្ធិបោះឆ្នោតនិងកិច្ចព្រមព្រៀងដែលអាចមានរវាងភាគ
ទុនិកៈ ដែលដើរតួនាទីក្នុងការដឹកនាំគោលនយោបាយរបស់ធនាគារ

ឆ- ភាគទុនិកៈដែលកាន់កាប់ប្រាំភាគរយ (៥%) នៃសិទ្ធិបោះឆ្នោតឬលើសពីនេះត្រូវផ្តល់
ព័ត៌មានដូចមានរៀបរាប់ក្នុងប្រការ ៥ នៃប្រកាសនេះ

ជ- អត្តសញ្ញាណរបស់បុគ្គលយ៉ាងតិចបំផុតពីររូប (២រូប) ដែលទទួលខុសត្រូវក្នុងការ
ដឹកនាំ ដោយមានប្រសិទ្ធភាព នូវសកម្មភាពអាជីវកម្មរបស់ធនាគារ អ្នកចាត់ការដែល
បានទទួលការតែងតាំងហើយខាងលើនេះ ត្រូវផ្តល់ព័ត៌មានដូចមានរៀបរាប់នៅប្រការ
៦ នៃ ប្រកាសនេះ ហើយផ្តល់នូវលិខិតបញ្ជាក់ទោសមួយច្បាប់ ។ ចំពោះអ្នកចាត់
ការជាជនបរទេសដែលមានលំនៅដ្ឋាននៅកម្ពុជាតិចជាងបីឆ្នាំ (៣ឆ្នាំ) លិខិតបញ្ជាក់
ទោសនេះ ត្រូវចំលងចេញដោយអាជ្ញាធរមានសមត្ថកិច្ច នៃប្រទេស
កំណើតរបស់ខ្លួន ដោយមានបញ្ជាក់ថា ជនដែលមានពាក់ព័ន្ធមិនត្រូវបានហាមឃាត់មិន
ឲ្យកាន់តែងការងារក្នុងគ្រឹះស្ថានហិរញ្ញវត្ថុណាមួយ តាមខ្លឹមសារនៃបទប្បញ្ញត្តិរបស់
ប្រទេសនោះទេ ។

អ្នកចាត់ការសាខាធនាគារបរទេសនៅកម្ពុជា ត្រូវបានតែងតាំងដោយអ្នកមានសមត្ថកិច្ច
នៅ ទីស្នាក់ការកណ្តាល

ឈ-អត្តសញ្ញាណរបស់សមាជិកក្រុមប្រឹក្សាភិបាល បន្ថែមពីលើព័ត៌មានខាងលើ ត្រូវមាន
ជីវប្រវត្តិ និងត្រូវឆ្លើយសំណួរដូចមានក្នុងឧបសម្ព័ន្ធទី ៤ ព្រមទាំងត្រូវមានរបាយ
ការណ៍ បញ្ជាក់ថា គ្មាននរណាម្នាក់ពាក់ព័ន្ធទៅនឹងការហាមឃាត់ដូចមានចែងក្នុង
មាត្រា ១៨ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។ សមាជិកក្រុមប្រឹក្សា
ភិបាលត្រូវមានបទពិសោធន៍ខាងឥណទានយ៉ាងតិចបំផុតបីឆ្នាំ (៣ឆ្នាំ) ហើយត្រូវមាន
បញ្ជាក់ក្នុងជីវប្រវត្តិរបស់សមាជិកនោះ

ញ-ប្រសិនបើនីតិបុគ្គលដែលបានដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណ គឺជាអង្គភាពដែលបាន
បង្កើតរួចហើយ ត្រូវផ្តល់មកជាមួយនូវការអធិប្បាយអំពីមុខរបររបស់ខ្លួនព្រមទាំង

តារាងតុល្យការ ដែលមានការបញ្ជាក់ពីស្នងការគណនីសំរាប់ប្រតិបត្តិការក្នុងរយៈពេលបីឆ្នាំ ( ៣ឆ្នាំ ) ចុងក្រោយ

គ- ការព្យាករណ៍អំពីផែនការសកម្មភាពអាជីវកម្មរយៈពេលបីឆ្នាំ (៣ឆ្នាំ) ទៅមុខ ៖

- ទំហំនៃការឲ្យខ្ចីគ្រប់ប្រភេទដែលអាចមាននៅក្នុង ឬក្រៅតារាងតុល្យការ និងសេវាផ្សេងៗទៀតដែលត្រូវផ្តល់ឲ្យអតិថិជន ឬសមាជិក (ចំពោះឥណទានប្រភេទ ទំរង់ គោលបំណង ខ្ចីអគារ និងល័ក្ខខ័ណ្ឌផ្សេងៗ ផលកំរៃដែលទទួលបានប្រចាំឆ្នាំនិងពីកប្រាក់មិនទាន់សង)
- ប្រភេទនិងទំហំនៃសេវាផ្សេងទៀតដែលផ្តល់ឲ្យអតិថិជន (គណនីសន្សំ ការផ្តល់មធ្យោបាយទូទាត់ ការគ្រប់គ្រងទ្រព្យសកម្មជាដើម)
- ប្រភេទអតិថិជន (ឯកជន ឯកត្តជន ក្រុមហ៊ុន អង្គការអន្តរជាតិ វិនិយោគិនជាស្ថាប័ន) ដែលធនាគារមានបំណងប្រាស្រ័យទាក់ទង
- ប្រភពធនធានហិរញ្ញវត្ថុដែលបានគ្រោងទុក ៖ មូលនិធិផ្ទាល់ បុរេប្រទានរបស់ភាគទុនិកៈ មូលប័ត្រគណនេយ្យដែលអាចជួញដូរបាន ប្រាក់បញ្ញើពីសាធារណជនទូទៅ ប្រាក់កម្ចីលើទីផ្សារអន្តរធនាគារជាដើម
- ចំនួនប៉ាន់ស្មាននៃនិយោជិតក្នុងរយៈពេលបីឆ្នាំ (៣ឆ្នាំ) ខាងមុខ និងបញ្ជីបើកបៀវត្សដោយសង្ខេបតាមប្រភេទបុគ្គលិក
- ការចាត់តាំងនិងធនធាន ដែលបានគ្រោងទុក ពិសេសចំពោះការទាក់ទងអតិថិជន (ការបង្កើតសាខា) និងចំពោះទំរង់ការគណនេយ្យនិងឧបករណ៍កុំព្យូទ័រ
- តារាងតុល្យការ និងការព្យាករណ៍គណនីខាត-ចំណេញសំរាប់ការិយបរិច្ឆេទគណនេយ្យបីឆ្នាំ (៣ឆ្នាំ) ខាងមុខ ។ ត្រូវព្យាករណ៍កំរិតអនុបាតប្រុងប្រយ័ត្នចំបងៗ (ដូចបានកំណត់ដោយធនាគារជាតិនៃកម្ពុជា) នៅខាងចុងការិយបរិច្ឆេទគណនេយ្យបីឆ្នាំ (៣ឆ្នាំ) ខាងមុខ

ឃ- ការត្រួតពិនិត្យផ្ទៃក្នុង ៖

- កាចាត់តាំងផែនការត្រួតពិនិត្យបញ្ជីផ្ទៃក្នុងដែលមានចែងក្នុងមាត្រា ៤៣ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- របៀបកំណត់កំរិតផ្ទៃក្នុងទៅលើប្រភេទហានិភ័យនិងទំរង់ការផ្សេងៗ សំរាប់ធានាការអនុវត្តន៍ឲ្យបានត្រឹមត្រូវ

- នីតិវិធីដែលបានគ្រោងទុកសំរាប់ធានាការអនុវត្តន៍ឲ្យបានត្រឹមត្រូវតាមសីលធម៌វិជ្ជា ជីវៈពិសេសចំពោះប្រតិបត្តិការហិរញ្ញវត្ថុជាមួយអតិថិជន និងសំរាប់រួមចំណែកក្នុងការប្រយុទ្ធប្រឆាំងការសំអាតប្រាក់
- សមាសភាព និងភារកិច្ចរបស់គណៈកម្មការត្រួតពិនិត្យបញ្ជី

ខ- ការត្រួតពិនិត្យពីខាងក្រៅ

- អត្តសញ្ញាណរបស់ស្នងការគណនីឯករាជ្យ ដែលត្រូវបានជ្រើសរើសពីបញ្ជីប្រតិស្រុតិ
- ប្រភេទនៃមុខងារដែលត្រូវប្រគល់ឲ្យស្នងការគណនីឯករាជ្យនោះ

គ-ការត្រួតពិនិត្យរបស់ទីស្នាក់ការកណ្តាលឬក្រុមហ៊ុនដើម (សំរាប់សាខាធនាគារបរទេសឬបុត្តសម្ព័ន្ធរបស់ក្រុមហ៊ុនបរទេស)

- ពិពណ៌នាពីទំរង់ការសំរាប់ការត្រួតពិនិត្យសាខា ឬបុត្តសម្ព័ន្ធរបស់ក្រុមហ៊ុនដើម
- ពិពណ៌នាពីការត្រួតពិនិត្យសាខា ឬបុត្តសម្ព័ន្ធបរទេសរបស់អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសដើម ។

**ប្រការ ៥ :** ភាគទុនិកៈដែលកាន់កាប់ប្រាំភាគរយ (៥%) ឬលើសពីនេះនៃដើមទុនឬនៃសិទ្ធិបោះឆ្នោតរបស់អ្នកដាក់ពាក្យសុំ ត្រូវផ្តល់ពត៌មានដូចតទៅ ៖

ក- អត្តសញ្ញាណរបស់ភាគទុនិកៈ ៖

ក្នុងករណីជានីតិបុគ្គល ត្រូវផ្តល់នាមករណ៍អាជីវកម្ម រូបភាពគតិយុត្ត អាសយដ្ឋាន ទីស្នាក់ការកណ្តាលនិងលេខចុះបញ្ជីក្នុងបញ្ជីពាណិជ្ជកម្ម ។ ក្នុងករណីជាឯកត្តជន ត្រូវរៀបរាប់នាម គោត្តនាម ថ្ងៃខែឆ្នាំនិងទីកន្លែងកំណើត សញ្ជាតិ និងលំនៅដ្ឋាន ។ ត្រូវបញ្ជាក់ថា តើបុគ្គលនេះត្រូវបានតែងតាំងជាអ្នកចាត់ការមួយរូបរបស់ធនាគារឬទេ ។ ត្រូវប្រាប់ថា តើភាគទុនិកៈជាសមាជិកនៃក្រុមប្រឹក្សាភិបាលរបស់គ្រឹះស្ថានឬទេ ។ បើមែន ត្រូវធានាថាសមាជិកនោះមិនមានពាក់ព័ន្ធជាមួយការហាមឃាត់ដូចមានចែងក្នុងមាត្រា ១៨ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទេ ។ សំរាប់គោលបំណងទាំងអស់នេះ បុគ្គលពាក់ព័ន្ធម្នាក់ៗត្រូវបំពេញជីវប្រវត្តិនិងសំនួរដូចមានក្នុងឧបសម្ព័ន្ធទី ៤

ខ- បញ្ជាក់ពីចំនួននិងភាគរយនៃភាគកម្មដែលបានស្នើនិងចំនួន និងភាគរយនៃសិទ្ធិបោះឆ្នោត ។ រៀបរាប់លំអិតពីការសំរបសំរួលខាងគតិយុត្ត និងខាងហិរញ្ញវត្ថុចំពោះការទទួលយកមូលប័ត្រ ។ បើភាគទុនិកៈជាឯកត្តជន ត្រូវបញ្ជាក់ច្បាស់ពីប្រភពដើមនៃដើមទុនវិនិយោគ ។ បង្ហាញថា តើសកម្មភាពប្រតិបត្តិការស្ថិតនៅ

ក្រោមច្បាប់ស្ដីពីវិធីដោះស្រាយដែលអនុវត្តចំពោះការវិនិយោគបរទេសនៅកម្ពុជាឬទេ ហើយតើទម្រង់បែបបទទាំងនេះត្រូវបានបំពេញហើយឬនៅ

គ- បញ្ជាក់ពីការបែងចែកភាគហ៊ុនរបស់ភាគទុនិកៈ ។ បើចាំបាច់ ត្រូវរៀបរាប់ពីការបែងចែកភាគហ៊ុនរបស់ក្រុមហ៊ុនដើមនិងរបស់ក្រុមហ៊ុនហូលឌិញជាកណ្ដាល (intermediate holding companies) បង្ហាញនូវសមាមាត្រភាគហ៊ុននិងសិទ្ធិបោះឆ្នោត ។

ត្រូវរៀបចំបញ្ជីឈ្មោះអ្នកចាត់ការធំៗនៃអ្នកចូលហ៊ុន

ឃ-រៀបរាប់ពីសកម្មរបស់ភាគទុនិកៈ ។ ប្រសិនបើភាគទុនិកៈជាសមាជិកនៃក្រុមមួយត្រូវពិពណ៌នាពីអង្គភាពធំៗនៃក្រុមនោះ រួមជាមួយអង្គការលេខផង ។ ត្រូវបញ្ជាក់ផងថា តើភាគទុនិកៈមានទ្រព្យសម្បត្តិច្រើននៅក្នុងស្ថាប័នឥណទានផ្សេងៗទៀតឬទេ បញ្ជាក់ថា តើភាគទុនិកៈមានសម្បត្តិច្រើននៅក្នុងស្ថាប័នឥណទានផ្សេងៗទៀតឬទេ បញ្ជាក់ថា តើក្រុមណាដែលជាកម្មសិទ្ធិផ្ទាល់របស់ទុនិកៈមានទុនច្រើននៅក្នុងគ្រឹះស្ថានឥណទានឬទេ ។ បើមានត្រូវរៀបរាប់ឲ្យអស់

ង- ប្រាប់ថា តើភាគទុនិកៈនិងក្រុមហ៊ុនដែលអាចបញ្ចូលជាមួយគ្នាមានធ្វើសកម្មភាពហិរញ្ញវត្ថុឬទេ ។ បើមាន ត្រូវបញ្ជាក់ថា ក្រុមហ៊ុនទាំងនោះស្ថិតក្រោមចំណុះបទបញ្ញាណាឬអាជ្ញាធរណា

ច- បញ្ជាក់ពីបែបបទនៃការត្រួតពិនិត្យផ្ទៃក្នុងនិងពីខាងក្រៅរបស់ភាគទុនិកៈ

ឆ- បញ្ជាក់ថា តើក្នុងរយៈពេលដប់ឆ្នាំ (១០ឆ្នាំ) កន្លងមក ភាគទុនិកៈបានទទួលរងនូវការស៊ើបអង្កេតឬទទួលរងនូវការពិន័យជាសំភារៈតាមទំរង់វិជ្ជាជីវៈ រដ្ឋបាល ឬតុលាការនៅកម្ពុជាឬនៅបរទេសឬទេ ។ ត្រូវរៀបរាប់ថា តើមានបានទទួលមរណភាពកម្មណាមួយដោយសារការស៊ើបអង្កេតឬទំរង់ការឬទេ ។ បញ្ជាក់ដែរថា តើភាគទុនិកៈជាកម្មវត្ថុឬអាចជាកម្មវត្ថុនៃទំរង់ការរដ្ឋបាល យុត្តិធម៌ ឬ ជាមិត្តភាពនៅកម្ពុជា ឬនៅបរទេស ដែលអាចមានឥទ្ធិពលខាងសំភារៈទៅលើស្ថានភាពហិរញ្ញវត្ថុរបស់ភាគទុនិកៈនេះឬទេ

ជ- ប្រាប់ពីគោលដៅរបស់ភាគទុនិកៈ ៖ ក្នុងការដាក់បញ្ចូលដើមទុនផ្ទាល់ទៅក្នុងធនាគារដែលបានដាក់ពាក្យសុំអាជ្ញាប័ណ្ណនិងផ្ដល់ពត៌មានដែលពាក់ព័ន្ធទាំងអស់

ឈ-បញ្ជាក់ថា តើមានទំនាក់ទំនងអាជីវកម្មសំខាន់ៗរវាងភាគទុនិកៈនិងអ្នកដាក់ពាក្យសុំឬទេ ហើយតើទំនាក់ទំនងនេះនឹងត្រូវបានពង្រីកទៅអនាគតយ៉ាងណា

ញ-បញ្ជាក់ថា តើទំនាក់ទំនងអាជីវកម្មសំខាន់ៗខាងធនាគាររបស់ភាគទុនិកៈនៅកម្ពុជាមានអ្វីខ្លះ ហើយទំនាក់ទំនងទាំងនេះនៅមានរហូតដល់ពេលណាទៀត

ជ-ផ្តល់តារាងនីរបស់ភាគទុនិកៈឬក្រុមហ៊ុនដើមរបស់ខ្លួន សំរាប់រយៈពេលបីឆ្នាំ(៣ឆ្នាំ) ចុងក្រោយ ព្រមទាំងធ្វើការព្យាករណ៍សំរាប់ឆ្នាំនេះ (រួមមានទាំងពត៌មាន ក្រុបាត់បញ្ចូលគ្នាផងបើចាំបាច់) ។ បើភាគទុនិកៈជាគ្រឹះស្ថានហិរញ្ញវត្ថុ ត្រូវផ្តល់ពត៌មានពីអនុបាតប្រុងប្រយ័ត្នសំខាន់ៗ ។

**ប្រការ ៦ :** បុគ្គលម្នាក់ក្នុងចំណោមពីររូប (២រូប) ដែលត្រូវបានតែងតាំងក្នុងមុខតំណែងគ្រប់គ្រងដូចជាការទទួលខុសត្រូវក្នុងការដឹកនាំអាជីវកម្មធនាគារឲ្យមានប្រសិទ្ធភាព ត្រូវផ្តល់ពត៌មានដូចខាងក្រោមនេះ(២) ដោយបំពេញជីវប្រវត្តិ និងសំណួរដូចមានក្នុងឧបសម្ព័ន្ធទី៥

ក- អត្តសញ្ញាណរបស់នាយកចាត់ការ ៖

- នាម និង គោត្តនាម
- ថ្ងៃខែឆ្នាំ និងទីកន្លែងកំណើត
- សញ្ជាតិ
- អាស័យដ្ឋានផ្ទាល់ខ្លួន (ត្រូវមានទីកន្លែងស្នាក់នៅ ក្រោយពេលបានទទួលការតែងតាំង បើមានការផ្លាស់ប្តូរ ។ នាយកចាត់ការត្រូវមានកន្លែងស្នាក់នៅជិតកន្លែងសំខាន់សំរាប់ធ្វើអាជីវកម្ម ដូចជានៅក្នុង ប្រទេសកម្ពុជា)

ខ- គុណវុឌ្ឍិនិងបទពិសោធន៍ ៖

- សញ្ញាប័ត្រ ក៏ដូចជាថ្ងៃខែឆ្នាំនិងទីកន្លែងទទួលសញ្ញាប័ត្រ
- មុខតំណែងដែលបានកាន់កាប់ក្នុងរយៈពេលដប់ឆ្នាំ (១០ឆ្នាំ) ចុងក្រោយ ដោយមានឈ្មោះ ទីកន្លែងនិងសកម្មភាពរបស់និយោជក ប្រភេទបទពិសោធន៍មទួលបាន និងកំរិតទទួលខុសត្រូវ

គ- បញ្ជាក់ថា តើក្នុងការអនុវត្តន៍ភារកិច្ចរបស់ខ្លួន នាយកចាត់ការនឹងចូលរួមសហការឬមានការព្រមព្រៀងជាមួយគ្រឹះស្ថានជាឯកត្តជន ឬជានីតិបុគ្គលមួយផ្សេងទៀត ក្រៅពីអ្នកដាក់ពាក្យសុំឬទេ ។ ក្នុងករណីណាមួយ ក៏ត្រូវផ្តល់ពត៌មានទាំងអស់ដែលពាក់ព័ន្ធ

ឃ-រៀបរាប់ពីភារកិច្ចគ្រប់គ្រង ដែលនាយកចាត់ការទទួលខុសត្រូវដោយផ្ទាល់

ង- បញ្ជាក់ថា តើនាយកចាត់ការនៅជាឬធ្លាប់បានធ្វើជាភាគទុនិកៈសំខាន់ (ដូចជាបានកាន់កាប់ភាគហ៊ុនដោយផ្ទាល់ឬដោយប្រយោលយ៉ាងតិចបំផុតដប់ភាគរយ (១០%) នៃដើមទុនឬនៃសិទ្ធិបោះឆ្នោត) នៃក្រុមហ៊ុនណាមួយក្រៅពីអ្នកដាក់ពាក្យស្នើសុំឬទេ ។ ប្រសិន បើមាន ត្រូវប្រាប់ឈ្មោះនិងសកម្មភាពរបស់ក្រុមហ៊ុន ចំនួនប្រាក់និងភាគហ៊ុនរបស់ខ្លួនឬផលប្រយោជន៍ក្នុងក្រុមហ៊ុននោះ

ច- ប្រាប់តាមការយល់ដឹងរបស់ខ្លួនថា តើក្រុមហ៊ុនណាខ្លះដែលខ្លួនបានកាន់កាប់តំណែងជាអ្នកទទួលខុសត្រូវឬក្នុងក្រុមហ៊ុនណាដែលខ្លួនជាភាគទុនិកៈសំខាន់ ឬដែលខ្លួនមាន ទំនាក់ទំនងអាជីវកម្មសំខាន់ជាមួយអ្នកស្នើសុំ

ឆ- បញ្ជាក់ថា តើនៅកម្ពុជាឬនៅបរទេស ខ្លួនធ្លាប់បានទទួលរងនូវទណ្ឌកម្មតាមនីតិវិធីវិជ្ជាជីវៈ រដ្ឋបាលឬតុលាការឬទេ ។ ត្រូវរាយលំអិតនូវពត៌មានទាំងអស់ឲ្យបានគរមស្រប

ជ- បញ្ជាក់ថា តើខ្លួនធ្លាប់បានទទួលរងនូវវិន័យ ឬការបណេ្តញពីនិយោជកណាមួយ ដែរឬទេ ។ បើមាន ត្រូវរាយរលំអិតនូវពត៌មានដែលពាក់ព័ន្ធទាំងអស់

---

កំណត់សំគាល់

(២) ចំពោះការតែងតាំងនាយកប្រតិបត្តិការ ធនាគារជាតិនៃកម្ពុជាត្រូវមានរាល់ពត៌មានទាំងអស់ ដើម្បីអាចវាយតំលៃពីកិត្តិនាម ភាពត្រឹមត្រូវនិងភាពថ្លៃថ្នូររបស់បុគ្គលដែលពាក់ព័ន្ធ ។

ឈ-បញ្ជាក់ថា តើខ្លួនជាអ្នកផ្តល់ដើមទុនទៅឲ្យអ្នកស្នើសុំឬទេ ហើយតើខ្លួនមានបំណងអនុវត្តដោយផ្ទាល់ឬតាមរយៈអន្តរការី នូវសកម្មភាពប្រតិបត្តិការឯកត្តជនឬវិជ្ជាជីវៈជាមួយអ្នកស្នើសុំឬទេ

ញ-ផ្តល់ពត៌មានបន្ថែមទាំងអស់ដែលអាចជួយបំភ្លឺដល់ធនាគារជាតិនៃកម្ពុជា

ដ- រាល់ចម្លើយទាំងអស់ដែលទាក់ទងទៅនឹងសំណួរខាងលើ ត្រូវផ្ញើជូនតាមរយៈជីវប្រវត្តិនិងសំណួរក្នុងឧបសម្ព័ន្ធទី៤ និងលិខិតស្របតាមគំរូលិខិតដូចមានក្នុងឧបសម្ព័ន្ធទី ២ ។

ប្រការ ៧ : ភាគទុនិកៈដែលកាន់កាប់ដោយផ្ទាល់ឬប្រយោល យ៉ាងតិចបំផុតម្ភៃភាគរយ (២០%) នៃដើមទុនឬនៃសិទ្ធិបោះឆ្នោត ត្រូវបានចាត់ទុកថាជាភាគទុនិកៈមានឥទ្ធិពល ស្របតាមមាត្រា ២៦ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។ ភាគទុនិកៈមានឥទ្ធិពលត្រូវបានធនាគារជាតិនៃកម្ពុជាតំរូវឲ្យបង្កើនមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ តាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ២៧ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។ សំរាប់គោលបំណងនោះ ត្រូវផ្ញើលិខិតដូចមានគំរូ នៅក្នុងឧបសម្ព័ន្ធទី៣ ទៅទេសាភិបាលធនាគារជាតិនៃកម្ពុជា ។

បទបញ្ញានេះអាចត្រូវដកចេញវិញបាន តែនៅពេលមានការបង្កើតឲ្យមានការធានារ៉ាប់រងលើប្រាក់បញ្ញើ នៅកម្ពុជា ។

## ជំពូក ទី ៣

## ការអនុម័តផ្តល់អាជ្ញាប័ណ្ណ និង ការយកកំរៃ

ប្រការ ៨ : ធនាគារជាតិនៃកម្ពុជាត្រូវជូនដំណឹងជាលាយលក្ខអក្សរអំពីការសំរេចរបស់ខ្លួន ក្នុងរយៈពេលប្រាំមួយខែ (៦ខែ) ចាប់ពីពេលទទួលពាក្យស្នើសុំអាជ្ញាប័ណ្ណ រួមទាំងឯកសារដែលពាក់ព័ន្ធ

ទាំងអស់ផង ។ នៅពេលណាមានការចាំបាច់ ធនាគារជាតិនៃកម្ពុជានឹងដាក់ចេញនូវលក្ខខណ្ឌ និងរយៈពេលនៃការអនុវត្តន៍លិខិតអនុញ្ញាត ។ ប្រសិនបើអនុវត្តពុំបានតាមពេលវេលាកំណត់ខាងលើលិខិតអនុញ្ញាតត្រូវចាត់ទុកជាមោឃៈលើកលែងតែមានការស្នើសុំពន្យារពេល និងការយល់ព្រមពីធនាគារជាតិនៃកម្ពុជា ។

**ប្រការ ៩ :** អាជ្ញាប័ណ្ណមានសុពលភាពសំរាប់រយៈពេលបីឆ្នាំ (៣ឆ្នាំ) គិតចាប់ពីពេលបានចេញថ្មី ។ អាជ្ញាប័ណ្ណនេះអាចស្នើសុំបន្តជាថ្មីបាន ល្មើកលែងតែរាល់ការប្រព្រឹត្តិល្មើសច្បាប់និងបទបញ្ញត្តិត្រូវបានដោះស្រាយ ។ ពាក្យស្នើសុំបន្តអាជ្ញាប័ណ្ណជាថ្មីត្រូវដាក់ជូនធនាគារជាតិនៃកម្ពុជា យ៉ាងយឺតបំផុតបីខែ (៣ខែ) មុនពេលផុតសុពលភាព នៃអាជ្ញាប័ណ្ណដែលកំពុងប្រើប្រាស់ ។

ក្នុងករណីមិនបានដាក់ពាក្យស្នើសុំបន្ត តាមកាលកំណត់ខាងលើនេះទេ ធនាគារសាមីត្រូវទទួលរងការផាកពិន័យជាប្រាក់មួយលានរៀល (១.០០០.០០០ រៀល) ក្នុងមួយថ្ងៃ រហូតដល់ថ្ងៃបានដាក់ពាក្យស្នើសុំនេះ ។

**ប្រការ ១០ :** អ្នកដាក់ពាក្យសុំត្រូវបង់សោហ៊ុយសិក្សាសំណុំលិខិតជាប្រាក់ចំនួនបីលានប្រាំសែន រៀល (៣.៥០០.០០០ រៀល) នៅពេលដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណ ។

**ប្រការ ១១ :** ធនាគារ និងសាខាធនាគារត្រូវបង់សោហ៊ុយអាជ្ញាប័ណ្ណប្រចាំឆ្នាំចំនួនចិតសិបលានរៀល (៧០.០០០.០០០ រៀល) ចំពោះទីស្នាក់ការកណ្តាលធនាគារ និងហាសិបប្រាំមួយលានរៀល (៥៦.០០០.០០០ រៀល) ចំពោះសាខានីមួយៗរបស់ធនាគារ នៅមុន ថ្ងៃទី ១៥ ខែ មករា រៀងរាល់ឆ្នាំ ។ ចំពោះធនាគារដែលបានបង្កើតឡើងក្នុងឆ្នាំ សោហ៊ុយអាជ្ញាប័ណ្ណត្រូវគណនាតាមសមាមាត្រនៃរយៈពេលដែលនៅសល់រហូតដល់ដំណាច់ឆ្នាំ ។ ក្នុងករណីមានការយឺតយ៉ាវក្នុងការបង់សោហ៊ុយអាជ្ញាប័ណ្ណធនាគារដែលពាក់ព័ន្ធ ត្រូវទទួលរងនូវការផាកពិន័យដោយបង់ការប្រាក់លើទឹកប្រាក់ដែលនៅមិនទាន់បានបង់តាមអត្រាការប្រាក់បុនហិរញ្ញប្បទានជាធរមាន ក្នុងរយៈពេលរហូតដល់សាមសិបថ្ងៃ (៣០ថ្ងៃ) ។ បើនៅតែពុំអាចបង់សោហ៊ុយអាជ្ញាប័ណ្ណនេះបាន ធនាគារសាមីត្រូវរងទណ្ឌកម្មធ្ងន់ជាងនេះទៀតរហូតដល់ត្រូវដកហូតអាជ្ញាប័ណ្ណ ។

## ជំពូក ទី ៤
## បទប្បញ្ញត្តិផ្សេងៗ

**ប្រការ ១២ :** ធនាគារដែលបានទទួលអាជ្ញាប័ណ្ណហើយ ត្រូវតំកល់ប្រាក់ចំនួនស្មើនឹងដប់ភាគរយ (១០%) នៃដើមទុនចុះក្នុងលក្ខន្តិកៈ នៅក្នុងគណនីដែលបានបើកនៅធនាគារជាតិនៃកម្ពុជាជាអចិន្ត្រៃយ៍ ក្នុងនោះប្រាំភាគរយ (៥%) គ្មានការប្រាក់ និងប្រាំភាគរយ (៥%) ទៀតត្រូវបានផ្តល់ការប្រាក់ចិតសិបប្រាំភាគរយ (៧៥%) នៃអត្រា SIBOR (អត្រាការប្រាក់អន្តរធនាគារនៅសិង្ហបុរី) ដែលមានកាលកំណត់ប្រាំមួយខែ (៦ខែ) ។

ធនាគារជាតិនៃកម្ពុជាទូទាត់សងប្រាក់តំកល់ធានាលើដើមទុនទៅឲ្យធនាគារវិញ តែនៅពេលធនាគារនេះត្រូវបានជំរះបញ្ជីដោយស្ម័គ្រចិត្តនិងគ្មានប្រាក់បញ្ញើនៅខាងទ្រព្យអកម្ម ។

ប្រការ ១៣ : សេចក្តីជូនដំណឹងទាក់ទងដល់ការទទួលបានឬការបាត់បង់ទៅវិញនូវភាគហ៊ុន ក្នុងក្របខ័ណ្ឌនៃមាត្រា ២៣ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវមានបញ្ចូលការពិពណ៌នាពីមូលហេតុផ្សេងៗសំរាប់ សកម្មភាពប្រតិបត្តិការនិងគោលដៅដែលត្រូវអនុវត្តតាម ។

ឯកសារជូនដំណឹងក៏ត្រូវមានពត៌មានបញ្ជាក់ក្នុងប្រការ ៥ ខាងលើ ស្តីពីភាគទុនិកៈដែលពាក់ព័ន្ធ ។

ធនាគារពាក់ព័ន្ធត្រូវបង់គោរកើយផ្ទេរហ៊ុនចំនួនមួយភាគរយ (១%) លើចំនួនប្រាក់ហ៊ុនដែលត្រូវបានផ្លាស់ប្តូរ ។

ប្រការ ១៤ : ការអនុញ្ញាតចំពោះពាក្យស្នើសុំទាក់ទងដល់ការទទួលបាន ឬការបាត់បង់ទៅវិញនៃភាគហ៊ុនក្នុងក្របខ័ណ្ឌនៃមាត្រា ២៤ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវមានបញ្ចូលការពិពណ៌នាពីមូលហេតុផ្សេងៗសំរាប់សកម្មភាពប្រតិបត្តិការនិងគោលដៅដែលត្រូវអនុវត្តតាម ។

ឯកសារស្នើសុំក៏ត្រូវមានពត៌មានដូចមានបញ្ជាក់ក្នុងប្រការ ៥ ខាងលើ ស្តីពីភាគទុនិកៈដែលពាក់ព័ន្ធ ។ ភាគទុនិកៈដែលមានបំណងកាន់កាប់ដោយផ្ទាល់ឬដោយប្រយោលយ៉ាងតិចបំផុតម្ភៃភាគរយ (២០%) នៃដើមទុន ឬ នៃសិទ្ធិបោះឆ្នោតត្រូវធ្វើប្រតិវេទន៍ ស្របតាមគំរូដែលមានក្នុងឧបសម្ព័ន្ធ ទី៣ ។ ជាងនេះទៀត ធនាគារពាណិជ្ជកម្មពាក់ព័ន្ធត្រូវបង់គោរកើយចំនួនមួយភាគរយ (១%) លើចំនួនប្រាក់ដែលត្រូវបានផ្លាស់ប្តូរ ដូចបានចែងនៅប្រការ ១៣ ខាងលើ ។

ប្រការ ១៥ : ក្នុងករណីតែងតាំងអ្នកចាត់ការថ្មី (គឺបុគ្គលពីររូប ដែលទទួលខុសត្រូវក្នុងការដឹកនាំប្រតិបត្តិការធនាគារឲ្យមានប្រសិទ្ធភាព) ត្រូវផ្តល់ពត៌មានដូចខាងក្រោមនេះ ទៅធនាគារជាតិនៃកម្ពុជា ៖

- អ្នកចាត់ការថ្មីត្រូវធ្វើលិខិតតាមគំរូដូចមានក្នុងឧបសម្ព័ន្ធទី ២ ផ្តល់ពត៌មានជូនទេសាភិបាលធនាគារជាតិនៃកម្ពុជាពីការតែងតាំងខ្លួនជាអ្នកចាត់ការ ហើយដោយមានបញ្ជាក់ពីមុខតំណែងរបស់ខ្លួនផង
- ឯកសារជាភស្តុតាងបញ្ជាក់ពីការតែងតាំង (មានជាអាទិ៍កំណត់ហេតុប្រជុំក្រុមប្រឹក្សាភិបាល)
- ពត៌មានដូចមានចែងក្នុងប្រការ ៦ នៃប្រកាសនេះ
- ឯកសារទាំងអស់នេះត្រូវតែផ្តល់ឲ្យយ៉ាងហោចណាស់មួយខែ មុនការចូលកាន់តំណែងរបស់បុគ្គលដែលត្រូវបានតែងតាំង ។

១

ប្រការ ១៦ : ការផ្លាស់ប្តូរផ្សេងទៀតនៃស្ថានភាពគតិយុត្ត ឬស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារត្រូវតែដាក់ជូនធនាគារជាតិនៃកម្ពុជាដើម្បីសុំការយល់ព្រម ។ ឯកសារស្នើសុំត្រូវមានភ្ជាប់មកជាមួយនូវការរៀបរាប់ពីមូលហេតុនៃ ផែនការប្រតិបត្តិការ ហើយផ្អែកតាមករណីនីមួយៗ ត្រូវមានភ្ជាប់នូវពត៌មានដូច តទៅ ៖

- ការពង្រីកឬការកំណត់ឡើងវិញនូវសកម្មភាព ៖ ត្រូវផ្តល់ពត៌មានដែលមានកំណត់ក្នុងកថាខ័ណ្ឌ ដ ប្រការ ៤ នៃប្រកាសនេះ
- ការបន្ថយដើមទុន ៖ពិពណ៌នាពីខ្លឹមសារនិងលក្ខខ័ណ្ឌដូចជាការសំរបសំរួលខាងគតិយុត្ត និងខាងគណនេយ្យព្រមទាំងការកំណត់ច្បាស់នូវចំនួនថ្មីនៃមូលនិធិផ្ទាល់ដែលអាចមានឥទ្ធិពលទៅលើអាជីវកម្ម ទៅអនាគតនិងទៅលើអនុបាតប្រុងប្រយ័ត្ន
- ការផ្លាស់ប្តូររូបភាពគតិយុត្ត ៖ សេចក្តីព្រាងវិសោធនកម្មលក្ខន្តិកៈ និងពត៌មានទាក់ទងដល់អង្គភាពគ្រប់គ្រង
- ការផ្លាស់ប្តូរនាមករណ៍អាជីកម្ម ៖ សេចក្តីព្រាងវិសោធនកម្មលក្ខន្តិកៈ
- រាល់ការផ្លាស់ប្តូរទាំងអស់ ត្រូវដាក់ជូនធនាគារជាតិនៃកម្ពុជាយ៉ាងតិចបំផុតបីខែ (៣ខែ) មុនពេលអនុវត្តដើម្បីសុំការយល់ព្រម

ធនាគារត្រូវបង់សោហ៊ុយចំនួនមួយលានរៀល (១.០០០.០០០ រៀល) ក្នុងមួយទំព័រនៃលក្ខន្តិកៈដែលរងវិសោធនកម្ម ។

ធនាគារត្រូវបង់សោហ៊ុយបន្ថយដើមទុនចំនួនមួយភាគរយ (១%) លើចំនួនដែលបន្ថយ ។

ប្រការ ១៧ : រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ១៨ : អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាពគ្រប់គ្រឹះស្ថានធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ នៅក្រោមឱវាទនិងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្ត ម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ។

ប្រការ ១៩ : ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសាភិបាល

ហត្ថលេខានិងត្រា

ជា ចាន់តូ

★★★

ឧបសម្ព័ន្ធទី ១

**គំរូលិខិតស្នើសុំអាជ្ញាប័ណ្ណ(១) ឬ ធ្វើប្រតិវេទន៍(២) ឬ សុំការអនុញ្ញាត(៣)**
**ដែលត្រូវផ្ញើជូន**
**ឯកឧត្តមអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា**

ឯកឧត្តមជាទីគោរព

ក្នុងនាមជា..........................................(៤)

ខ្ញុំសូមដាក់ជូនធនាគារជាតិនៃកម្ពុជាដើម្បី ៖

- ទទួលឬបន្តអាជ្ញាប័ណ្ណរបស់ (ឈ្មោះក្រុមហ៊ុន) ដូចមាននៅក្នុងជំពូកទី ៤ នៃច្បាប់ស្ដីអំពីគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ
- ធ្វើប្រតិវេទន៍ពាក់ព័ន្ធនិងការធ្វើលទ្ធកម្មឬអនុប្បទានភាគទុនដូចមានក្នុងមាត្រាទី ២៣ នៃច្បាប់ស្ដីពីគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ
- សុំការអនុញ្ញាតធ្វើលទ្ធកម្មឬអនុប្បទានភាគទុនដូចមានក្នុងមាត្រាទី ២៤ នៃច្បាប់ស្ដីពីគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ ។

ជាទីបញ្ចប់ ខ្ញុំសូមភ្ជាប់មកជាមួយនូវពាក្យសុំស្របតាមបញ្ញត្តិនៃ ប្រកាសលេខ.........

សូមឯកឧត្តមទេសាភិបាលទទួលនូវគារវកិច្ចដ៏ស្មោះស្ម័គ្រអំពីយើងខ្ញុំ ។

ហត្ថលេខា

***

(១) ក្នុងករណីស្នើសុំអាជ្ញាប័ណ្ណ រឺ សុំបន្តអាជ្ញាប័ណ្ណ

(២) ក្នុងករណីប្រែប្រួលភាគហ៊ុនដូចមានក្នុងមាត្រាទី ២៣ នៃច្បាប់ស្ដីពីគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ

(៣) ក្នុងករណីប្រែប្រួលភាគហ៊ុនដូចមានក្នុងមាត្រាទី ២៤ នៃច្បាប់ស្ដីពីគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ

(៤) ផ្ដល់គំរូហត្ថលេខារបស់ប្រធាន (Chaiman) នាយកចាត់ការ មន្ត្រីដទៃទៀតដែលជាភ្នាក់ងារបានទទួលសិទ្ធិអំណាច (ភ្ជាប់ឯកសារភស្ដុតាងមកជាមួយផង) ។

***

ឧបសម្ព័ន្ធ ២

**គំរូលិខិត**

**ផ្ញើជូនឯកឧត្តមអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា**

ឯកឧត្តមជាទីគោរព

យោងតាមការតែងតាំងនាយកធនាគារ (ឈ្មោះធនាគារ) ដែលខ្ញុំនឹងចូលកាន់តំណែងជា (.....) ខ្ញុំសូមភ្ជាប់មកជាមួយនូវពត៌មាន (រួមមានប្រវត្តិសង្ខេបនិងសំណួរ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ៤) តាមប្រការទី៦នៃ ប្រកាសលេខ..... តំរូវអោយមាន ។

ខ្ញុំសូមធានាថាពត៌មានទាំងនេះពិតជាត្រឹមត្រូវ និង ពេញលេញឆ្លើយតបទៅនឹងតំរូវការរបស់ធនាគារជាតិ ។ ជាពិសេសខ្ញុំសូមធានាអះអាងថាខ្ញុំពិតជាគ្មានជាប់ទាក់ទិនទៅនឹងការហាមឃាត់ណាមួយក្នុងមាត្រា១៨ នៃច្បាប់ស្តីអំពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

ខ្ញុំសូមសន្យាថា នឹងផ្តល់ពត៌មានស្តីពីការប្រែប្រួលណាមួយដែលទាក់ទងទៅនឹងពត៌មានខាងលើជូនធនាគារជាតិនៃកម្ពុជាភ្លាម ។

បន្ថែមលើនេះទៀត ក្នុងនាមជានាយកគ្រឹះស្ថានធនាគារខ្ញុំសូមធានាថានឹងផ្តល់ជូនធនាគារជាតិនៃកម្ពុជា នូវរាល់ពត៌មានដែលទាក់ទងទៅនឹងការចាត់តាំងរដ្ឋបាលនិងគណនេយ្យ ស្ថានភាពហិរញ្ញវត្ថុ ជាពិសេសចំពោះគុណភាពនៃឥណទាននិងស្ថានភាពហិរញ្ញវត្ថុរបស់ភាគទុនិកទាំងអស់ ។

សូមឯកឧត្តមទេសាភិបាលធនាគារជាតិទទួលនូវគារវកិច្ចដ៏ស្មោះស្ម័គ្រអំពីយើងខ្ញុំ ។

ហត្ថលេខា

★★★

ឧបសម្ព័ន្ធ ៣

**គំរូលិខិត**

**របស់ភាគទុនិកៈដែលកាន់កាប់ដោយផ្ទាល់ឬដោយប្រយោលនូវ**
**ចំនួន ២០ % ឬច្រើនជាងនេះនៃដើមទុនឬនៃសិទ្ធិបោះឆ្នោតរបស់ធនាគារ**
**ដែលត្រូវផ្ញើជូនឯកឧត្តមអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា**

ឯកឧត្តមទេសាភិបាលជាទីគោរព

ក្នុងនាមខ្លួនខ្ញុំជា (ប្រាប់ពីឋានៈ) ខ្ញុំសូមភ្ជាប់មកជាមួយនូវពត៌មានទាំងឡាយតាមសំណើរបស់ធនាគារជាតិនៃកម្ពុជាសុំ (តាមប្រកាសលេខ ............) ទាក់ទងទៅនឹងការកាន់កាប់ដើមទុនផ្ទាល់ដែល (ឈ្មោះភាគទុនិកៈ) មានបំណងចូលរួមនៅក្នុង (ឈ្មោះធនាគារ) ។

ខ្ញុំសូមបញ្ជាក់នៅក្នុងលិខិតនេះថា ពត៌មានទាំងនេះពិតជាត្រឹមត្រូវនិងគ្រប់គ្រាន់ ហើយថាតាមការយល់ដឹងដ៏ប្រសើរបំផុតរបស់ខ្ញុំ ពុំមានឯកសារបញ្ជាក់ការពិតណាផ្សេងពីនេះទៀតដែលត្រូវផ្ញើជូនធនាគារជាតិនៃកម្ពុជាទៀតទេ ។

ខ្ញុំសូមសន្យាថា នឹងផ្តល់ពត៌មានភ្លាមៗជូនធនាគារជាតិនៃកម្ពុជានូវរាល់ការប្រែប្រួលណាដែលខុសប្លែកយ៉ាងខ្លាំងពីពត៌មានដែលបានផ្តល់ជូនហើយ ។

ខ្ញុំបានកត់សំគាល់ទៅលើបទប្បញ្ញត្តិប្រការ ៧ នៃប្រកាសស្តីពីការផ្តល់អាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលបានចែងថានៅពេលណាស្ថានភាពត្រូវហើយនោះ ធនាគារជាតិនៃកម្ពុជាអាចបង្គាប់ឲ្យភាគទុនិកៈមានឥទ្ធិពលរបស់គ្រឹះស្ថានផ្តល់នូវការគាំទ្រដល់គ្រឹះស្ថាននោះ ។

សូមឯកឧត្តមទេសាភិបាលមេត្តាទទួលនូវការកិច្ចដ៏ស្មោះស្ម័គ្រអំពីយើងខ្ញុំ ។

ហត្ថលេខា

★★★

## ឧបសម្ព័ន្ធទី ៤

Photo
4 x 6

### ជីវប្រវត្តិ និង ការសាកសួរនូវពត៌មាន អំពី
### "ឯកត្តជន ឬ ជនដែលបំរុងក្លាយទៅជា : គណៈនាយក ភាគទុនិកៈ នាយកចាត់ការ របស់ធនាគារពាណិជ្ជ

## CURRICULUM VITAE

and

Questionnaire for individuals who are, or are proposing to become,
**Directors, Shareholders of Commercial Banks**

1- គោត្តនាម

family name

---------------------------------------------------------------------------------------------------

2- នាមខ្លួន

Given Name (s).

------------------------------------------------------------------------------------------------

3- ឈ្មោះហៅក្រៅ

Other name (s) by which you are or have been known

------------------------------------------------------------------------------------------------

4.1 សូមរៀបរាប់បំពេញលើតំរូវនេះនូវនីតិសម្បទារបស់លោក, ឧទាហរណ៍ដូចជា : គណៈនាយកបច្ចុប្បន្ន ឬជាអនាគតគណៈនាយក, ភាគទុនិក ឬ នាយកចាត់ការ ឬបុគ្គលដែលមានលក្ខណៈប្រហាក់ប្រហែលនេះ :

Please state in what capacity you are completing this form, i.e. as a current or prospective director, shareholder or manager or any combination of these.

------------------------------------------------------------------------------------------------

------------------------------------------------------------------------------------------------

------------------------------------------------------------------------------------------------

4-2 សូមរៀបរាប់អំពីភារកិច្ច និង ការទទួលខុសត្រូវណាមួយដែលទាក់ទងនឹងឋានៈនាទីទាំងនេះ

Please describe the particular duties and responsibilities attaching to the position (s)

------------------------------------------------------------------------------------------------

------------------------------------------------------------------------------------------------

------------------------------------------------------------------------------------------------

------------------------------------------------------------------------------------------------

------------------------------------------------------------------------------------------------

------------------------------------------------------------------------------------------------

4-3 ក្នុងការអនុវត្តន៍ភារកិច្ចរបស់អ្នក តើអ្នកនឹងសហប្រតិបត្តិការជាមួយ ឬយល់ស្របតាមការបង្គាប់បង្គាញ់របស់រូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយក្រៅពីបេក្ខជនដាក់ពាក្យសុំ ។ ករណីណាមួយក៏ដោយសូមផ្តល់នូវពត៌មានដែលពាក់ព័ន្ធទាំងនេះ ។

In carrying out your duties, will you act in concert with or in accordance with the instructions of another individual or legal person outside the applicant. In either case, give all relevant information.

4-4 សូមបញ្ជាក់បើសិនជាអ្នកជា អ្នកផ្តល់ទុនម្នាក់ទៅអោយបេក្ខជនដាក់ពាក្យសុំ ហើយបើសិនជាអ្នកមានបំណងធ្វើអន្តរប្រតិបត្តិការផ្ទាល់ ឬតាមរយៈអន្តរការីកម្មណាមួយ ឬផ្ទាល់ខ្លួនឬជាប្រតិបត្តិការវិជ្ជាជីវៈជាមួយបេក្ខជនទាំងនេះ ។

Indicate if you are a contributor of capital to the applicant and if you intend to carry out, directly or through an intermediary, personal or professional transactions with the applicant.

5- អាសយដ្ឋានផ្ទាល់ខ្លួន

Your private address.

6- អាសយដ្ឋានផ្ទាល់ខ្លួនដែលធ្លាប់បានរស់នៅកន្លងមក ចាប់ពីកំឡុង ៥ ឆ្នាំមុន :

Your previous private address (es) during the last 5 years.

7- កាលបរិច្ឆេទ (ថ្ងៃ/ ខែ/ ឆ្នាំ) និងទីកន្លែងកើត (គិតទាំងស្រុកនិងក្រុង)

Your date (day/month/year) and place of birth (including district, town or city).

------------------------------------------------------------

------------------------------------------------------------

------------------------------------------------------------

------------------------------------------------------------

8- សញ្ជាតិ ហើយតើសញ្ជាតិនោះត្រូវបានដោយរបៀបណា (កើតនៅទីនោះ, សញ្ជាតូបនីយកម្ម, ការរៀបអាពាហ៍ពិពាហ៍) ?

Your nationality and how it was acquired (birth, naturalization, marriage).

------------------------------------------------------------

------------------------------------------------------------

9- ឈ្មោះ និង អាសយដ្ឋាននៃធនាគាររបស់លោក-លោកស្រី ក្នុងរយៈពេល៥ឆ្នាំកន្លងមក

Name(s) and address(es) of your bankers within the last 5 years.

------------------------------------------------------------

------------------------------------------------------------

------------------------------------------------------------

10- ចូរបញ្ជាក់ពីកំរិតចំណេះដឹង និង គុណវុឌ្ឍិវិជ្ជាជីវៈ ព្រមទាំងទីកន្លែង និងឆ្នាំដែលបានទទួល

Your higher education and/or professional qualifications and the place and year they were obtained.

------------------------------------------------------------

------------------------------------------------------------

------------------------------------------------------------

------------------------------------------------------------

------------------------------------------------------------

11-1 ចូររៀបរាប់អំពីមុខរបរ និងការងារដែលបានធ្វើក្នុងពេលបច្ចុប្បន្ន និងរយៈពេល១០ឆ្នាំកន្លងមកដោយបញ្ជាក់ពីឈ្មោះអាសយដ្ឋានរបស់និយោជកក្នុងករណីនីមួយៗ, ចរិតនៃមុខជំនួញ, ស្ថានភាពដែលមាននិងកាលបរិច្ឆេទពាក់ព័ន្ធ ។

Your occupation and employment now and during the **last 10 years,** including the name and address of the employer in each case, the nature of the business, the position held and relevant dates.

11-2 សូមបញ្ជាក់ការពេល១០ឆ្នាំមុន បើសិនជាអ្នកជាភាគទុនិកដែលមានឈ្មោះកាន់កាប់ផ្ទាល់ ឬដោយប្រយោលនូវ១០ភាគរយយ៉ាងតិចនៃដើមទុន ឬនៃសិទ្ធិបោះឆ្នោតនៃក្រុមហ៊ុនមួយក្រៅពីក្រុមហ៊ុនបេក្ខជន បើសិនជាមានសូមបញ្ជាក់ឈ្មោះនិងសកម្មភាពក្រុមហ៊ុននេះ និងចំនួនភាគហ៊ុនព្រមទាំងអត្ថប្រយោជន៍ផ្សេងៗ ទៀតរបស់អ្នកចំពោះក្រុមហ៊ុននេះ ។

Indicate if you are or if you have been in the last ten years a significant shareholder (namely holding directly or indirectly at least 10 % of the share capital or voting rights other than the applicant. If it is the case, state the name and activities of such companies and the amount of your shareholding or interest in them.)

11 3 សូមបញ្ជាក់ចំពោះការដែលដឹងរបស់លោក ក្រុមហ៊ុនដែលអ្នកកាន់កាប់ ឬបានកាន់កាប់តួនាទីទទួលខុសត្រូវក្នុងចំណែកក្រុមហ៊ុនមួយ ឬជាភាគទុនិកសំខាន់មួយដែលមានទំនាក់ទំនងអាជីវកម្មជាមួយអ្នកដាក់ពាក្យសុំ ។

State, to the best of your knowledge, which of the companies in which you have held or hold a position of responsibility, or in which you have been or are a significant shareholder, has or might soon have significant business rilations with the applicant.

12- តើខ្លួនលោក-លោកស្រីធ្លាប់ ឬអង្គភាពណាមួយដែលលោក-លោកស្រីរួមជាស្រ័យក្នុងឋានៈជានាយក, ជាភាគទុនិក ឬជាអ្នកចាត់ការ ធ្លាប់ទទួល ឬធ្លាប់ស្នើសុំអាជ្ញាប័ណ្ណ ឬធ្លាប់ចាត់ចែងសកម្មភាពជំនួញ នៅក្នុងប្រទេសណាមួយដែរឬទេ ? បើមាន សូមបញ្ជាក់នូវចំណុចពិសេសៗ ប្រសិនបើការស្នើនោះត្រូវបានបដិសេធ ឬត្រូវដកវិញបន្ទាប់ពីបានធ្វើហើយ ឬបានដកហូតការអនុញ្ញាត ក៏ត្រូវបញ្ជាក់ចំណុចពិសេសៗដែរ ។

Have you or any entity with which you are associated as a director, shareholder or manager, ever held or applied for a license or to carry on any business activity in any country ? If so, giv particulars, if any such application was refused or withdrawn after it was made or any authorization revoked , give particulars.

13- តើខ្លួនលោក-លោកស្រីធ្លាប់ ឬអង្គភាពណាមួយដែលលោក-លោកស្រីបានពាក់ព័ន្ធជាមួយក្នុងការអនុវត្តន៍កិច្ចការរបស់ខ្លួន ធ្លាប់ត្រូវបានអាជ្ញាធរអោយលោកព្រមាន ឬអង្គភាពវិជ្ជាជីវៈណាមួយព្រមានជាសាធារណៈ ឬជាកម្មវត្ថុដែលត្រូវគេធ្វើការស៊ើបអង្កេតដែរឬទេ ? បើមានសូមបញ្ជាក់ ។

Have you or any entity with which you have been involved in the conduct of its affairs, been disciplined, warned as to future conduct, publicly criticized, or the subject of an investigation by any regulatory authority or any professional body ? If so, give particulars.

14- តើលោក-លោកស្រី ធ្លាប់បានបញ្ឈប់ពីការងារ ឬ ត្រូវបណ្តេញចេញពីការងារ ដោយនិយោជក ឬ ត្រូវគេហាមមិនអោយចូលប្រកបវិជ្ជាជីវៈជំនាញឬបំរើការងារណាមួយដែរឬទេ? បើមានសូមបញ្ជាក់ ។

Have you, in any country, been dismissed from any office or employment by your imployer or barred from entry to any professional or occupation ? If so, give particulars.

15- តើធ្លាប់ មានបញ្ហាដែលពាក់ព័ន្ធនឹងការកាត់ក្តីរបស់តុលាការពីការជំពាក់បំណុល មិនព្រមបង់ដែលត្រូវតែសង ដែរឬទេ ? តើធ្លាប់មានប្រកាសក្តីពីការក្ស័យធនតាមលក្ខណៈគតិយុត្តដែរឬទេ? នៅប្រទេសណា ? តើធ្លាប់ទទួលរងការប្តឹងលើក្ស័យធនដែរឬទេ ? បើមានសូមបញ្ជាក់ក្នុងករណីនីមួយៗអោយបាន ច្បាស់លាស់ ។

Have you, failed to satisfy any debt adjudged due and payable by you under an order of a court, or have you been declared bankrupt by a court in any country or has a bankruptcy petition ever been seved on you ? If so, give particulars.

---

---

---

---

---

---

16- តើធ្លាប់មានពាក់ព័ន្ធនឹងការគ្រប់គ្រងអង្គភាពណាខ្លះ ដែលត្រូវតុលាការកាត់សេចក្តីពីបទឆបោក, នៅ ប្រទេសណា ? តើធ្លាប់បានទទួលខុសត្រូវលើកំហុសណាខ្លះ ឬ ការប្រព្រឹត្តិខុសផ្សេងៗ ដែលមាន ចំពោះអង្គភាពណាមួយឬសមាជិកណាម្នាក់ដែរឬទេ ? បើពិតជាមាន សូមបញ្ជាក់ករណីនីមួយៗ អោយបានច្បាស់លាស់ ។

Have you, in connection with the management of any entity been adjudged by a court, in any country, legally liable for any fraud, or other misconduct by you towards such an entity or towards any of its members ? If so, give particulars.

---

---

---

---

17- បច្ចុប្បន្ននេះ ក្រៅពីសមត្ថភាពវិជ្ជាជីវៈ តើលោក-លោកស្រីមានការពាក់ព័ន្ធនឹងការប្តឹងផ្តល់នៅប្រទេស ណាមួយទេ ? បើមានសូមបញ្ជាក់អោយច្បាស់លាស់ ។

Are you presently, or do you, other than in a professinal capacity, expect to be , engaged in any litigation in any country ? If so, give particulars.

---

---

18- សូមផ្តល់នូវរបាយការណ៍ត្រូវពិនិត្យ ស្តីពីមូលនិធិផ្ទាល់សុទ្ធរបស់ខ្លួន ដោយផ្តល់នូវតារាងលំអិតស្តីពីទ្រព្យសកម្ម និងទ្រព្យអកម្ម ។

Please supply an audited statement of personal net worth providing a breakdown of your assets and liabilities.

19- សូមបង្ហាញឈ្មោះ អាសយដ្ឋាន លេខទូរស័ព្ទ និង តួនាទីឬកិត្តិនាម របស់អ្នកតួជនបីរូប ដែលត្រូវមានលក្ខណៈសម្បត្តិល្អ ដើម្បីបញ្ជាក់ពីលក្ខណៈបុគ្គល និងវិជ្ជាជីវៈរបស់សាមីខ្លួន (សាក្សីដឹងឮជាបុគ្គលដែលមិនមែនជាសាច់ញាតិ ហើយធ្លាប់បានស្គាល់លោក-លោកស្រីយ៉ាងតិច៥ឆ្នាំ ) ។

Indicate the names, addresses, telephone numbers and positions of three individuals of good standing who would be able to provide a reference on your personal and professional integrity. **The referees must not be related to you, and should have known you for at least five years.**

20- បើសិនជាមានពត៌មានបន្ថែមទៀតដែលសមស្របនឹងមុខងារ-តួនាទីផ្ទាល់ខ្លួនដូចមានបញ្ជាក់ក្នុងសំណួរ ៤-១ ? សាមីជនគួរតែបញ្ជាក់បន្ថែមអោយបានច្បាស់លាស់ ដើម្បីជាគុណប្រយោជន៍សំរាប់ការពិនិត្យពិចារណាអោយត្រឹមត្រូវតាមទំរង់គតិយុត្ត ។ ករណីបំបាត់ចោលរាល់ព្រឹត្តិការណ៍រឿងរ៉ាវផ្សេងៗដែលពាក់ព័ន្ធ ដោយបង្វែរពត៌មានពិត ឬផ្តល់អោយនូវពត៌មានខុសពីការពិត នឹងត្រូវទទួលខុសត្រូវចំពោះច្បាប់ជាធរមាន (សូមអានសេចក្តីប្រកាសដូចខាងក្រោម) :

<u>ចូរកត់សំគាល់អោយបានច្បាស់ថា</u> : រាល់ពត៌មានដែលបានផ្តល់អោយ ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន ហើយរាល់ពត៌មានទាំងនេះ ត្រូវបានរក្សាទុកជាសំងាត់ដោយអាជ្ញាធរគ្រប់គ្រង (ធនាគារជាតិនៃកម្ពុជា) លើកលែងតែករណីដែលផ្តល់អោយស្របតាមទំរង់គតិយុត្ត ។

Is there any additional information which you consider is relevant for the consideration of your suitability for the position(s) listed in question 4.1 ? The omission of material facts may represent the provision of misleading information (see declaration below).

**N.B. (note well)** the information given in response to this questionnaire shall be kept fully confidential by the supervisory authority. The National Bank of Cambodia. Except in cases provided for by law.

## សេចក្តីប្រកាស ឬ កិច្ចសន្យាផ្ទាល់ខ្លួន

ខ្ញុំបាទសូមសន្យាថា នឹងទទួលខុសត្រូវនៅចំពោះមុខច្បាប់ បើសិនជាព័ត៌មានណាមួយដែលបានផ្តល់ជូននេះក្លែងក្លាយឬខុសពីការពិត ដែលពាក់ព័ន្ធនឹងការដាក់ពាក្យសុំអាជ្ញាប័ណ្ណ ឬបន្តអាជ្ញាប័ណ្ណប្រកបអាជីវកម្មគ្រឹះស្ថាន ។

ខ្ញុំបាទសូមបញ្ជាក់ជូនជាឧឡារិកថា ព័ត៌មានដែលបានអោយចម្លើយចំពោះសំណួរខាងលើ គឺពិតជាត្រឹមត្រូវ និងបានបំពេញបរិបូរណ៍ដោយចំណេះដឹងផ្ទាល់ខ្លួនរបស់ខ្ញុំបាទឬនាងខ្ញុំ ហើយពិតជាមិនមានហេតុការណ៍ផ្សេង ឬផ្ទុយពីសេចក្តីហេតុការណ៍ ដូចដែលបានបញ្ជាក់ជូនអាជ្ញាធរដែលគ្រប់គ្រង (តាមតួកិច្ច) ដើម្បីជ្រាបនោះឡើយ ។

ខ្ញុំបាទសូមសន្យាថា នឹងផ្តល់ព័ត៌មានជូនអាជ្ញាធរដែលគ្រប់គ្រង ដើម្បីជ្រាបអំពី រឿងរ៉ាវ ឬហេតុការណ៍ ដែលត្រូវផ្លាស់ប្តូរណាមួយដែលកើតមាន នៅពេលដែលអាជ្ញាធរគ្រប់គ្រងកំពុងពិនិត្យពិចារណាលើពាក្យស្នើសុំរបស់យើងខ្ញុំ ជ្រាបជាព័ត៌មាន ។

## DECLARATION

I am aware that it is an offense knowing or recklessly to provide any information which is false or misleading in connection with an application for a banking license or a renewal of bank license.

I certify that the information given in answer to the questions above is complete and accurate to the best of my knowledge, and that there are no other facts relevant to this application of which the supervisory authority should be aware.

I undertake to inform the supervisory authority of any changes material to the application which arise while the supervisory authority is considering the application.

ឈ្មោះ :

Name :

------------------------------------------------------------------------

មុខងារ និង ឋានៈដែលទទួលបន្ទុក

Position held :

------------------------------------------------------------------------

ហត្ថលេខា : ថ្ងៃ ខែ ឆ្នាំ :

Signed : Date : ......../......./.........

★★★

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០០០

**ប្រកាសលេខ ធ ៧០០-០៥ ប្រក**

**ស្តីពី**

**ការផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារឯកទេសឥណទានជនបទ**

***

**ទេសាភិបាល ធនាគារជាតិនៃកម្ពុជា**

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣៩៨/៩៥ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង ឯកឧត្តម **ជា ចាន់តូ** ជាអគ្គទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា
- យោងតាមសំណើរបស់នាយកដ្ឋានត្រួតពិនិត្យ

**សំរេច**

**ជំពូក ទី ១**

**បទប្បញ្ញត្តិទូទៅ**

**ប្រការ ១ :** ធនាគារឯកទេសឥណទានជនបទ តទៅនេះហៅថាធនាគារឯកទេស ដូចមានក់ណត់និយមន័យក្នុងជំពូកទី ១ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិង ហិរញ្ញវត្ថុត្រូវទទួលអាជ្ញាប័ណ្ណពីធនាគារជាតិ នៃកម្ពុជាមុនពេលចាប់ផ្តើមធ្វើប្រតិបត្តិការអនុលោមតាមមាត្រា ១៩ នៃច្បាប់ដដែលនេះ ។

**ប្រការ ២ :** ធនាគារឯកទេសដែលបានទទួលអាជ្ញាប័ណ្ណ ត្រូវធ្វើតែប្រតិបត្តិការណាដែលមានបញ្ជាក់ច្បាស់តាមខ្លឹមសារនៃលិខិតអនុញ្ញាត ។

**ប្រការ ៣ :** អ្នកដាក់ពាក្យសុំអាជ្ញាប័ណ្ណសំរាប់ធនាគារឯកទេស ត្រូវប្រកាន់យកនូវរូបភាពគតិយុត្តណាមួយក្នុងចំណោមរូបភាព គតិយុត្តដែលមានចែងក្នុងជំពូកទី ៣ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

**ប្រការ ៤ :** ធនាគារឯកទេស ត្រូវមានដើមទុនអប្បបរមាចុះក្នុងលក្ខន្តិកៈចំនួន ដប់ពាន់លានរៀល (១០.០០០.០០០.០០០ រៀល) ។

## ជំពូក ទី ២
## នីតិវិធីនៃការដាក់ពាក្យសុំអាជ្ញាប័ណ្ណ

**ប្រការ ៥ :** ពាក្យសុំអាជ្ញាប័ណ្ណ ត្រូវស្នើដោយបុគ្គល ដែលបានទទួលការអនុញ្ញាតត្រឹមត្រូវ (អ្នកចាត់ការ ឬជនដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ) គ្រប់តាមបញ្ជី ដែលមានរៀបរាប់ខាងក្រោមនេះ ៖

ក- នាម ឬ នាមករណ៍អាជីវកម្មរបស់គ្រឹះស្ថាន

ខ- អាសយដ្ឋាននៃទីស្នាក់ការកណ្តាលដែលបានចុះបញ្ជី

គ- រូបភាពគតិយុត្តនិងលក្ខន្តិកៈ ឬឯកសារបង្កើតផ្សេងៗទៀត

ឃ- ប្រភេទមូលប័ត្រតំណាងឲ្យដើមទុន ។ ចំណងទាក់ទងរវាងការកាន់កាប់មូលប័ត្រទាំងនោះនិងការអនុវត្តន៍សិទ្ធិបោះឆ្នោត

ង- ចំនួនដើមទុនផ្តល់ដែលបានអនុញ្ញាតនិងដែលបានបង់

ច- ការបែងចែកភាគហ៊ុន និងសិទ្ធិបោះឆ្នោត និងកិច្ចព្រមព្រៀងដែលអាចមានរវាងភាគទុនិកៈដែលដើរតួនាទីក្នុងការដឹកនាំគោលនយោបាយរបស់ធនាគារ

ឆ- ភាគទុនិកៈដែលកាន់កាប់ប្រាំភាគរយ (៥%) នៃសិទ្ធិបោះឆ្នោតឬលើសពីនេះត្រូវផ្តល់ព័ត៌មានដូចមានរៀបរាប់ក្នុងប្រការ ៦ នៃប្រកាសនេះ

ជ- អត្តសញ្ញាណរបស់បុគ្គលយ៉ាងតិចបំផុតពីររូប (២រូប) ដែលទទួលខុសត្រូវក្នុងការដឹកនាំដោយមានប្រសិទ្ធភាពនូវសកម្មភាពអាជីវកម្មរបស់ធនាគារឯកទេស ។

អ្នកចាត់ការដែលត្រូវបានតែងតាំងដោយអ្នកមានសមត្ថកិច្ច ត្រូវបំពេញជីវប្រវត្តិនិងសំណួរដូចមានក្នុងឧបសម្ព័ន្ធទី ២ ហើយ ត្រូវផ្តល់នូវលិខិតថ្កោលទោស

ឈ- អត្តសញ្ញាណរបស់សមាជិកក្រុមប្រឹក្សាភិបាលនិងដោយ បន្ថែមពីលើព័ត៌មានខាងលើត្រូវមានជីវប្រវត្តិ ព្រមទាំងមានរបាយការណ៍បញ្ជាក់ថា គ្មាននរណាម្នាក់ពាក់ព័ន្ធទៅនឹងការហាមឃាត់ដូចមានចែងក្នុងមាត្រា ១៨ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។ សមាជិកក្រុមប្រឹក្សាភិបាលត្រូវមាន បទពិសោធន៍ខាងឥណទានយ៉ាងតិចបំផុតបីឆ្នាំ (៣ឆ្នាំ)

ញ- ប្រសិនបើនីតិបុគ្គលដែលបានដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណ គឺជាអង្គភាពដែលបានបង្កើតរួចហើយ ត្រូវផ្តល់មកជាមួយនូវការអធិប្បាយអំពីមុខរបររបស់ខ្លួនព្រមទាំងតារាងតុល្យការដែលមានការបញ្ជាក់ពីស្នងការគណនី សំរាប់ប្រតិបត្តិការក្នុងរយៈពេលបីឆ្នាំ (៣ឆ្នាំ) ចុងក្រោយ

ដ- ការពិពណ៌នាពីផែនការសកម្មភាពអាជីវកម្មរយៈពេលបីឆ្នាំ (៣ឆ្នាំ) ទៅមុខ ៖

- ទំហំនៃការឲ្យខ្ចីគ្រប់ប្រភេទដែលអាចមាននៅក្នុង ឬក្រៅតារាងតុល្យការនិងគេរា ផ្សេងៗទៀតដែលត្រូវផ្តល់ឲ្យអតិថិជនឬសមាជិក (ចំពោះឥណទាន ប្រភេទ ទំរង់ គោលបំណង ខ្ទឹមសារ និងលក្ខខណ្ឌចំរៀងៗ គឺលក់ដែលទទួលបានប្រចាំឆ្នាំ និងទឹកប្រាក់មិនទាន់សង)
- ប្រភេទអតិថិជនដែលធនាគារឯកទេសមានបំណងប្រាស្រ័យទាក់ទង
- ប្រភពធនធានហិរញ្ញវត្ថុដែលរំពឹងទុក ៖ មូលនិធិផ្ទាល់ ប្រាក់ឧបត្ថម្ភ បំណុល បន្ទាប់ បន្សំ ប្រាក់បញ្ញើ ប្រាក់កម្ចី ជាដើម ហើយបើចាំបាច់ ត្រូវបញ្ជាក់ច្បាស់ពីដើមកំណើតនិងកម្មសិទ្ធិនៃធនធានទាំងនេះក្នុងករណីពិសេសក្រៅពី (បំណុលបន្ទាប់បន្សំជាដើម)
- ចំនួនប្រហាក់ប្រហែលនៃនិយោជិតក្នុងរយៈពេលបីឆ្នាំ (៣ឆ្នាំ) ខាងមុខ និងបញ្ជីបើកបៀវត្សរ៍ដោយបែងចែកតាមប្រភេទបុគ្គលិក
- ទីតាំងសាខាដែលមានស្រាប់ឬដែលគ្រោងឲ្យមាន
- ការចាត់តាំងនិងធនធាន ដែលបានគ្រោងទុក ពិសេសចំពោះប្រព័ន្ធគណនេយ្យ និងឧបករណ៍កុំព្យូទ័រ
- តារាងតុល្យការ និងការព្យាករណ៍គណនីខាត-ចំណេញ សំរាប់ការិយបរិច្ឆេទគណនេយ្យបីឆ្នាំ (៣ឆ្នាំ) ខាងមុខ ។ ត្រូវព្យាករណ៍ពីអនុបាតប្រុងប្រយ័ត្នចំរៀងៗ (ដូចបានកំណត់ដោយ ធនាគារជាតិនៃកម្ពុជា) នៅខាងចុងការិយបរិច្ឆេទ គណនេយ្យបីឆ្នាំ (៣ឆ្នាំ) ខាងមុខ

ឃ- ការត្រួតពិនិត្យផ្ទៃក្នុង

- ការចាត់តាំងផែនការត្រួតពិនិត្យបញ្ជីផ្ទៃក្នុងដែលមានចែងក្នុងមាត្រា ៤៣ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- អត្តសញ្ញាណរបស់ស្នងការគណនីឯករាជ្យ ដែលបានជ្រើសរើសពីបញ្ជីប្រតិគ្រុតិ
- ប្រភេទនៃមុខងារដែលត្រូវប្រគល់ឲ្យស្នងការគណនីឯករាជ្យនោះ ។

**ប្រការ ៦ :** ភាគទុនិកៈដែលកាន់កាប់ប្រាំភាគរយ (៥%) ឬលើសពីនេះនៃដើមទុន ឬនៃសិទ្ធិបោះឆ្នោតរបស់អ្នកស្នើសុំត្រូវផ្តល់ព័ត៌មានដូចតទៅ ៖

ក- អត្តសញ្ញាណរបស់ភាគទុនិកៈ ៖

ក្នុងករណីជានីតិបុគ្គល ត្រូវផ្តល់នាមករណ៍អាជីវកម្ម រូបភាពគតិយុត្ត អាសយដ្ឋានទីស្នាក់ការកណ្តាល និងលក្ខន្តិកៈ ។

ក្នុងករណីជារូបវន្តបុគ្គល ត្រូវរៀបរាប់ នាម គោត្តនាម ថ្ងៃខែឆ្នាំនិងទីកន្លែងកំណើត សញ្ជាតិនិងលំនៅដ្ឋាន ។ ត្រូវបញ្ជាក់ថា តើបុគ្គលនេះត្រូវបានតែងតាំងជាអ្នកចាត់ការមួយរូបរបស់ ធនាគារឬទេ ។ ត្រូវប្រាប់ថា តើភាគទុនិកៈជាសមាជិកនៃក្រុមប្រឹក្សាភិបាលរបស់គ្រឹះស្ថានឬទេ ។ បើមែន ត្រូវធានាថា សមាជិកនោះមិនមានពាក់ព័ន្ធជាមួយការហាមឃាត់ដូចមានចែងក្នុងមាត្រា ១៩ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុទេ

ខ- បញ្ជាក់ពីចំនួន និងភាគរយនៃភាគកម្មដែលបានស្នើនិងចំនួននិងភាគរយនៃសិទ្ធិបោះឆ្នោត ។ រៀបរាប់លំអិតពីការសម្រេចសម្រួលខាងគតិយុត្តនិងខាងហិរញ្ញវត្ថុ ចំពោះការទទួលយកមូលប័ត្រ ។ បង្ហាញថា តើសកម្មភាពប្រតិបត្តិការនៅក្រោមចំណុះនីតិវិធីដោយឡែកដែលអនុវត្ត ចំពោះការវិនិយោគបរទេសនៅកម្ពុជាឬទេ ហើយតើទម្រង់បែបបទទាំងនេះ ត្រូវបានបំពេញហើយឬនៅ

គ- រៀបរាប់ពីសកម្មភាពរបស់ភាគទុនិកៈ ។ ប្រសិនបើភាគទុនិកៈជាសមាជិកនៃក្រុមមួយ ត្រូវពិពណ៌នាពីសណ្ឋានភាពធំៗនៃក្រុមនោះរួមជាមួយអង្គការលេខផង ។ ត្រូវបញ្ជាក់ផងថា តើភាគទុនិកៈមាន ប្រយោជន៍សមុត្តិពុទ្ធិននៅក្នុងស្ថាប័នឥណទានផ្សេងៗទៀតឬទេ បញ្ជាក់ថា តើក្រុមដែលជាកម្មសិទ្ធិផ្ទាល់របស់ភាគទុនិកៈមានទុនពុទ្ធិននៅក្នុងគ្រឹះស្ថានឥណទាន ឬទេ ។ បើ មានត្រូវរៀបរាប់អោយអស់

ឃ- ប្រាប់ថា តើភាគទុនិកៈនិងក្រុមហ៊ុនដែលអាចបញ្ចូលជាមួយគ្នាមានធ្វើសកម្មភាពហិរញ្ញវត្ថុឬទេ ។ បើមានត្រូវបញ្ជាក់ថា ក្រុមហ៊ុនទាំងនោះស្ថិតក្រោមចំណុះបទបញ្ញត្តិណា ឬអាជ្ញាធរណា

ង- បញ្ជាក់ពីបែបបទនៃការត្រួតពិនិត្យ ផ្ទៃក្នុងនិងពីខាងក្រៅរបស់ភាគទុនិកៈ

ច- បញ្ជាក់ថា តើក្នុងរយៈពេលដប់ឆ្នាំ (១០ឆ្នាំ) កន្លងមក ភាគទុនិកៈបានទទួលរងនូវការស៊ើបអង្កេតឬទទួលរងនូវការពិន័យជាសំភារៈតាមទម្រង់ការវិជ្ជាជីវៈ រដ្ឋបាលឬតុលាការឬទេ

ឆ- ប្រាប់ពីគោលដៅរបស់ភាគទុនិកៈ ក្នុងការដាក់បញ្ចូលដើមទុនផ្ទាល់ទៅក្នុងធនាគារដែលបានដាក់ពាក្យសុំអាជ្ញាប័ណ្ណនិងផ្តល់ព័ត៌មានដែលពាក់ព័ន្ធទាំងអស់

ជ- បញ្ជាក់ថា តើមានទំនាក់ទំនងអាជីវកម្មសំខាន់ៗរវាងភាគទុនិកៈនិងអ្នកស្នើសុំឬទេ ហើយ តើទំនាក់ទំនងទាំងនេះនឹងត្រូវបានពង្រីកទៅអនាគតយ៉ាងណា

ឈ- បញ្ជាក់ថា តើទំនាក់ទំនងអាជីវកម្មសំខាន់ៗខាងធនាគាររបស់ភាគទុនិកៈនៅកម្ពុជាមានអ្វីខ្លះ ហើយទំនាក់ទំនងទាំងនេះនៅមានរហូតដល់ពេលណាទៀត ។

ប្រការ ៧ :

ភាគទុនិកៈដែលកាន់កាប់ដោយផ្ទាល់ឬប្រយោល យ៉ាងតិចបំផុតម្ភៃភាគរយ (២០%) នៃដើមទុនឬនៃសិទ្ធិបោះឆ្នោត ត្រូវបានចាត់ទុកថាជាភាគទុនិកៈមានឥទ្ធិពល ស្របតាមមាត្រា ២៦ នៃច្បាប់ស្ដីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។ ភាគទុនិកៈមានឥទ្ធិពលត្រូវបានធនាគារជាតិនៃកម្ពុជាតំរូវឲ្យបង្កើនមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ តាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ២៧ នៃច្បាប់ស្ដីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។ សំរាប់គោលបំណងនោះ ត្រូវធ្វើលិខិតដូចមានជូននៅក្នុងឧបសម្ព័ន្ធ ទី៣ ទៅទេសាភិបាលធនាគារជាតិនៃកម្ពុជា ។

បទបញ្ញានេះអាចត្រូវដកចេញវិញបាន តែនៅពេលបានបង្កើតឲ្យមានការធានារ៉ាប់រងលើប្រាក់បញ្ញើ នៅកម្ពុជា ។

ក្រៅពីនេះយោងតាមមាត្រា ៤០ នៃច្បាប់ស្ដីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាអាចលើកលែងជាពាយលក្ខអក្សរ អនុញ្ញាតឲ្យរួចផុតពីការអនុវត្តន៍ មាត្រា ៧ នៅពេលអនុម័តលើអាជ្ញាប័ណ្ណ ។

## ជំពូក ទី ៣
## ការអនុម័តផ្ដល់អាជ្ញាប័ណ្ណ និង ការយកកំរៃ

ប្រការ ៨ :

ធនាគារជាតិនៃកម្ពុជាត្រូវជូនដំណឹងជាលាយលក្ខអក្សរអំពីការសំរេចរបស់ខ្លួន ក្នុងរយៈពេលប្រាំមួយខែ (៦ខែ) ចាប់ពីពេលទទួលពាក្យស្នើសុំអាជ្ញាប័ណ្ណ រួមទាំងឯកសារដែលពាក់ព័ន្ធទាំងអស់ផង ។ នៅពេលណាមានការចាំបាច់ ធនាគារជាតិនៃកម្ពុជានឹងដាក់ចេញនូវលក្ខខ័ណ្ឌនិងរយៈពេលនៃការអនុវត្តន៍លិខិតអនុញ្ញាត ។ ប្រសិនបើអនុវត្តពុំបានតាមពេលវេលាកំណត់ខាងលើ លិខិតអនុញ្ញាតនេះត្រូវចាត់ទុកជាមោឃៈ លើកលែងតែមានការស្នើសុំពន្យារពេល និងមានការយល់ព្រមពីធនាគារជាតិនៃកម្ពុជា ។

ប្រការ ៩ :

អាជ្ញាប័ណ្ណមានសុពលភាពសំរាប់រយៈពេលបីឆ្នាំ (៣ឆ្នាំ) គិតចាប់ពីពេលបានចេញឲ្យ ។ អាជ្ញាប័ណ្ណនេះអាចស្នើសុំបន្តជាថ្មីបាន ល្គឹកណាតែរាល់ការប្រព្រឹត្តិល្មើសច្បាប់និងបទបញ្ញាត្រូវបានដោះស្រាយ ។ ពាក្យស្នើសុំបន្តអាជ្ញាប័ណ្ណជាថ្មីត្រូវដាក់ជូនធនាគារជាតិនៃកម្ពុជា យ៉ាងយឺតបំផុតបីខែ (៣ខែ) មុនពេលផុតសុពលភាព នៃអាជ្ញាប័ណ្ណដែលកំពុងប្រើប្រាស់ ។

ក្នុងករណីមិនបានដាក់ពាក្យស្នើសុំបន្ត តាមការកំណត់ខាងលើនេះទេ ធនាគារសាមីត្រូវទទួលរងការផាកពិន័យជាប្រាក់មួយរយពាន់រៀល (១០០.០០០ រៀល) ក្នុងមួយថ្ងៃ រហូតដល់ថ្ងៃបានដាក់ពាក្យស្នើសុំនេះ ។

**ប្រការ ១០ :**

អ្នកស្នើសុំ ត្រូវបង់សោហ៊ុយសិក្សាសំណុំលិខិតចំនួនប្រាំរយពាន់រៀល (៥០០.០០០ រៀល) នៅពេលដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណ ។

**ប្រការ ១១ :**

ធនាគារឯកទេស ត្រូវបង់សោហ៊ុយអាជ្ញាប័ណ្ណប្រចាំឆ្នាំចំនួនដប់លានរៀល (១០.០០០.០០០ រៀល) ចំពោះទីស្នាក់ការកណ្តាល និងប្រាំបីលានរៀល (៨.០០០.០០០រៀល) ចំពោះសាខានីមួយៗរបស់ធនាគារឯកទេសនៅមុន ថ្ងៃទី ១៥ ខែ មករា រៀងរាល់ឆ្នាំ ។ ចំពោះធនាគារដែលបានបង្កើតឡើងក្នុងឆ្នាំ សោហ៊ុយអាជ្ញាប័ណ្ណត្រូវគណនាតាម សមាមាត្រនៃរយៈពេលដែលនៅសល់រហូតដល់ដំណាច់ឆ្នាំ ។ ក្នុងករណីមានការយឺតយ៉ាវក្នុងការបង់សោហ៊ុយអាជ្ញាប័ណ្ណធនាគារដែលពាក់ព័ន្ធ ត្រូវទទួលរងនូវការផាកពិន័យដោយការប្រាក់លើទឹកប្រាក់ដែលនៅមិនទាន់បានបង់តាមអត្រាការប្រាក់ប្រុង ហិរញ្ញប្បទានជាធរមានក្នុងរយៈពេលរហូតដល់សាមសិបថ្ងៃ (៣០ថ្ងៃ) ។ បើនៅតែពុំអាចបង់សោហ៊ុយអាជ្ញាប័ណ្ណបាន ធនាគារសាមីត្រូវរងទណ្ឌកម្មធ្ងន់ជាងនេះទៀត រហូតដល់ត្រូវដក ហូតអាជ្ញាប័ណ្ណ ។

## ជំពូក ទី ៤
## បទបញ្ញត្តប្រុងប្រយ័ត្ន

**ប្រការ ១២ :**

អ្នកដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណដែលពុំធ្លាប់ធ្វើប្រតិបត្តិការ ត្រូវបង់បង្គ្រប់ឲ្យពេញមួយរយភាគរយ (១០០%) នៃដើមទុនចុះបញ្ជីក្នុងលក្ខន្តិកៈក្នុងគណនីដែលបានបើកនៅធនាគារជាតិនៃកម្ពុជា នៅមុន ពេលចាប់ ផ្តើមធ្វើប្រតិបត្តិការ ។

**ប្រការ ១៣ :**

ធនាគារឯកទេសដែលបានទទួលអាជ្ញាប័ណ្ណហើយ ត្រូវរក្សាប្រាក់តំកល់ធានាលើដើមទុនស្មើនឹងប្រាំភាគរយ (៥%) ដោយគ្មានការប្រាក់នៃដើមទុនដែលបានចុះបញ្ជីនៅក្នុងគណនីដែលបានបើកនៅធនាគារជាតិ នៃកម្ពុជា ។

ធនាគារជាតិនៃកម្ពុជា នឹងទូទាត់សងប្រាក់តំកល់ធានាលើដើមទុននេះទៅឲ្យធនាគារឯកទេសវិញ តែនៅពេលធនាគារនោះត្រូវបានជំរះបញ្ជីដោយស្ម័គ្រចិត្តនិងគ្មានប្រាក់បញ្ញើនៅខាងទ្រព្យអកម្ម ។

**ប្រការ ១៤ :**

ធនាគារឯកទេសដែលបានទទួលអាជ្ញាប័ណ្ណ ហើយត្រូវតំកល់ទុកបំរុងកាតព្វកិច្ចប្រាំភាគរយ (៥%) នៃប្រាក់បញ្ញើ ដែលបានទទួលពីអតិថិជន នៅក្នុងគណនីដែលបានបើកនៅ

ធនាគារជាតិនៃកម្ពុជា ។ ទុនបំរុងកាតព្វកិច្ចនេះ ត្រូវបានរក្សាទុកតាមលក្ខខ័ណ្ឌដែលមានចែងក្នុងបទបញ្ញាដោយឡែក ស្តីពីទុនបំរុងកាតព្វកិច្ច ។

ប្រការ ១៥ :

ធនាគារឯកទេសដែលបានទទួលអាជ្ញាប័ណ្ណរួចហើយ ត្រូវអនុវត្តឲ្យបានគោរពគ្រប់តាមបញ្ញត្តិទាំងអស់ដែលធនាគារត្រូវអនុវត្ត ពិសេសចំពោះការនៃការធ្វើរបាយការណ៍ ។

## ជំពូក ទី ៥

## បទប្បញ្ញត្តិផ្សេងៗ

ប្រការ ១៦ :

សេចក្តីជូនដំណឹងទាក់ទងដល់ការទទួលបានឬការបាត់បង់ទៅវិញនូវភាគហ៊ុន ក្នុងក្របខ័ណ្ឌនៃមាត្រា ២៣ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវមានបញ្ចូលការពិពណ៌នាពីមូលហេតុផ្សេងៗ សំរាប់សកម្មភាពប្រតិបត្តិការនិងគោលដៅដែលត្រូវអនុវត្តតាម ។

ឯកសារជូនដំណឹងក៏ត្រូវមានពត៌មានដូចមានបញ្ជាក់ក្នុងប្រការ ៦ ខាងលើស្តីពីភាគទុនិកៈដែលពាក់ព័ន្ធ ។

ធនាគារពាក់ព័ន្ធត្រូវបង់សោហ៊ុយផ្ទេរហ៊ុនចំនួនមួយភាគរយ (១%) លើចំនួនប្រាក់ហ៊ុនដែលត្រូវបានផ្លាស់ប្តូរ ។

ប្រការ ១៧ :

ការអនុញ្ញាតចំពោះពាក្យស្នើសុំទាក់ទងដល់ការទទួលបាន ឬការបាត់បង់ទៅវិញនៃភាគហ៊ុនក្នុងក្របខ័ណ្ឌនៃមាត្រា ២៤ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវមានបញ្ចូលការពិពណ៌នាពីមូលហេតុ ផ្សេងៗសំរាប់សកម្មភាពប្រតិបត្តិការនិងគោលដៅដែលត្រូវអនុវត្តតាម ។

ឯកសារស្នើសុំក៏ត្រូវមានពត៌មានដូចមានបញ្ជាក់ក្នុងប្រការ ៦ ខាងលើ ស្តីពីភាគទុនិកៈដែលពាក់ព័ន្ធ ។ ភាគទុនិកៈដែលមានបំណងកាន់កាប់ដោយផ្ទាល់ឬដោយប្រយោលយ៉ាងតិចបំផុតម្ភៃភាគរយ (២០%) នៃដើមទុន ឬ នៃសិទ្ធិបោះឆ្នោត ត្រូវធ្វើប្រតិវេទន៍ គ្រប់តាមគំរូដែលមានក្នុងឧបសម្ព័ន្ធ ទី ១ ។ ជាងនេះទៀត ធនាគារឯកទេសពាក់ព័ន្ធត្រូវបង់សោហ៊ុយចំនួនមួយភាគរយ (១%) លើចំនួនប្រាក់ដែលត្រូវបានផ្លាស់ប្តូរ ។

ប្រការ ១៨ :

ក្នុងករណីតែងតាំងអ្នកចាត់ការថ្មី (គឺបុគ្គលពីររូប ដែលទទួលខុសត្រូវក្នុងការដឹកនាំប្រតិបត្តិការធនាគារឲ្យមានប្រសិទ្ធភាព) ត្រូវផ្តល់ពត៌មានដូចខាងក្រោមនេះទៅធនាគារជាតិនៃកម្ពុជា ៖

- ឯកសារជាភស្តុតាងបញ្ជាក់ពីការតែងតាំង (មានជាអាទិ៍កំណត់ហេតុប្រជុំក្រុមប្រឹក្សាភិបាល)

- ជីវប្រវត្តិនិងការបំពេញសំណួរក្នុងឧបសម្ព័ន្ធទី ២

ឯកសារទាំងអស់នេះ ត្រូវតែផ្តល់ឲ្យយ៉ាងហោចណាស់មួយខែមុនការចូលកាន់តំណែងរបស់បុគ្គលដែលត្រូវបានតែងតាំង ។

ប្រការ ១៩ :

ការផ្លាស់ប្តូរផ្សេងទៀតនៃស្ថានភាពគតិយុត្ត ឬស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ ត្រូវតែដាក់ជូនធនាគារជាតិនៃកម្ពុជាដើម្បីសុំការយល់ព្រម ។ ឯកសារស្នើសុំត្រូវមានភ្ជាប់មកជាមួយនូវការរៀបរាប់ពីមូលហេតុនៃ ផែនការប្រតិបត្តិការ ហើយផ្អែកតាមករណីនីមួយៗ ត្រូវមានភ្ជាប់នូវពត៌មានដូចតទៅ ៖

- ការពង្រីក ឬការកំណត់ឡើងវិញនូវសកម្មភាព ៖ ត្រូវផ្តល់ពត៌មានដែលមានកំណត់ក្នុងកថាខ័ណ្ឌ ជ ប្រការ ៥ នៃប្រកាសនេះ
- ការបន្ថយដើមទុន ៖ ការពិពណ៌នាពីខ្លឹមសារនិងល័ក្ខខ័ណ្ឌដូចជាការសំរបសំរួលខាងគតិយុត្ត និងខាងគណនេយ្យព្រមទាំងការកំណត់ច្បាស់នូវចំនួនថ្មីនៃមូលនិធិផ្ទាល់ដែលអាចមានឥទ្ធិពលទៅលើអាជីវកម្មទៅអនាគតនិងទៅលើអនុបាតប្រុងប្រយ័ត្ន
- ការផ្លាស់ប្តូររូបភាពគតិយុត្ត ៖ សេចក្តីព្រាងវិសោធនកម្មលក្ខន្តិកៈនិងពត៌មានទាក់ទងដល់អង្គភាពគ្រប់គ្រង
- ការផ្លាស់ប្តូរនាមករណ៍អាជីវកម្ម ៖ សេចក្តីព្រាងវិសោធនកម្មលក្ខន្តិកៈ

រាល់ការផ្លាស់ប្តូរទាំងអស់ត្រូវដាក់ជូនធនាគារជាតិនៃកម្ពុជាយ៉ាងយឺតបំផុតបីខែ (៣ខែ) មុនពេលអនុវត្តដើម្បីសុំការយល់ព្រម

ធនាគារត្រូវបង់សោហ៊ុយចំនួនមួយលានរៀល (១.០០០.០០០ រៀល) ក្នុងមួយទំព័រនៃលក្ខន្តិកៈដែលរងវិសោធនកម្ម ។

ធនាគារត្រូវបង់សោហ៊ុយបន្ថយដើមទុនចំនួនមួយភាគរយ (១%) លើចំនួនដែលបន្ថយ។

ប្រការ ២០ :

រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ២១ :

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាពគ្រប់គ្រឹះស្ថានធនាគារឯកទេសនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវ ប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ២២ :**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០០០

ទេសាភិបាល

ហត្ថលេខា និង ត្រា

**ជា ចាន់តូ**

★★★

ឧបសម្ព័ន្ធ ១

**គំរូលិខិត**
**របស់ភាគទុនិកៈដែលកាន់កាប់ដោយផ្ទាល់ឬដោយប្រយោលនូវ**
**ចំនួន ២០ % ឬច្រើនជាងនេះនៃដើមទុនឬនៃសិទ្ធិបោះឆ្នោតរបស់ធនាគារ**
**ដែលត្រូវផ្ញើជូនឯកឧត្តមអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា**

---

ឯកឧត្តមទេសាភិបាលជាទីគោរព

ក្នុងនាមខ្លួនខ្ញុំជា (ប្រាប់ពីវោនៈ) ខ្ញុំសូមភ្ជាប់មកជាមួយនូវពត៌មានទាំងឡាយតាមសំណើរបស់ធនាគារជាតិនៃកម្ពុជាស្តី (តាមប្រកាសលេខ ............) ទាក់ទងទៅនឹងការកាន់កាប់ដើមទុនផ្ទាល់ដែល (ឈ្មោះភាគទុនិកៈ) មានបំណងចូលរួមនៅក្នុង (ឈ្មោះធនាគារ) ។

ខ្ញុំសូមបញ្ជាក់នៅក្នុងលិខិតនេះថា ពត៌មានទាំងនេះពិតជាត្រឹមត្រូវនិងគ្រប់គ្រាន់ ហើយថាតាមការយល់ដឹងដ៏ប្រសើរបំផុតរបស់ខ្ញុំ ពុំមានឯកសារបញ្ជាក់ការពិតណាផ្សេងពីនេះទៀតដែលត្រូវផ្ញើជូនធនាគារជាតិនៃកម្ពុជាទៀតទេ ។

ខ្ញុំសូមសន្យាថានឹងផ្តល់ពត៌មានយ៉ាងឆាប់ជូនធនាគារជាតិ នៃកម្ពុជានូវរាល់ការប្រែប្រួលណាដែលខុសប្លែកយ៉ាងខ្លាំងពីពត៌មានដែលបានផ្តល់ជូនហើយ ។

ខ្ញុំបានកត់សំគាល់ទៅលើបទប្បញ្ញត្តិមាត្រា ២៧ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលបានចែងថានៅពេលណាស្ថានភាពតំរូវហើយនោះ ធនាគារជាតិនៃកម្ពុជាអាចបង្គាប់ឲ្យភាគទុនិកៈមានឥទ្ធិពលរបស់គ្រឹះស្ថានផ្តល់នូវការគាំទ្រដល់គ្រឹះស្ថាននោះ ។

សូមឯកឧត្តមទេសាភិបាលមេត្តាទទួលនូវគារវកិច្ចដ៏ស្មោះស្ម័គ្រអំពីយើងខ្ញុំ ។

ហត្ថលេខា

★★★

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ មករា ឆ្នាំ

## ប្រកាសលេខ ធ ៧០០-០៦ ប្រក
## ស្តីពី
## ការផ្តល់អាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

***

## ទេសាភិបាល ធនាគារជាតិនៃកម្ពុជា

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣៩៨/៨៥ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំង លោកឧត្តម ជា ចាន់តូ ជាអគ្គទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា
- យោងតាមសំណើរបស់នាយកដ្ឋានត្រួតពិនិត្យ

## សំរេច

## ជំពូក ទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១ :**

ធនាគារជាតិនៃកម្ពុជាផ្តល់អាជ្ញាប័ណ្ណសំរាប់ធ្វើប្រតិបត្តិការមីក្រូហិរញ្ញវត្ថុ ចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ តទៅនេះហៅថាគ្រឹះស្ថាន ដែលបំពេញបានតាមបញ្ញត្តិទាំងឡាយនៃប្រកាសនេះ ។ អង្គការក្រៅរដ្ឋាភិបាល សមាគម អង្គភាពឬគ្រឹះស្ថានទាំងឡាយណាដែលមិនអាចបំពេញបានតាមលក្ខខណ្ឌសំរាប់ការផ្តល់អាជ្ញាប័ណ្ណ ហើយនៅតែចូលរួមផ្តល់សេវាឥណទានជាឯកត្តជន ឬជាក្រុមសាមគ្គី ត្រូវចុះឈ្មោះក្នុងបញ្ជីនៅធនាគារជាតិនៃកម្ពុជា ។

**ប្រការ ២ :**

គ្រឹះស្ថានដែលបានទទួលអាជ្ញាប័ណ្ណ ត្រូវធ្វើតែប្រតិបត្តិការធនាគារដូចមានកំណត់ក្នុងមាត្រា ២ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិង ហិរញ្ញវត្ថុ ។ សេវាឥណទាននិងសញ្ញយត្រូវបានអនុញ្ញាតអោយធ្វើប្រសិនបើមិនមានការហាមឃាត់ដោយប្រកាសនេះ ឬដោយខ្លឹមសារនៃលិខិតអនុញ្ញាតអោយបង្កើតគ្រឹះស្ថាន ។

រាល់គ្រឹះស្ថាន អង្គការក្រៅរដ្ឋាភិបាល សមាគម ទោះបានទទួលអាជ្ញាប័ណ្ណ ឬបានចុះបញ្ជី ហើយក្តីមិនត្រូវបានអនុញ្ញាតអោយ ៖

ក- ផ្តល់ឥណទានភតិសន្យា ធ្វើប្រតិបត្តិការលើឧបករណ៍ហិរញ្ញវត្ថុ និស្សន្ទ (derivatives) និងសេដ្ឋពាណិជ្ជដល់ដែលមានកាលកំណត់ លើលោហធាតុមានតំលៃ ទំនិញ ត្បូងថ្មមានតំលៃ វត្ថុធាតុដើម

ខ- ផ្តល់សេវាទូទាត់តាមរយៈគណនីមូលប្បទានប័ត្រ (checking accounts) ឬធ្វើប្រតិបត្តិការ swap ឬមានកាលកំណត់ជារូបិយប័ណ្ណបរទេស ។

ប្រការ ៣ :

អ្នកដាក់ពាក្យសុំអាជ្ញាប័ណ្ណសំរាប់គ្រឹះស្ថាន ត្រូវចុះបញ្ជីជាក្រុមហ៊ុនភាគហ៊ុន ឬជាសហករណ៍ ។

ប្រការ ៤ :

គ្រឹះស្ថានដែលបានទទួលអាជ្ញាប័ណ្ណ ត្រូវមានដើមទុនអប្បបរមាចុះក្នុងលក្ខន្តិកៈចំនួនពីររយហាសិបលានរៀល (២៥០.០០០.០០០ រៀល) ។

## ជំពូក ទី ២

## នីតិវិធីនៃការដាក់ពាក្យសុំអាជ្ញាប័ណ្ណ

ប្រការ ៥ : ពាក្យសុំអាជ្ញាប័ណ្ណត្រូវស្នើដោយបុគ្គល ដែលបានទទួលការអនុញ្ញាតត្រឹមត្រូវ (អ្នកចាត់ការឬជនដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ) គោរពតាមបទប្បញ្ញត្តិដែលមានរៀបរាប់ខាងក្រោមនេះ ៖

ក- នាម ឬ អាហករណ៍អាជីវកម្មរបស់គ្រឹះស្ថាន

ខ- អាសយដ្ឋាននៃទីស្នាក់ការកណ្តាលដែលបានចុះបញ្ជី

គ- រូបភាពចតិយត្តនិងលក្ខន្តិកៈ ឬឯកសារបង្កើតផ្សេងៗទៀត

ឃ-ប្រភេទមូលប័ត្រតំណាងឲ្យដើមទុន និងចំពោងទាក់ទងរវាងការកាន់កាប់មូលប័ត្រទាំងនោះនិងការអនុវត្តន៍សិទ្ធិបោះឆ្នោត

ង- ចំនួនដើមទុនដែលបានអនុញ្ញាត ឬចំនួនដើមទុនដែលបានបង់

ច- ការបែងចែកភាគហ៊ុននិងសិទ្ធិបោះឆ្នោត និងកិច្ចព្រមព្រៀងដែលអាចមានរវាងភាគទុនិកៈ ដែលដើរតួនាទីក្នុងការដឹកនាំគោលនយោបាយរបស់គ្រឹះស្ថាន

ឆ- ភាគទុនិកៈដែលកាន់កាប់ប្រាំភាគរយ (៥%) នៃសិទ្ធិបោះឆ្នោតឬលើសពីនេះត្រូវផ្តល់ពត៌មានដូចមានរៀបរាប់ក្នុងប្រការ ៦ នៃប្រកាសនេះ

ជ- អត្តសញ្ញាណរបស់បុគ្គលយ៉ាងតិចបំផុតពីររូប (២រូប) ដែលទទួលខុសត្រូវក្នុងការដឹកនាំ ដោយមានប្រសិទ្ធភាព នូវសកម្មភាពអាជីវកម្មរបស់គ្រឹះស្ថាន

ឈ-អត្តសញ្ញាណរបស់សមាជិកក្រុមប្រឹក្សាភិបាល បន្ថែមពីលើពត៌មានខាងលើ ត្រូវមាន ជីវប្រវត្តិ និងរបាយការណ៍បញ្ជាក់ថា គ្មាននរណាម្នាក់ពាក់ព័ន្ធទៅនឹងការហាមឃាត់ ដូចមានចែងក្នុង មាត្រា ១៨ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

ញ-ប្រសិនបើនីតិបុគ្គលដែលបានដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណ គឺជាអង្គភាពដែលបាន បង្កើតរួចហើយ ត្រូវផ្តល់មកជាមួយនូវការអធិប្បាយអំពីមុខរបររបស់ខ្លួនព្រមទាំង តារាងតុល្យការ ដែលមានការបញ្ជាក់ពីស្នងការគណនី សំរាប់ប្រតិបត្តិការក្នុងរយៈ ពេលបីឆ្នាំ ( ៣ឆ្នាំ )ចុងក្រោយ

ដ- ការពិពណ៌នាពីផែនការសកម្មភាពអាជីវកម្មរយៈពេលបីឆ្នាំ (៣ឆ្នាំ) ទៅមុខ ៖

- ទំរង់នៃការអោយខ្ចីគ្រប់ប្រភេទដែលអាចមាននៅក្នុងឬក្រៅតារាងតុល្យការ និងសេវា ផ្សេងៗទៀតដែលត្រូវផ្តល់អោយអតិថិជនឬសមាជិក (ចំពោះឥណទាន ប្រភេទ ទំរង់គោលបំណង ខ្ចីមសារ និងលក្ខខណ្ឌចំបងៗ ផលកំរៃដែលទទួលបានប្រចាំឆ្នាំ និងទឹកប្រាក់មិនទាន់សង)
- ប្រភេទអតិថិជនដែលគ្រឹះស្ថានមានបំណងប្រាស្រ័យទាក់ទង
- ប្រភពធនធានហិរញ្ញវត្ថុដែលបានគ្រោងទុក ៖ មូលនិធិផ្ទាល់ ប្រាក់ឧបត្ថម្ភ បំណុល បន្ទាប់បន្សំ ប្រាក់បញ្ញើ ប្រាក់កម្ចីជាដើម ហើយបើចាំបាច់ត្រូវបញ្ជាក់ច្បាស់ពីដើម កំណើត និងកម្មសិទ្ធិនៃធនធានទាំងនេះក្នុងករណីមិនប្រាកដ (បំណុលបន្ទាប់ បន្សំជាដើម)
- ចំនួនប្រមាណប្រហែលនៃនិយោជិតក្នុងរយៈពេលបីឆ្នាំ (៣ឆ្នាំ) ខាងមុខ និងបញ្ជីបើក បៀវត្សរ៍ដោយរាយលំអិតតាមប្រភេទបុគ្គលិក
- ទីតាំងនៃសាខាដែលមានហើយឬក៏សាខាដែលបំរុងបង្កើត
- ការតាក់តាំងនិងធនធាន ដែលបានគ្រោងទុក ពិសេសចំពោះទំរង់ការគណនេយ្យ និងឧបករណ៍កុំព្យូទ័រ
- តារាងតុល្យការនិងការព្យាករណ៍គណនីខាត-ចំណេញ សំរាប់ការិបរិច្ឆេទគណនេយ្យ បីឆ្នាំ (៣ឆ្នាំ) ខាងមុខ ។ ត្រូវព្យាករណ៍ករិតអនុបាតប្រុងប្រយ័ត្នចំបងៗ (ដូចបាន កំណត់ដោយធនាគារជាតិនៃកម្ពុជា) នៅខាងចុង ការិយបរិច្ឆេទបីឆ្នាំ (៣ឆ្នាំ) ខាងមុខ

ឋ- ទំរង់នៃការត្រួតពិនិត្យ ៖

- ការចាត់តាំងផែនការត្រួតពិនិត្យបញ្ជីផ្ទៃក្នុងដែលមានចែងក្នុងមាត្រា ៤៣ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- អត្តសញ្ញាណរបស់ស្នងការគណនីឯករាជ្យដែលត្រូវបានជ្រើសរើសពីបញ្ជីប្រតិស្រុត
- ប្រភេទនៃមុខងារដែលត្រូវប្រគល់ឲ្យស្នងការគណនីឯករាជ្យនោះ ។

ប្រការ ៦ :

ភាគទុនិកៈដែលកាន់កាប់ប្រាំភាគរយ (៥%) ឬលើសពីនេះនៃដើមទុនឬនៃសិទ្ធិបោះឆ្នោត របស់អ្នកដាក់ពាក្យសុំ ត្រូវផ្តល់ព័ត៌មានដូចតទៅ ៖

ក- អត្តសញ្ញាណរបស់ភាគទុនិកៈ ៖

ក្នុងករណីជានីតិបុគ្គល ត្រូវផ្តល់នាមករណ៍អាជីវកម្ម រូបភាពគតិយុត្ត អាសយដ្ឋាន ទីស្នាក់ការកណ្តាលនិងលក្ខន្តិកៈ ។

ក្នុងករណីជាឯកត្តជន ត្រូវរៀបរាប់ នាម គោត្តនាម ថ្ងៃខែឆ្នាំនិងទីកន្លែងកំណើត សញ្ជាតិ និងអាសយដ្ឋាន ។ ត្រូវបញ្ជាក់ថា តើបុគ្គលនេះត្រូវបានតែងតាំងជាអ្នកចាត់ការមួយរូបរបស់ធនាគារឬទេ ។ ត្រូវប្រាប់ថា តើភាគទុនិកៈជាសមាជិកនៃក្រុមប្រឹក្សាភិបាលរបស់គ្រឹះស្ថានឬទេ ។ បើមែន ត្រូវធានាថាសមាជិកនោះមិនមានពាក់ព័ន្ធជាមួយការហាមឃាត់ដូចមានចែងក្នុងមាត្រា ១៨ នៃច្បាប់ស្តីពីគ្រឹះ-ស្ថានធនាគារនិងហិរញ្ញវត្ថុទេ

ខ- បញ្ជាក់ពីចំនួននិងភាគរយនៃភាគហ៊ុនដែលបានស្នើនិងចំនួន និងភាគរយនៃសិទ្ធិបោះឆ្នោត ។

រៀបរាប់លំអិតពីការសំរបសំរួលខាងគតិយុត្ត និងខាងហិរញ្ញវត្ថុចំពោះការទទួលយកកម្មសិទ្ធិប័ត្រ ។

បង្ហាញថា តើសកម្មភាពប្រតិបត្តិការស្ថិតនៅក្រោមចំណុះនីតិវិធីដោយឡែកដែលអនុវត្ត ចំពោះការវិនិយោគបរទេសនៅកម្ពុជាឬទេ ហើយបើទំរង់បែបបទទាំងនេះត្រូវបានបំពេញហើយឬនៅ

គ- រៀបរាប់ពីសកម្មភាពរបស់ភាគទុនិកៈ ។ ប្រសិនបើភាគទុនិកៈជាសមាជិកនៃក្រុមមួយ ត្រូវពិពណ៌នាពីអង្គភាពផ្សេងៗនៃក្រុមនោះរួមជាមួយអង្គការលេខផង ។ ត្រូវបញ្ជាក់ផងថា តើភាគទុនិកៈមានប្រព្រឹត្តសម្បត្តិច្រើននៅក្នុងស្ថាប័នឥណទានផ្សេងៗទៀតឬទេ បញ្ជាក់ថា តើក្រុមដែលជាកម្មសិទ្ធិផ្ទាល់របស់ភាគទុនិកៈមានហ៊ុនច្រើននៅក្នុងគ្រឹះស្ថានឥណទានឬទេ ។ បើមានត្រូវរៀបរាប់អោយអស់

ឃ- ប្រាប់ថា តើភាគទុនិកៈនិងក្រុមហ៊ុនដែលអាចបញ្ចូលជាមួយគ្នា មានធ្វើសកម្មភាពហិរញ្ញវត្ថុឬទេ ។ បើមាន ត្រូវបញ្ជាក់ថា ក្រុមហ៊ុនទាំងនោះស្ថិតក្រោមចំណុះបទបញ្ញត្តិណាឬអាជ្ញាធរណា

ង- បញ្ជាក់ពីបែបបទនៃការត្រួតពិនិត្យ ផ្ទៃក្នុងនិងពីខាងក្រៅរបស់ភាគទុនិកៈ

ច- បញ្ជាក់ថា តើក្នុងរយៈពេលដប់ឆ្នាំ (១០ឆ្នាំ) កន្លងមក ភាគទុនិកៈបានទទួលរងនូវការ ផ្តន្ទាទោសឬទទួលរងនូវការពិន័យជាសំភារៈតាមវិន័យការវិជ្ជាជីវៈ រដ្ឋបាល ឬតុលាការឬទេ

ឆ- ប្រាប់ពីគោលដៅរបស់ភាគទុនិកៈ ក្នុងការដាក់បញ្ញើមូលធនផ្ទាល់នៅក្នុងគ្រឹះស្ថាន ដែលបានដាក់ពាក្យសុំអាជ្ញាប័ណ្ណនិងផ្តល់ព័ត៌មានដែលពាក់ព័ន្ធទាំងអស់

ជ- បញ្ជាក់ថា តើមានទំនាក់ទំនងអាជីវកម្មសំខាន់ៗរវាងភាគទុនិកៈនិងអ្នកដាក់ពាក្យសុំឬទេ ហើយ តើទំនាក់ទំនងទាំងនេះនឹងត្រូវបានពង្រីកទៅអនាគតយ៉ាងណា

ប្រការ ៧ :

ភាគទុនិកៈដែលកាន់កាប់ដោយផ្ទាល់ឬប្រយោលយ៉ាងតិចបំផុតម្ភៃភាគរយ (២០ %) នៃដើមទុនឬនៃសិទ្ធិបោះឆ្នោត ត្រូវបានចាត់ទុកថាជាភាគទុនិកៈមានឥទ្ធិពលស្របតាមមាត្រា ២៦ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។ ភាគទុនិកៈមានឥទ្ធិពលត្រូវបានធនាគារជាតិនៃកម្ពុជាតំរូវអោយបង្កើនមូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថាន តាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ២៧ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។ សំរាប់គោលបំណងនោះ ត្រូវធ្វើលិខិតដូចមានគំរូនៅក្នុងឧបសម្ព័ន្ធ ទី១ ទៅទេសាភិបាលធនាគារជាតិនៃកម្ពុជា ។

បទបញ្ញានេះអាចត្រូវដកចេញវិញបាន តែនៅពេលដែលបានបង្កើតអោយមានការធានារ៉ាប់រងលើប្រាក់បញ្ញើនៅកម្ពុជា ។

ក្រៅពីនេះយោងតាមមាត្រា ៤០ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុធនាគារជាតិនៃកម្ពុជាអាចលើកលែងជាលាយលក្ខណ៍អក្សរ អនុញ្ញាតឲ្យរួចផុតពីការអនុវត្តន៍មាត្រា ៧ នៅពេលអនុម័តលើអាជ្ញាប័ណ្ណ ។

## ជំពូក ទី ៣
## ការអនុម័តផ្តល់អាជ្ញាប័ណ្ណ និង ការយកកំរៃ

ប្រការ ៨ :

ធនាគារជាតិនៃកម្ពុជាត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការសំរេចរបស់ខ្លួនក្នុងរយៈពេលប្រាំមួយខែ (៦ ខែ) ចាប់ពីពេលទទួលពាក្យស្នើសុំអាជ្ញាប័ណ្ណ រួមទាំងឯកសារដែលពាក់ព័ន្ធទាំងអស់ផង ។ នៅពេលណាមានការចាំបាច់ ធនាគារជាតិនៃកម្ពុជានឹងដាក់ចេញនូវលក្ខខណ្ឌនិងរយៈពេលនៃការអនុវត្តន៍លិខិតអនុញ្ញាត ។ ប្រសិនបើអនុវត្តពុំបានតាមពេលវេលា កំណត់ខាងលើ លិខិតអនុញ្ញាតត្រូវចាត់ទុកជាមោឃៈ លើកលែងតែមានការស្នើសុំពន្យារពេល និងមានការយល់ព្រមពីធនាគារជាតិនៃកម្ពុជា ។

**ប្រការ ៩ :**

អាជ្ញាប័ណ្ណមានសុពលភាពសំរាប់រយៈពេលបីឆ្នាំ (៣ឆ្នាំ) គិតចាប់ពីពេលបានចេញឲ្យ ។ អាជ្ញាប័ណ្ណនេះអាចស្នើសុំបន្តជាថ្មីបាន លើកណាតែរាល់ការប្រព្រឹត្តិល្មើសច្បាប់និងបទបញ្ញាត្រូវបានដោះស្រាយ ។ ពាក្យស្នើសុំបន្តអាជ្ញាប័ណ្ណជាថ្មីត្រូវដាក់ជូនធនាគារជាតិនៃកម្ពុជា យ៉ាងយឺតបំផុតបីខែ (៣ខែ) មុនពេលផុតសុពលភាព នៃអាជ្ញាប័ណ្ណដែលកំពុងប្រើប្រាស់ ។

ក្នុងករណីមិនបានដាក់ពាក្យស្នើសុំបន្ត តាមកាលកំណត់ខាងលើនេះទេ គ្រឹះស្ថានសាមីត្រូវទទួលរងការផាកពិន័យជាប្រាក់ដប់ពាន់រៀល (១០.០០០ រៀល) ក្នុងមួយថ្ងៃ រហូតដល់ថ្ងៃបានដាក់ពាក្យស្នើសុំនេះ ។

**ប្រការ ១០ :**

គ្រឹះស្ថាន ត្រូវបង់សោហ៊ុយសិក្សាសំណុំលិខិតចំនួនហាសិបពាន់ (៥០.០០០ រៀល) នៅពេលដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណ ។

**ប្រការ ១១ :**

គ្រឹះស្ថានត្រូវបង់សោហ៊ុយអាជ្ញាប័ណ្ណប្រចាំឆ្នាំចំនួនមួយលានរៀល (១.០០០.០០០ រៀល) នៅមុនថ្ងៃទី១៥ ខែមករា រៀងរាល់ឆ្នាំ ។ ចំពោះគ្រឹះស្ថានដែលបានបង្កើតឡើងក្នុងឆ្នាំ សោហ៊ុយអាជ្ញាប័ណ្ណ ត្រូវបានគណនាតាមសមាមាត្រនៃរយៈពេលដែលនៅសល់រហូតដល់ដំណាច់ឆ្នាំ ។ ក្នុងករណីមានការយឺតយ៉ាវក្នុងការបង់សោហ៊ុយអាជ្ញាប័ណ្ណ គ្រឹះស្ថានដែលពាក់ព័ន្ធត្រូវទទួលរងនូវការផាកពិន័យ ដោយបង់ការប្រាក់លើទឹកប្រាក់ដែលនៅមិនទាន់បានបង់តាមអត្រាការប្រាក់បុនហិរញ្ញប្បទានជាធរមានក្នុងរយៈពេល រហូតដល់សាមសិបថ្ងៃ (៣០ថ្ងៃ) ។ បើនៅតែពុំអាចបង់សោហ៊ុយអាជ្ញាប័ណ្ណបាន គ្រឹះស្ថានសាមីត្រូវរងទណ្ឌកម្មធ្ងន់ជាងនេះទៀតរហូតដល់ត្រូវដកហូតអាជ្ញាប័ណ្ណ ។

## ជំពូក ទី ៤
## បទបញ្ញាប្រុងប្រយ័ត្ន

**ប្រការ ១២ :**

ចំពោះគ្រឹះស្ថានបង្កើតថ្មី អ្នកដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណ ត្រូវបង់មួយរយភាគរយ (១០០%) នៃដើមទុនចុះបញ្ជីក្នុងលក្ខន្តិកៈក្នុងគណនីដែលបានបើកនៅធនាគារជាតិនៃកម្ពុជា នៅមុនពេលចាប់ផ្តើមធ្វើប្រតិបត្តិការ ។

**ប្រការ ១៣ :**

គ្រឹះស្ថាននីមួយៗដែលបានទទួលអាជ្ញាប័ណ្ណរួចហើយ ដោយរួមទាំងគ្រឹះស្ថានណាដែលបានបង់ដើមទុនរបស់ខ្លួននៅ ធនាគារជាតិនៃកម្ពុជា ដូចមានចែងក្នុងប្រការ ១២ ។ ត្រូវរក្សាប្រាក់តំកល់ធានាលើដើមទុនស្មើនឹងប្រាំភាគរយ (៥%) ដោយគ្មានការប្រាក់ នៃដើមទុនដែលបានចុះបញ្ជី

នៅក្នុងគណនី ដែលបានបើកនៅធនាគារជាតិនៃកម្ពុជា គ្រឹះស្ថានអាចដកយកអត្ថប្រយោជន៍ ដែលកើតចេញពីនោះបាន ។

ធនាគារជាតិនៃកម្ពុជា នឹងទូទាត់សងប្រាក់តម្កល់ធានាលើដើមទុនទៅឲ្យគ្រឹះស្ថានវិញ តែនៅពេលគ្រឹះស្ថាននោះត្រូវបានជំរះបញ្ជីដោយស្ម័គ្រចិត្តនិងគ្មានប្រាក់បញ្ញើនៅខាងក្រៅអកម្ម ។

ប្រការ ១៤ :

គ្រឹះស្ថានដែលបានទទួលអាជ្ញាប័ណ្ណរួចហើយ ត្រូវតែតម្កល់ទុកបំរុងកាតព្វកិច្ចប្រាំភាគរយ (៥%) នៃប្រាក់បញ្ញើ ដែលបានទទួលពីអតិថិជននៅក្នុងគណនីដែលបានបើកនៅធនាគារជាតិនៃកម្ពុជា ។ ទុនបំរុងកាតព្វកិច្ចនេះត្រូវបានរក្សាទុកជាមធ្យមក្នុងរយៈពេលដែលមានកំណត់ក្នុងរយៈពេលដោយប្រកាសស្ដីពីទុនបំរុងកាតព្វកិច្ច ។

ប្រការ ១៥ :

គ្រឹះស្ថានត្រូវរក្សាទុកអនុបាតគ្រប់គ្រាន់នៃដើមទុនយ៉ាងតិចបំផុតស្មើម្ភៃភាគរយ (២០%) រវាងដើមទុនដែលអាចទទួលបាន (eligible capital) និងហានិភ័យថ្លឹងថ្លែង (weighted risk) ។ ដើមទុនដែលអាចទទួលបានរួមមានដើមទុនស្នូល (ដើមទុនថ្នាក់ ១) និងឧបករណ៍ ដើមទុនបន្ថែម-ប្លែកជាប្រាក់បម្រុងដែលមិនសងវិញ (អំណោយពីសាធារណៈ) មូលនិធិធានាជា គណនីធានាដើម្បីដោះស្រាយហានិភ័យកើតឡើងលើឥណទានអតិថិជន និងជំពាក់បន្ទាប់បន្សំជាប់ជាប្រាក់ (ជាផ្នែកនៃដើមទុនថ្នាក់ ២) ។ ការថ្លឹងថ្លែងហានិភ័យនឹងត្រូវកំណត់តាមប្រកាសដោយឡែក ។

ប្រការ ១៦ :

គ្រឹះស្ថាន ត្រូវរក្សាអនុបាតសាច់ប្រាក់ងាយស្រួលយ៉ាងតិចត្រឹមស្មើមួយរយភាគរយ (១០០%) ។ អនុបាតសាច់ប្រាក់ងាយស្រួលនេះត្រូវបានគណនាដូចតទៅ :

ភាគយក : សាច់ប្រាក់ក្នុងដៃ + ប្រាក់បញ្ញើនៅក្នុងធនាគារជាតិនៃកម្ពុជា + ប្រាក់បញ្ញើនៅធនាគារផ្សេងៗ - ចំនួនទឹកប្រាក់ជំពាក់នៅធនាគារជាតិនិងធនាគារផ្សេងៗ (សាច់ប្រាក់ងាយស្រួលសុទ្ធ) + ចំណែកនៃទឹកប្រាក់ឲ្យខ្ចីដែលត្រូវសងនៅក្នុងប្រតិបត្តិការមួយខែ (លើកលែងតែឥណទានចំពោះអតិថិជនដោយមានកំណត់ការសងវិញ)

ភាគបែង : អត្រាភាគរយនៃប្រាក់បញ្ញើមានរយៈពេលកំណត់ដែលត្រូវសងក្នុងខែបន្ទាប់ + អត្រាភាគរយនៃគណនីចរន្ត និងអត្រាភាគរយនៃគណនីប្រាក់សន្សំ ។ អត្រាភាគរយទាំងនេះត្រូវបានកំណត់តាមប្រកាសដោយឡែក ។

ប្រការ ១៧ :

គ្រឹះស្ថានដែលបានទទួលអាជ្ញាប័ណ្ណហើយត្រូវអនុវត្តអោយសមស្របតាមបញ្ញត្តិ ទាក់ទងជាក្បួនចំណាត់ថ្នាក់ប្រភេទឥណទាននិងកំរិតសំវិធានធនសំរាប់ការបាត់បង់ ។

**ប្រការ ១៨ :**

ការិតសមេទានចំពោះអ្នកខ្ចីឯកត្តជនម្នាក់ឬអ្នកខ្ចីមួយក្រុម ដែលរួមបង្កើតជាអ្នកទទួលផលតែមួយដោយសារមានទំនាក់ទំនងជាមួយគ្នាទៅវិញទៅមក ត្រូវតែរក្សាមិនអោយលើសពីដប់ភាគរយ (១០%) នៃមូលនិធិផ្ទាល់របស់គ្រឹះស្ថានឡើយ ។

## ជំពូកទី ៥

## បទប្បញ្ញត្តិផ្សេងៗ

**ប្រការ ១៩ :**

រាល់បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ២០ :**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាពគ្រប់ គ្រឹះស្ថាននៅក្រោមឱវាទនិងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ២១ :**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសាភិបាល

ហត្ថលេខានិងត្រា

**ជា ចាន់តូ**

★★★

ឧបសម្ព័ន្ធ ១

**គំរូលិខិត**

**របស់ភាគទុនិកៈដែលកាន់កាប់ដោយផ្ទាល់ឬដោយប្រយោលនូវ**
**ចំនួន ២០ % ឬច្រើនជាងនេះនៃដើមទុនឬនៃសិទ្ធិបោះឆ្នោតរបស់ធនាគារ**
**ដែលត្រូវផ្ញើជូនឯកឧត្តមអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា**

---

ឯកឧត្តមទេសាភិបាលជាទីគោរព

ក្នុងនាមខ្លួនខ្ញុំជា (ប្រាប់ពីឋានៈ) ខ្ញុំសូមភ្ជាប់មកជាមួយនូវពត៌មានទាំងឡាយតាមតំរូវរបស់ធនាគារជាតិនៃកម្ពុជាសុំ (តាមប្រកាសលេខ ............) ទាក់ទងទៅនឹងការកាន់កាប់ដើមទុនផ្ទាល់ដែល (ឈ្មោះភាគទុនិកៈ) មានបំណងចូលរួមនៅក្នុង (ឈ្មោះធនាគារ) ។

ខ្ញុំសូមបញ្ជាក់នៅក្នុងលិខិតនេះថា ពត៌មានទាំងនេះពិតជាត្រឹមត្រូវនិងគ្រប់គ្រាន់ ហើយថាតាមការយល់ដឹងដ៏ប្រសើរបំផុតរបស់ខ្ញុំ ពុំមានឯកសារបញ្ជាក់ការពិតណាផ្សេងពីនេះទៀតដែលត្រូវផ្ញើជូនធនាគារជាតិនៃកម្ពុជាទៀតទេ ។

ខ្ញុំសូមសន្យាថានឹងផ្តល់ពត៌មានយ៉ាងឆាប់ជូនធនាគារជាតិ នៃកម្ពុជានូវរាល់ការប្រែប្រួលណាដែលខុសប្លែកយ៉ាងខ្លាំងពីពត៌មានដែលបានផ្តល់ជូនហើយ ។

ខ្ញុំបានកត់សំគាល់ទៅលើបទប្បញ្ញត្តិប្រការ ៧ នៃប្រកាសស្តីពីការផ្តល់អាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលបានចែងថានៅពេលណាស្ថានភាពតម្រូវហើយនោះ ធនាគារជាតិនៃកម្ពុជាអាចបង្គាប់ឲ្យភាគទុនិកៈមានឥទ្ធិពលរបស់គ្រឹះស្ថានផ្តល់នូវការគាំទ្រដល់គ្រឹះស្ថាននោះ ។

សូមឯកឧត្តមទេសាភិបាលមេត្តាទទួលនូវគារវកិច្ចដ៏ស្មោះស្ម័គ្រអំពីយើងខ្ញុំ ។

ហត្ថលេខា

★★★

## ឧបសម្ព័ន្ធទី ២

Photo 4x6

## ជីវប្រវត្តិ និង ការសាកសួរនូវពត៌មាន អំពី ឯកត្តជន ឬ ជនដែលបំរុងក្លាយទៅជា : គណៈនាយក ភាគទុនិក នាយកចាត់ការ របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

**CURRICULUM VITAE**

and

Questionnaire for individuals who are, or are proposing to become,

**Directors, Shareholders or Managers of Micro-finance Institutions**

1- គោត្តនាម
family name

------------------------------------------------------------

2- នាមខ្លួន
Given name (s).

------------------------------------------------------------

3- ឈ្មោះហៅក្រៅ

Other name (s) by which you are or have been known

---

4-1. សូមរៀបរាប់ពីភារកិច្ច និងការទទួលខុសត្រូវណាមួយដែលទាក់ទងនឹងឋានៈនាទីទាំងនេះ

Please describe the particular duties and responsibilities attaching to the position(s).

---

---

---

---

---

---

4-2 សូមរៀបរាប់បើសិនជាអ្នកជា អ្នកផ្តល់ទុនម្នាក់ទៅលើអ្នកដាក់ពាក្យសុំអាជ្ញាប័ណ្ណ ហើយបើសិនជាអ្នកមានបំណងចង់អនុវត្តដោយផ្ទាល់ ឬតាមរយៈអន្តរការីណាមួយ ឬផ្ទាល់ខ្លួនឬជាប្រតិបត្តិការវិជ្ជាជីវៈជាមួយអ្នកដាក់ពាក្យសុំនោះ ។

Indicate if you are a contributor of capital to the applicant and if you intend to carry out, directly or through an intermediary, personal or professional transactions with the applicant.

---

---

---

---

---

5- អាសយដ្ឋានផ្ទាល់ខ្លួន

Your private address.

---

---

6- អាសយដ្ឋានផ្ទាល់ខ្លួនដែលធ្លាប់បានរស់នៅកន្លងមក ចាប់ពីកំឡុង ៥ ឆ្នាំមុន :
Your previous private address(es) during the last 5 years.

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

7- កាលបរិច្ឆេទ (ថ្ងៃ/ ខែ/ ឆ្នាំ) និងទីកន្លែងកើត (គិតទាំងស្រុកនិងក្រុង)
Your date (day/month/year) and place of birth (including district, town or city).

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

8- សញ្ជាតិ ហើយតើសញ្ជាតិនោះត្រូវបានដោយរបៀបណា (កើតនៅទីនោះ, សញ្ជាតូបនីយកម្ម, ការរៀបអាពាហ៍ពិពាហ៍) ?
Your nationality and how it was acquired (birth, naturalization, marriage).

--------------------------------------------------------------------------------

--------------------------------------------------------------------------------

9- ឈ្មោះ និង អាសយដ្ឋាននៃធនាគាររបស់លោក-លោកស្រី ក្នុងរយះកាល៥ឆ្នាំកន្លងមក
Name(s) and address(es) of your bankers within the last 5 years.

--------------------------------------------------------------------------------

--------------------------------------------------------------------------------

--------------------------------------------------------------------------------

10- ចូរបញ្ជាក់ពីកំរិតចំណេះដឹង និង គុណវុឌ្ឍិវិជ្ជាជីវៈ ព្រមទាំងទីកន្លែង និងឆ្នាំដែលបានទទួល
Your higher education and/or professional qualifications and the place and year they were obtained.

--------------------------------------------------------------------------------

--------------------------------------------------------------------------------

11-1 ចូររៀបរាប់អំពីមុខរបរ និងការងារដែលបានធ្វើក្នុងពេលបច្ចុប្បន្ន និងរយៈពេល១០ឆ្នាំកន្លងមកដោយបញ្ជាក់ពីឈ្មោះអាសយដ្ឋានរបស់និយោជកក្នុងករណីនីមួយៗ, ចរិតនៃមុខជំនួញ, ស្ថានភាពដែលមាននិងកាលបរិច្ឆេទពាក់ព័ន្ធ ។

Your occupation and employment now and during the **last 10 years,** including the name and address of the employer in each case, the nature of the business, the positoin held and relevant dates.

11-2 សូមរៀបរាប់កាលពី១០ឆ្នាំមុន បើសិនជាអ្នកជាភាគទុនិកដែលមានឈ្មោះកាន់កាប់ផ្ទាល់ ឬដោយប្រយោលនូវ១០ភាគរយយ៉ាងតិចនៃដើមទុន ឬនៃសិទ្ធិបោះឆ្នោតនៃក្រុមហ៊ុនម្នាក់ក្រៅពីក្រុមហ៊ុនបច្ចុប្បន្ន បើសិនជាមានសូមរៀបរាប់ឈ្មោះនិងសកម្មភាពក្រុមហ៊ុននេះ និងចំនួនភាគហ៊ុនព្រមទាំងអត្ថប្រយោជន៍ផ្សេងៗ ទៀតរបស់អ្នកចំពោះក្រុមហ៊ុននេះ ។

Indicate if you are or if you have been in the last ten years a significant shareholder (namely holding directly or indirectly at least 10 % of the share capital or voting rights other than the applicant. If it is the case, state the name and activities of such companies and the amount of your shareholding or interest in them.)

11-3- សូមរៀបរាប់ចំពោះការយល់ដឹងរបស់អ្នកចំពោះក្រុមហ៊ុនដែលអ្នកកាន់កាប់ ឬបានកាន់កាប់ក្នុងការទទួលខុសត្រូវក្នុងតំណែងក្រុមហ៊ុនមួយ ឬជាភាគទុនិកសំខាន់មួយដែលមានទំនាក់ទំនងជាមួយអ្នកដាក់ពាក្យសុំ ។

State, to the best of your knowledge, which of the companies in which you have held or hold a position of responsibility, or in which you have been or are a significant shareholder, has or might soon have significant business relations with the applicant.

12- តើខ្លួនលោក-លោកស្រីផ្ទាល់ ឬអង្គភាពណាមួយដែលលោក-លោកស្រីរួមអាស្រ័យក្នុងឋានៈជានាយក, ជាភាគទុនិក ឬជាអ្នកចាត់ការ ធ្លាប់ទទួល ឬធ្លាប់ស្នើសុំអាជ្ញាប័ណ្ណ ឬធ្លាប់ចាត់ចែងសកម្មភាពជំនួញ នៅក្នុងប្រទេសណាមួយដែរឬទេ ? បើមាន សូមបញ្ជាក់នូវចំណុចពិសេសៗ ប្រសិនបើការស្នើនោះត្រូវបានបដិសេធ ឬត្រូវដកវិញបន្ទាប់ពីបានធ្វើហើយ ឬបានដកហូតការអនុញ្ញាត ក៏ត្រូវបញ្ជាក់ចំណុចពិសេសៗដែរ ។

Have you or any entity with which you are associated as a director, shareholder or manager, ever held or applied for a license or to carry o any business activity in any country ? If so, give particulars, if any such application was refused or withdrawn after it was made or any authorization revoked , give particulars.

13- តើខ្លួនលោក-លោកស្រីផ្ទាល់ ឬអង្គភាពណាមួយដែលលោក-លោកស្រីបានពាក់ព័ន្ធជាមួយក្នុងការអនុវត្តន៍កិច្ចការរបស់ខ្លួន ធ្លាប់ត្រូវបានអាជ្ញាធរអោយព្រមាន ឬអង្គភាពវិជ្ជាជីវៈណាមួយព្រមានជាសាធារណៈ ឬជាកម្មវត្ថុដែលត្រូវគេធ្វើការស៊ើបអង្កេតដែរឬទេ ? បើមានសូមបញ្ជាក់ ។

Have you or any entity with which you have been involved in the conduct or its affairs, been disciplined, warned as to future conduct, publicly criticized, or the subject of an

investigation by any regulatory authority or any professional body ? If so, give particulars.

---

---

---

---

14- តើលោក-លោកស្រី ធ្លាប់បានបញ្ឈប់ពីការងារ ឬ ត្រូវបណ្តេញចេញពីការងារ ដោយនិយោជក ឬ ត្រូវគេហាមមិនអោយចូលប្រកបវិជ្ជាជីវៈជំនាញឬមុខរបរការងារណាមួយដែរឬទេ? បើមានសូមបញ្ជាក់ ។

Have you, in any country, been dismissed from any office or employment by your employer or barred from entry to any professional or occupation ? If so, give particulars.

---

---

---

---

15- តើធ្លាប់ មានបញ្ហាដែលពាក់ព័ន្ធនឹងការកាត់ក្តីរបស់តុលាការពីការជំពាក់បំណុល និងប្រាក់ដែលត្រូវតែសងគេដែរឬទេ ? តើធ្លាប់មានប្រកាសស្តីពីការក្ស័យធនតាមលក្ខណៈគតិយុត្តដែររឺទេ ? នៅប្រទេស ណា ? តើធ្លាប់ទទួលរងការប្តឹងលើក្ស័យធនដែរឬទេ ? បើមានសូមបញ្ជាក់ក្នុងករណីនីមួយៗអោយបានច្បាស់លាស់ ។

Have you, failed to satisfy any debt adjudged due and payable by you under an order of a court, or have you been declared bankrupt by a court in any country or has a bankruptcy petition ever been served on you ? If so, give particulars.

---

---

---

---

---

---

16- តើធ្លាប់មានពាក់ព័ន្ធនឹងការគ្រប់គ្រងអង្គភាពណាខ្លះ ដែលត្រូវតុលាការកាត់សេចក្តីពីបទល្មើស, នៅប្រទេសណា ? តើធ្លាប់បានទទួលខុសលើកំហុសណាខ្លះ ឬ ការប្រព្រឹត្តិខ្ទាំខ្ទង់ផ្សេងៗ ដែលមាន

ចំពោះអង្គភាពណាមួយឬចំពោះសមាជិកណាម្នាក់ដែរឬទេ ? បើសិនជាមាន សូមបញ្ជាក់ករណីនីមួយៗ អោយបានច្បាស់លាស់ ។

Have you, in connection with the management of any entity been adjudged by a court, in any country, legally liable for any fraud, or other misconduct by you towards such an entity or towards any of its members ? If so, give particulars.

17- បច្ចុប្បន្ននេះ ក្រៅពីសមត្ថភាពវិជ្ជាជីវៈ តើលោក-លោកស្រីមានការពាក់ព័ន្ធនឹងការប្តឹងផ្តល់នៅប្រទេសណាមួយទេ ? បើមានសូមបញ្ជាក់អោយច្បាស់លាស់ ។

Are you presently, or do you, other than in a professional capacity, expect to be , engaged in any litigation in any country ? If so, give particulars.

18- សូមផ្តល់នូវរបាយការណ៍ត្រួតពិនិត្យ ស្តីពីមូលនិធិផ្ទាល់សុទ្ធរបស់ខ្លួន ដោយផ្តល់នូវតារាងលំអិតស្តីពីទ្រព្យសកម្ម និងទ្រព្យអកម្ម ។

Please supply an **audited statement** of personal net worth providing a breakdown of your assets and liabilities.

19- សូមបង្ហាញឈ្មោះ អាសយដ្ឋាន លេខទូរស័ព្ទ និង តួនាទីឬកិត្តិនាម របស់អ្នកគួរឱ្យជឿ ដែលត្រូវមាន លក្ខណៈសម្បត្តិល្អ ដើម្បីបញ្ជាក់ពីលក្ខណៈបុគ្គល និងវិជ្ជាជីវៈរបស់លោកអ្នក (លោកអ្នកត្រូវស្គាល់បុគ្គល ដែលមិនមែនជាសាច់ញាតិ ហើយធ្លាប់បានស្គាល់លោក-លោកស្រីយ៉ាងតិច៥ឆ្នាំ) ។

Indicate the names, addresses, telephone numbers and positions of three individuals of good standing who would be able to provide a reference on your personal and professional integrity. **The referees must not be related to you, and should have known you for at least five years.**

20- បើសិនជាមានព័ត៌មានបន្ថែមទៀតដែលគេត្រូវយកមកពិចារណា-តួនាទីផ្ទាល់ខ្លួនដូចមានបញ្ជាក់ក្នុងសំណួរ ៤-១ ? សាមីជនគួរតែបញ្ជាក់បន្ថែមអោយបានច្បាស់លាស់ ដើម្បីជាគុណប្រយោជន៍សំរាប់ការពិនិត្យ ពិចារណាអោយត្រឹមត្រូវតាមទំរង់គតិយុត្ត ។ ករណីលាក់បាំងនូវរាល់ព្រឹត្តិការណ៍រឿងរ៉ាវផ្សេងៗដែលពាក់ព័ន្ធ ដោយបង្វែរព័ត៌មានពិត ឬផ្តល់អោយនូវព័ត៌មានខុសពីការពិត នឹងត្រូវទទួលខុសត្រូវចំពោះច្បាប់ជាធរមាន (សូមអានសេចក្តីប្រកាសដូចខាងក្រោម) :

ចូរកត់សំគាល់អោយបានច្បាស់ថា : រាល់ព័ត៌មានដែលបានផ្តល់អោយ ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន ហើយរាល់ព័ត៌មានទាំងនេះ ត្រូវបានរក្សាទុកសំងាត់ដោយអាជ្ញាធរត្រួតត្រា (ធនាគារជាតិនៃកម្ពុជា) លើកលែងតែករណីដែលផ្តល់អោយស្របតាមទំរង់គតិយុត្ត ។

**Is there any additional information which you consider is relevant for the consideration of your suitability for the position(s) listed in question 4.1 ? The omission of material facts may represent the provision of misleading information (see declaration below).**

**N.B. (note well) the information given in response to this questionnaire shall be kept fully confidential by the supervisory authority. The National Bank of Cambodia. Except in cases provided for by law.**

## សេចក្តីប្រកាស ឬ កិច្ចសន្យាផ្ទាល់ខ្លួន

ខ្ញុំបាទសូមសន្យាថា នឹងទទួលខុសត្រូវនៅចំពោះមុខច្បាប់ ប្រសិនជាព័ត៌មានណាមួយដែលបានផ្តល់ជូននេះក្លែងក្លាយឬខុសពីការពិត ដែលពាក់ព័ន្ធនឹងការដាក់ពាក្យសុំអាជ្ញាប័ណ្ណ ឬបន្តអាជ្ញាប័ណ្ណប្រកបអាជីវកម្មគ្រឹះស្ថាន ។

ខ្ញុំបាទសូមបញ្ជាក់ជូនជាឧឡារិកថា ព័ត៌មានដែលបានអោយចម្លើយចំពោះសំណួរខាងលើ គឺពិតជាត្រឹមត្រូវ និងបានបំពេញបរិបូរណ៍ដោយចំណេះដឹងផ្ទាល់ខ្លួនរបស់ខ្ញុំបាទឬនាងខ្ញុំ ហើយពិតជាមិនមាន

ហេតុការណ៍ផ្សេង ឬផ្ទុយពីសេចក្តីរាយការណ៍ ដូចដែលបានបញ្ជាក់ជូនអាជ្ញាធរដែលគ្រប់គ្រង (តាមតួកិច្ច) ដើម្បីជ្រាបនោះឡើយ ។

ខ្ញុំបាទសូមសន្យាថា នឹងផ្តល់ព័ត៌មានជូនអាជ្ញាធរដែលគ្រប់គ្រងដើម្បីជ្រាបអំពី រឿងរ៉ាវ ឬហេតុការណ៍ ដែលត្រូវផ្លាស់ប្តូរលក្ខខណ្ឌដែលកើតមាន នៅពេលដែលអាជ្ញាធរគ្រប់គ្រងកំពុងពិនិត្យពិចារ-ណាលើពាក្យស្នើសុំរបស់យើងខ្ញុំ ជ្រាបជាព័ត៌មាន ។

**DECLARATION**

I am aware that it is an offense knowing or recklessly to provide any information which is false or misleading in connection with an application for a banking license or a renewal of bank license.

I certify that the information given in answer to the questions above is complete and accurate to the best of my knowledge, and that there are no other facts relevant to this application of which the supervisory authority should be aware.

I undertake to inform the supervisory authority of any changes material to the application which arise while the supervisory authority is considering the application.

ឈ្មោះ :

Name :

------------------------------------------------------------

មុខងារ និង ភារៈដែលទទួលបន្ទុក

Position held :

------------------------------------------------------------

ហត្ថលេខា : ថ្ងៃ ខែ ឆ្នាំ :

Signed : Date : ......../......./.........

★★★

## ២-នីតិការរដ្ឋមន្ត្រី ក្រសួងព័ត៌មាន

### ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០០០

### ប្រកាសលេខ ០២០/០០ ពម.ប្រក
### ស្តីពីការតែងតាំងមន្ត្រីរាជការ

***

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព័ត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ លេខ ន.ស.រ.ក.ត. ១១៩៨. ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០៦ ន.ស ៩៤ ចុះថ្ងៃទី ២៦ ខែតុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ ន.ស ៩៤. ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម ន.ស.រ.ក.ម ០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពត៌មាន
- បានឃើញអនុក្រឹត្យលេខ ៧០. អ.ន.ក្រ..ប.ក ចុះថ្ងៃទី ៥ ខែ សីហា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តិក្រសួងពត៌មាន
- ពិនិត្យលើលក្ខណៈសម្បត្តិនិងសមត្ថភាពមន្ត្រីរាជការ

**សំរេច**

**ប្រការ ១ :** តែងតាំងមន្ត្រីរាជការជាប្រធានការិយាល័យ និងអនុប្រធានការិយាល័យនៃអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជាដូចមានខាងក្រោម :

១- លោកស្រី **សុខ សុវណ្ណារី** ជាប្រធានការិយាល័យ ផលិតកម្មវិធី ចំណេះដឹងទូទៅ

២- លោកស្រី **សុខ ឆាវី** ជាអនុប្រធានការិយាល័យផ្សាយពាណិជ្ជកម្ម

**ប្រការ ២ :** ឯកឧត្តមអគ្គនាយករដ្ឋបាលសេវាគទស្សន៍ លោកនាយកខុទ្ទកាល័យ ឯកឧត្តមអគ្គនាយកទូរទស្សន៍ជាតិកម្ពុជា លោកប្រធាននាយកដ្ឋានបុគ្គលិក លោកប្រធាននាយកដ្ឋានផែនការគណនេយ្យ ហិរញ្ញវត្ថុ និងសាមីខ្លួនក្នុងប្រការ ១ ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី
ហត្ថលេខា និង ត្រា
**លី ឡាយស្រេង**

★★★

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០០

## ប្រកាសលេខ ០២១/០០ ពម.ប្រក
## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨-៧២ ចុះថ្ងៃទី ៣០-១១-៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់សហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិល ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រម លេខ ០៦ ន.ស ៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស.រកម ០១៩៦-១៤ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ៥ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងព័ត៌មាន
- យោងលិខិតលេខ ២៧១ លសរកឆ ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៩ របស់ ឯកឧត្តម អភិបាលខេត្តកំពង់ឆ្នាំង ស្តីពីសំណើសុំតែងតាំងប្រធានមន្ទីរព័ត៌មានខេត្ត
- យោងលិខិតលេខ ០២ អសរ.គត ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០០០ របស់ ឯកឧត្តម រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ ស្តីពីការឯកភាព ក្នុងការតែងតាំង ប្រធានមន្ទីរព័ត៌មាន ខេត្ត
- យោងតាមតម្រូវការចាំបាច់

សំរេច

ប្រការ ១ : តែងតាំង លោក **ម៉ម ម៉ាលី** ជាប្រធានមន្ទីរព័ត៌មានខេត្តកំពង់ឆ្នាំង នៃក្រសួងព័ត៌មាន

ប្រការ ២ : ឯកឧត្តមអគ្គនាយក គ្រប់អគ្គនាយកដ្ឋានចំណុះ លោកនាយកខុទ្ទកាល័យ លោកស្រីប្រធាននាយកដ្ឋានបុគ្គលិក លោកស្រីប្រធាននាយកដ្ឋានផែនការ គណនេយ្យ ហិរញ្ញកិច្ច លោកប្រធានមន្ទីរព័ត៌មាន គ្រប់ខេត្ត-ក្រុង និងសាមីខ្លួន ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**លី ធុាយស្រេង**

★★★

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០០០

## ប្រកាសលេខ ០២៨/០០ ពម.ប្រក
## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព័ត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យលេខ ន.ស.រ.ក.ត ១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ន.ស.រ.ក.ត ០១៩៦-១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ-បក ចុះថ្ងៃទី ៥ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការ រៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងព័ត៌មាន
- តាមការចាំបាច់របស់ក្រសួងព័ត៌មាន
- ពិនិត្យលើលក្ខណៈសម្បត្តិ និងសមត្ថភាពមន្ត្រីរាជការ

**សំរេច**

**ប្រការ ១ :** តែងតាំង លោក **ប៉ាល់ ឆាន** ជាអនុប្រធាននាយកដ្ឋានសោតទស្សន៍ នៃ អគ្គនាយកដ្ឋានរដ្ឋបាល-សោតទស្សន៍ ក្រសួងព័ត៌មាន ។

**ប្រការ ២ :** ឯកឧត្តមអគ្គនាយករដ្ឋបាល សោតទស្សន៍ ឯកឧត្តមអគ្គនាយកគ្រប់អគ្គនាយកដ្ឋាន លោកនាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានសោតទស្សន៍ ប្រធាននាយកដ្ឋានផែនការគណនេយ្យ - ហិរញ្ញកិច្ច គ្រប់ប្រធានមន្ទីរព័ត៌មានខេត្ត-ក្រុង និងសាមីខ្លួន ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី
ហត្ថលេខា និង ត្រា
**លឺ ឡាយស្រេង**

★★★

## ៣-ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា

## ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០០

### ប្រកាសលេខ ០៨ អយក.ប្រក

### ស្តីពីការផ្លាស់សាលាឧបសម្ព័ន្ធ "ទីតាងើយ" មកជាសាលាបឋមសិក្សា ពេញលក្ខណៈ

***

### ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត-១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការ រៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានពិនិត្យលិខិតស្នើសុំរបស់ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តព្រៃវែង លេខ ១៦៦ .អករក.អអ.៣វ ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៩៩
- តាមសេចក្តីសំណូមពររបស់នាយកដ្ឋានបឋម និង អគ្គនាយកសិក្សា

### សំរេច

**ប្រការ ១ :** ផ្លាស់សាលាឧបសម្ព័ន្ធ ទីតាងើយ ពីសាលាបឋមសិក្សា ពងពស់ ដែលមានទីតាំងស្ថិតនៅឃុំ រោងដំរី ស្រុក ពាមរ៍ ខេត្ត ព្រៃវែង មកជា សាលាបឋមសិក្សាពេញលក្ខណៈ វិញ ចាប់ពីឆ្នាំសិក្សា ១៩៩៩-២០០០ នេះតទៅ ។

**ប្រការ ២ :** សាលាបឋមសិក្សាទីតាងើយត្រូវដឹកនាំដោយនាយកមួយរូប និង នាយករង តាមការចាំបាច់ ព្រមទាំងបុគ្គិកផ្សេងៗស្របតាមបទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌ សំរាប់សាលាបឋមសិក្សា ។

**ប្រការ ៣ :** នាយក នាយករង មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ច តាមគោលការណ៍កំណត់របស់រដ្ឋ ។

ប្រការ ៤ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៥ : នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានបុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានបឋម និងមត្តេយ្យសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡា ខេត្តព្រៃវែង ការិយាល័យអប់រំ យុវជន និងកីឡាស្រុកបាភ្នំ នាយកសាលាបឋមសិក្សា "ទីតាឈើ" មានភារកិច្ចអនុវត្ត ប្រកាសនេះ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

**អ៊ឹម សិទ្ធី**

★★★

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០០

**ប្រកាសលេខ ០៩ អយក.ប្រក**

**ស្តីពីការផ្ទាច់សាលាឧបសម្ព័ន្ធ "ព្រៃប្រង់"**

**មកជាសាលាបឋមសិក្សា ពេញលក្ខណៈ**

***

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត-១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការ រៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានពិនិត្យលិខិតស្នើសុំរបស់ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តព្រៃវែង លេខ ១៦៦ .អយក.មម.៣វ ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៩៩

- តាមសំណើរបស់ឯកឧត្តមនាយកនាយកដ្ឋានបឋម និង មត្តេយ្យសិក្សា

**សំរេច**

**ប្រការ ១ :** ផ្លាស់សាលាឧបសម្ព័ន្ធ ព្រៃប្រង់ ពីសាលាបឋមសិក្សា តានីរ៉ា ដែលមានទីតាំងស្ថិតនៅ ឃុំ ស្តី ខ ស្រុក បាភ្នំ ខេត្ត ព្រៃវែង មកជា សាលាបឋមសិក្សាពេញលក្ខណៈ វិញ ចាប់ពីឆ្នាំ សិក្សា ១៩៩៩-២០០០ នេះតទៅ ។

**ប្រការ ២ :** សាលាបឋមសិក្សា ព្រៃប្រង់ ត្រូវដឹកនាំដោយនាយកមួយរូប និង នាយករង តាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗគ្រប់តាមបទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌ សំរាប់សាលាបឋមសិក្សា ។

**ប្រការ ៣ :** នាយក នាយករង មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ច តាមគោលការណ៍កំណត់របស់រដ្ឋ ។

**ប្រការ ៤ :** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥ :** នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានបុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡា ខេត្តព្រៃវែង ការិយាល័យអប់រំ យុវជន និងកីឡាស្រុកបាភ្នំ នាយកសាលាបឋមសិក្សា "ព្រៃប្រង់" មានភារកិច្ចអនុវត្ត ប្រកាសនេះ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

**អ៊ឹម សិទ្ធី**

★★★

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០០

## ប្រកាសលេខ ១០ អយក.ប្រក

## ស្តីពីការផ្លាស់សាលាឧបសម្ព័ន្ធ "សាមគ្គីតេជមុនី" មកជាសាលាបឋមសិក្សា ពេញលក្ខណៈ

***

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត-១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការ រៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើត ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានពិនិត្យលិខិតស្នើសុំពលកម្មការទ្រទ្រង់សាលាឧបសម្ព័ន្ធ គាមគ្គីរតនមុនី ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៩៩ ដែលមានចំណោរឯកភាពរបស់ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ស្វាយរៀង លេខ ចប.អយក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៩
- តាមសេចក្តីឯកភាពរបស់នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា

**សំរេច**

**ប្រការ ១ :** ផ្លាស់សាលាឧបសម្ព័ន្ធ គាមគ្គីរតនមុនី ពីសាលាបឋមសិក្សា ស្វាយតាយាន ដែលមានទីតាំងស្ថិតនៅ វត្ត ស្វាយតាយាន ស្រុក កំពង់រោទិ៍ ខេត្ត ស្វាយរៀង មកជា សាលាបឋមសិក្សា ពេញលក្ខណៈ វិញ ចាប់ពីឆ្នាំ សិក្សា ១៩៩៩-២០០០ នេះតទៅ ។

**ប្រការ ២ :** សាលាបឋមសិក្សា គាមគ្គីរតនៈមុនី ត្រូវដឹកនាំដោយនាយកមួយរូប និង នាយករង តាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗស្របតាមបទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌ សំរាប់សាលាបឋមសិក្សា ។

**ប្រការ ៣ :** នាយក នាយករង មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ច តាមគោលការណ៍សាមញ្ញរបស់រដ្ឋ ។

**ប្រការ ៤ :** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥ :** នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានបុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡា ខេត្តស្វាយរៀង ការិយាល័យអប់រំ យុវជន និងកីឡាស្រុកកំពង់រោទិ៍ នាយកសាលាបឋមសិក្សា "គាមគ្គីរតនមុនី" មានភារកិច្ច អនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

បត្តលេខា និង ត្រា

**អ៊ឹម សិទ្ធី**

★★★

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០០

**ប្រកាសលេខ ១១ អយក.ប្រក**

**ស្តីពីការផ្តាច់សាលាឧបសម្ព័ន្ធ "ត្រពាំងត្រាវ"**

**មកជាសាលាបឋមសិក្សា ពេញលក្ខណៈ**

***

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត-១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានពិនិត្យលើលិខិតស្នើសុំគណៈកម្មការទ្រទ្រង់សាលាឧបសម្ព័ន្ធ ត្រពាំងត្រាវ ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៩៩ ដែលមានចំណារឯកភាពរបស់ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ស្វាយរៀង លេខ ៧៣ ចប .អយក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៩
- តាមសេចក្តីឯកភាពរបស់នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា

**សំរេច**

ប្រការ ១ : ផ្តាច់សាលាឧបសម្ព័ន្ធ ត្រពាំងត្រាវ ពីសាលាបឋមសិក្សា ហ៊ុនសែន-កំពង់រោទ៍ ដែលមានទីតាំងស្ថិតនៅ ឃុំ ញរ ស្រុក កំពង់រោទ៍ ខេត្ត ស្វាយរៀង មកជា សាលាបឋមសិក្សាពេញលក្ខណៈ វិញ ចាប់ពីឆ្នាំ សិក្សា ១៩៩៩-២០០០ នេះតទៅ ។

ប្រការ ២ : សាលាបឋមសិក្សា ត្រពាំងត្រាវ ត្រូវដឹកនាំដោយនាយកមួយរូប និង នាយករង តាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗស្របតាមបទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌ សំរាប់សាលាបឋមសិក្សា ។

ប្រការ ៣ : នាយក នាយករង មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ច តាមគោលការណ៍កំណត់របស់រដ្ឋ ។

ប្រការ ៤ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៥ : នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានបុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា ខេត្តស្វាយរៀង ការិយាល័យអប់រំ យុវជន និងកីឡាស្រុកកំពង់រោទ៍ នាយកសាលាបឋមសិក្សា "ត្រពាំងត្រាវ" មានភារកិច្ច អនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

អ៊ឹម សិទ្ធី

***

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០០

## ប្រកាសលេខ ១២ អយក.ប្រក
## ស្តីពីការផ្តាច់សាលាឧបសម្ព័ន្ធ "ក្តីកណ្តាល" មកជាសាលាបឋមសិក្សា ពេញលក្ខណៈ

***

### ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត-១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានពិនិត្យលិខិតស្នើសុំគណៈកម្មការទ្រទ្រង់សាលាឧបសម្ព័ន្ធ ក្តីកណ្តាល ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ១៩៩៩ ដែលមានចំណារឯកភាពរបស់ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ស្វាយរៀង លេខ ៧២ ចប .អយក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៩
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា

### សំរេច

ប្រការ ១ : ផ្តាច់សាលាឧបសម្ព័ន្ធ ក្តីកណ្តាល ពីសាលាបឋមសិក្សា ត្រពាំងកំពិស ដែលមានទីតាំងស្ថិតនៅ ឃុំ ខ្សែត្រ ស្រុក កំពង់រោទ៍ ខេត្ត ស្វាយរៀង មកជា សាលាបឋមសិក្សាពេញលក្ខណៈ វិញ ចាប់ពីឆ្នាំសិក្សា ១៩៩៩-២០០០ នេះតទៅ ។

**ប្រការ ២ :** គណៈគ្រប់គ្រងសាលាបឋមសិក្សា ក្តីកណ្តាល ត្រូវដឹកនាំដោយនាយកម្នាក់ និង នាយករង តាមការកំណត់ ព្រមទាំងបុគ្គលិកផ្សេងៗទៀតតាមបទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌ សំរាប់គណៈសាលាបឋមសិក្សា ។

**ប្រការ ៣ :** នាយក នាយករង មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ច តាមគោលនយោបាយរបស់រដ្ឋ ។

**ប្រការ ៤ :** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥ :** នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានបុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានបឋម និង អគ្គនាយកសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡា ខេត្តស្វាយរៀង ការិយាល័យអប់រំ យុវជន និងកីឡាស្រុកកំពង់រោទិ៍ នាយកសាលាបឋមសិក្សា "ក្តីកណ្តាល" មានភារកិច្ច អនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

**អ៊ឹម សិទ្ធី**

***

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០០

## ប្រកាសលេខ ១៣ អយក.ប្រក
## ស្តីពីការផ្លាស់សាលាឧបសម្ព័ន្ធ "បាទីគកណ្តាល"
## មកជាសាលាបឋមសិក្សា ពេញលក្ខណៈ

***

### ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត-១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានពិនិត្យលិខិតស្នើសុំរបស់ ប្រធានមន្ទីរអប់រំ យុវជន និង កីឡាខេត្តស្វាយរៀង លេខ ៣៩៩ អយក.ឃស.បម ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ១៩៩៩

- តាមសេចក្តីស្នើសុំរបស់នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា

**សំរេច**

**ប្រការ ១ :** ផ្លាស់សាលាឧបសម្ព័ន្ធ បារិតកណ្តាល ពីសាលាបឋមសិក្សា បារិត ដែលមានទីតាំងស្ថិតនៅឃុំ បារិត ស្រុក ចន្ទ្រា ខេត្ត ស្វាយរៀង មកជា សាលាបឋមសិក្សាពេញលក្ខណៈ វិញ ចាប់ពីឆ្នាំសិក្សា ១៩៩៩-២០០០ នេះតទៅ ។

**ប្រការ ២ :** សាលាបឋមសិក្សា បារិតកណ្តាល ត្រូវដឹកនាំដោយនាយកម្នាក់ និង នាយករង តាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗគ្រប់តាមបទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌ សំរាប់សាលាបឋមសិក្សា ។

**ប្រការ ៣ :** នាយក នាយករង មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ច តាមគោលការណ៍ធំណាច់របស់រដ្ឋ ។

**ប្រការ ៤ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥ :** នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានបុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា ខេត្តស្វាយរៀង ការិយាល័យអប់រំ យុវជន និងកីឡាស្រុកចន្ទ្រា នាយកសាលាបឋមសិក្សា "បារិតកណ្តាល" មានភារកិច្ច អនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

**អ៊ឹម សិទ្ធី**

***

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០០

## ប្រកាសលេខ ១៤ អយក.ប្រក

## ស្តីពីការផ្លាស់សាលាឧបសម្ព័ន្ធ "ឧត្តមមានជ័យ" មកជាសាលាបឋមសិក្សា ពេញលក្ខណៈ

***

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត-១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រមលេខ នស/រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានពិនិត្យលើលិខិតស្នើសុំរបស់ប្រធានមន្ទីរអប់រំ យុវជន និង កីឡាខេត្តព្រៃវែង លេខ ១៦៦. អយក.អម.ពវ ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៩៩
- តាមសេចក្តីស្នើសុំរបស់នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា

**សំរេច**

ប្រការ ១ : ផ្តាច់សាលាឧបសម្ព័ន្ធ ឧត្តមមានជ័យ ពីសាលាបឋមសិក្សា តាកោ ដែលមានទីតាំងស្ថិតនៅភូមិ តាកោ ស្រុក កំពង់លាវ ខេត្ត ព្រៃវែង មកជា សាលាបឋមសិក្សាពេញលក្ខណៈ វិញ ចាប់ពីឆ្នាំសិក្សា ១៩៩៩-២០០០ នេះតទៅ ។

ប្រការ ២ : សាលាបឋមសិក្សា ឧត្តមមានជ័យ ត្រូវដឹកនាំដោយនាយកមួយរូប និង នាយករង តាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗស្របតាមបទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌ សំរាប់សាលាបឋមសិក្សា ។

ប្រការ ៣ : នាយក នាយករង មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ច តាមគោលការណ៍កំណត់របស់រដ្ឋ ។

ប្រការ ៤ : រាល់បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៥ : នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានបុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡា ខេត្តព្រៃវែង ការិយាល័យអប់រំ យុវជន និងកីឡាស្រុកកំពង់លាវ នាយកសាលាបឋមសិក្សា "ឧត្តមមានជ័យ" មានភារកិច្ច អនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ពេជ្ញលេខា និង ត្រា

**អ៊ឹម សិទ្ធី**

★★★

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០០

## ប្រកាសលេខ ១៥ អយក.ប្រក
## ស្តីពីការផ្លាស់សាលាឧបសម្ព័ន្ធ "វាលព្រៅ"
## មកជាសាលាបឋមសិក្សា ពេញលក្ខណៈ

***

### ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត-១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានពិនិត្យលិខិតស្នើសុំរបស់ ប្រធានមន្ទីរអប់រំ យុវជន និង កីឡាខេត្តព្រៃវែង លេខ ១៦៦ . អយក.មម.៣វ ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៩៩
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា

**សំរេច**

**ប្រការ ១ :** ផ្លាស់សាលាឧបសម្ព័ន្ធ វាលព្រៅ ពីសាលាបឋមសិក្សា ពោធិ៍រៀង ដែលមានទីតាំងស្ថិតនៅឃុំ ពោធិ៍រៀង ស្រុក កំពង់លាវ ខេត្ត ព្រៃវែង មកជា សាលាបឋមសិក្សាពេញលក្ខណៈ វិញ ចាប់ពីឆ្នាំសិក្សា ១៩៩៩-២០០០ នេះតទៅ ។

**ប្រការ ២ :** សាលាបឋមសិក្សា វាលព្រៅ ត្រូវដឹកនាំដោយនាយកមួយរូប និង នាយករង តាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗស្របតាមបទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌ សំរាប់គណៈគ្រប់គ្រងសិក្សា ។

**ប្រការ ៣ :** នាយក នាយករង មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ច តាមគោលការណ៍កំណត់របស់រដ្ឋ ។

**ប្រការ ៤ :** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥ :** នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានបុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្តព្រៃវែង

ការិយាល័យអប់រំ យុវជន និងកីឡាស្រុកកំពង់លាវ នាយកសាលាបឋមសិក្សា "ភាលេព្រៅ" មានភារកិច្ច អនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

អ៊ឹម សិទ្ធី

***

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០០

## ប្រកាសលេខ ១៦ អយក.ប្រក

## ស្តីពីការផ្ទាច់សាលាឧបសម្ព័ន្ធ "ទ័ពស្តេច" មកជាសាលាបឋមសិក្សា ពេញលក្ខណៈ

***

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត-១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានពិនិត្យលិខិតស្នើសុំរបស់ ប្រធានមន្ទីរអប់រំ យុវជន និង កីឡាខេត្តព្រៃវែង លេខ ១១៦ . អយក.មម.៣វ ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៩៩
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា

## សំរេច

ប្រការ ១ : ផ្តាច់សាលាឧបសម្ព័ន្ធ ទ័ពស្តេច ពីសាលាបឋមសិក្សា កើនសែន-សិរីសន្ទាយ ដែលមានទីតាំងស្ថិតនៅឃុំ តាយ៉ូ ស្រុក បាភ្នំ ខេត្ត ព្រៃវែង មកជាសាលាបឋមសិក្សា ពេញលក្ខណៈ វិញ ចាប់ពីឆ្នាំសិក្សា ១៩៩៩-២០០០ នេះតទៅ ។

**ប្រការ ២ :** សាលាបឋមសិក្សា ទ័ពស្ដេច ត្រូវដឹកនាំដោយនាយកមួយរូប និង នាយករង តាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗស្របតាមបទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌ សំរាប់សាលាបឋមសិក្សា ។

**ប្រការ ៣ :** នាយក នាយករង មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ច តាមគោលការណ៍កំណត់របស់រដ្ឋ ។

**ប្រការ ៤ :** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥ :** នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានបុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានបឋម និងអគ្គាធិការដ្ឋានសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្តព្រៃវែង ការិយាល័យអប់រំ យុវជន និងកីឡាស្រុកបាភ្នំ នាយកសាលាបឋមសិក្សា "ទ័ពស្ដេច" មានភារកិច្ច អនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

អ៊ឹម សិទ្ធី

***

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០០

## ប្រកាសលេខ ៣៧ អយក.ប្រក

## ស្ដីពីការប្ដូរឈ្មោះសាលាបឋមសិក្សា "បែកចាន"

## មកជាសាលាបឋមសិក្សា "កែវមុំនួនមុត បែកចាន"

***

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត-១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្ដីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា

- បានពិនិត្យលិខិតស្នើសុំរបស់ការិយាល័យអប់រំ យុវជន និង កីឡាស្រុកស្វាយទាបលេខ ១១៦ អយក.ស្វទ ចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ១៩៩៩

- តាមសេចក្តីឯកភាពរបស់នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា

សំរេច

ប្រការ ១ : ប្តូរឈ្មោះសាលាបឋមសិក្សា បែកចាន ដែលមានទីតាំងស្ថិតនៅឃុំ រមាំងថ្កោល ស្រុក ស្វាយទាប ខេត្ត ស្វាយរៀង មកជាសាលាបឋមសិក្សា "កែវមុំងួនមុត បែកចាន" វិញ ចាប់ពីឆ្នាំសិក្សា ១៩៩៩-២០០០ នេះតទៅ ។

ប្រការ ២ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៣ : នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានបុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និង កីឡាខេត្ត ស្វាយរៀង ការិយាល័យអប់រំ យុវជន និងកីឡា ស្រុក ស្វាយទាប នាយកសាលាបឋមសិក្សា "កែវមុំងួនមុត បែកចាន" មានភារកិច្ច អនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

អ៊ឹម សិទ្ធី

***

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០០

## ប្រកាសលេខ ៣៨ អយក.ប្រក

## ស្តីពីការប្តូរឈ្មោះសាលាបឋមសិក្សា "ស្រះចក" មកជាសាលាបឋមសិក្សា " ហាំង ឌៅ ស្រះចក " វិញ

***

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត-១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានពិនិត្យលិខិតស្នើសុំរបស់ប្រធានមន្ទីរអប់រំ យុវជន និង កីឡារាជធានីភ្នំពេញលេខ ៤២២ អយក.ភ ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ១៩៩៩
- តាមសេចក្តីស្នើរបស់នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា

**សំរេច**

**ប្រការ ១ :** ប្តូរឈ្មោះសាលាបឋមសិក្សា ត្រះពក ដែលពីមុនមានទីតាំងស្ថិតនៅផ្លូវលេខ ៣៩ វិថីព្រះសុីសុវត្ថិ សង្កាត់ ត្រះពក ខ័ណ្ឌ ដូនពេញ រាជធានីភ្នំពេញ មកជាសាលាបឋមសិក្សា " ហាំង ង៉ោ ត្រះពក " ដែលមានទីតាំងស្ថិតនៅផ្លូវលេខ ០១ កែង ផ្លូវ ១០២ សង្កាត់ វត្តភ្នំ ខ័ណ្ឌ ដូនពេញ រាជធានីភ្នំពេញ ចាប់ពីឆ្នាំសិក្សា ១៩៩៩-២០០០ នេះតទៅ ។

**ប្រការ ២ :** សាលាបឋមសិក្សា " ហាំង ង៉ោ ត្រះពក" ត្រូវរក្សារចនាសម្ព័ន្ធគ្រប់គ្រងឲ្យនៅដដែល ។

**ប្រការ ៣ :** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៤ :** នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានបុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានបឋម និងមត្តេយ្យសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និង កីឡារាជធានីភ្នំពេញ ការិយាល័យអប់រំ យុវជន និងកីឡាខ័ណ្ឌដូនពេញ នាយកសាលាបឋមសិក្សា " ហាំង ង៉ោ ត្រះពក " មានភារកិច្ច អនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ
ពេជ្ជលេខា និង ត្រា
អ៊ឹម សិទ្ធិ

***

## ៤- និស្ថិការរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា

### ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០០០

**ប្រកាសលេខ ០១៩ សកបយ.**

**ស្តីពីការអនុញ្ញាតឲ្យក្រុមហ៊ុនខេមបូឌាលេប៉រ ស៊ីបប្លាយ តឹធីវ៉ាយ អិលធីឌី ( Camodia Labour Supply Pty. Ltd. ) ធ្វើការរៀបចំបញ្ជូនពលករខ្មែរទៅធ្វើការនៅប្រទេសម៉ាឡេស៊ី សិង្ហបុរី និងប្រ៊ុយណេ**

***

**រដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ របស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសឲ្យប្រើដោយព្រះរាជក្រម ចុះ ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួង សង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នសរកម ០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៩
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ-បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៥ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស
- បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ-បក ចុះថ្ងៃទី ០៤ ខែតុលា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង សង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- បានឃើញសេចក្តីប្រកាស លេខ ៦៩៥ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៩៥ របស់ក្រសួងសង្គមកិច្ច ការងារ និងអតីត យុទ្ធជន ស្តីពីការអនុញ្ញាតឲ្យក្រុមហ៊ុនខេមបូឌាលេប័រ ស៊ីបប្លាយ ភីធី វ៉ាយ អិលធីឌី ( Cambodia Labour Supply Pty. Ltd. ) ធ្វើការរៀបចំនិងបញ្ជូនពលករខ្មែរ ទៅធ្វើការនៅប្រទេសម៉ាឡេស៊ី សិង្ហបុរី តៃវ៉ាន់ ប្រ៊ុយណេ និងកូរ៉េ
- តាមសំណើសុំការអនុញ្ញាតរបស់ក្រុមហ៊ុនខេមបូឌាលេប័រ ស៊ីបប្លាយ ភីធីវ៉ាយ អិលធីឌី ( Cambodia Labour Supply Pty. Ltd. ) ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការស្នើរៀបចំ និងបញ្ជូនពលករខ្មែរ ទៅធ្វើការនៅប្រទេសម៉ាឡេស៊ី សិង្ហបុរី តៃវ៉ាន់ ប្រ៊ុយណេ និងកូរ៉េ

## សំរេច

**ប្រការ ១ :** អនុញ្ញាតឲ្យក្រុមហ៊ុន ខេមបូឌាលេប័រ ស៊ីបប្លាយ ភីធី វ៉ាយ អិលធីឌី ( Cambodia Labour Supply Pty. Ltd. ) ធ្វើការបញ្ជូនពលករខ្មែរគ្រប់ប្រភេទទៅធ្វើការនៅប្រទេសសិង្ហបុរី និងប្រ៊ុយណេ ។ រីឯប្រទេសម៉ាឡេស៊ី អនុញ្ញាតឲ្យបន្តធ្វើការបញ្ជូនពលការិនីសំរាប់ការងារបំរើតាមផ្ទះប៉ុណ្ណោះ ពីព្រោះរាជរដ្ឋាភិបាលកម្ពុជាបានអនុញ្ញាតឲ្យក្រុមហ៊ុនយូមេនរីសសស៍ឌីវេឡុបមេន ខូ អេលធីឌី ( Human Resources Development Co., Ltd. ) ធ្វើការបញ្ជូនពលករគ្រប់ប្រភេទផ្តាច់មុខ ទៅធ្វើការនៅប្រទេសនេះរួចហើយ ។

ក្នុងករណីចាំបាច់ ក្រុមហ៊ុន ខេមបូឌាលេប័រ ស៊ីបប្លាយ ភីធីវ៉ាយ អិលធីឌី ( Cambodia Labour Supply Pty. Ltd. ) អាចចុះកិច្ចសន្យា ឬកិច្ចព្រមព្រៀងជាមួយ

ក្រុមហ៊ុនផ្សេងទៀតបានដោយមានការបញ្ជាក់យល់ព្រម ពីក្រសួង សង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ។

**ប្រការ ២ :** អ្នកស្រី មេឌីនណាត្យា ជាអ្នកតំណាងឲ្យក្រុមហ៊ុន ខេមបូឌាលេបើរ ស៊ីបប្លាយ ភីធីវ៉ាយ អិលធីឌី ( Cambodia Labour Supply Pty. Ltd. ) សញ្ជាតិខ្មែរ, កាន់អត្តសញ្ញាណប័ណ្ណលេខ ៤០៥៩៥៥ កណ ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ ១៩៩៥ ។

ក្រុមហ៊ុន ខេមបូឌាលេបើរ ស៊ីបប្លាយ ភីធីវ៉ាយ អិលធីឌី ( Cambodia Labour Supply Pty. Ltd. ) មានទីស្នាក់ការលេខ ១៦១ ផ្លូវព្រះនរោត្តម សង្កាត់ បឹងកេងកងទី ១ ខណ្ឌ ចំការមន រាជធានីភ្នំពេញ ។

**ប្រការ ៣ :** ក្រុមហ៊ុនខេមបូឌាលេបើរ ស៊ីបប្លាយ ភីធីវ៉ាយ អិលធីឌី ( Cambodia Labour Supply Pty. Ltd. ) ត្រូវដាក់ប្រាក់ធានា ចំនួន៥០.០០០ ដុល្លារអាមេរិក (ហាសិបពាន់ដុល្លារអាមេរិក) ទៅក្នុងគណនីរបស់ក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

**ប្រការ ៤ :** ការទទួលបានកូតា ស្ដីការបញ្ជូនពលករខ្មែរគ្រប់ប្រភេទ ទៅធ្វើការនៅប្រទេស សិង្ហបុរី និងប្រ៊ូណេ ត្រូវបានជូនដំណឹងដោយ ក្រសួងសង្គមកិច្ចការងារបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទាមក ក្រុមហ៊ុន ខេមបូឌាលេបើរ ស៊ីបប្លាយ ភីធីវ៉ាយ អិលធីឌី ( Cambodia Labour Supply Pty. Ltd. ) ។ ក្រុមហ៊ុនត្រូវដាក់ប្រាក់តំកល់ធានាបន្ថែម ចំនួន ៥០.០០០ ដុល្លារអាមេរិក (ហាសិបពាន់ដុល្លារអាមេរិក) ទៀតទៅក្នុងគណនីរបស់ ក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ដើម្បីគ្រប់ចំនួន ១០០.០០០ ដុល្លារអាមេរិក (មួយរយពាន់ដុល្លារអាមេរិក) មុនពេលបញ្ជូនពលករទៅធ្វើការនៅប្រទេសទាំងនោះ ។

**ប្រការ ៥ :** ប្រកាសនេះនឹងត្រូវបានចាត់ទុកជាមោឃៈដោយពេញច្បាប់ ក្នុងករណីដែលក្រុមហ៊ុន ខេមបូឌាលេបើរ ស៊ីបប្លាយ ភីធីវ៉ាយ អិលធីឌី ( Cambodia Labour Supply Pty. Ltd. ) មិនបានអនុវត្តតាមប្រការ៣ និងប្រការ៤ ដូចមានចែងខាងលើ ។

**ប្រការ ៦ :** ក្រុមហ៊ុន ខេមបូឌាលេបើរ ស៊ីបប្លាយ ភីធីវ៉ាយ អិលធីឌី ( Cambodia Labour Supply Pty. Ltd. ) ត្រូវចុះកិច្ចសន្យាជាមួយក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដើម្បីសហការក្នុងការគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅបរទេស ។

**ប្រការ ៧ :** ក្រុមហ៊ុន ខេមបូឌាលេបើរ ស៊ីបប្លាយ ភីធីវ៉ាយ អិលធីឌី ( Cambodia Labour Supply Pty. Ltd. ) ត្រូវសុំសេចក្ដីសម្រេចជាមុន ពីក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា នូវរាល់ការផ្សព្វផ្សាយជាសាធារណៈស្ដីពីការជ្រើសរើស ការបណ្ដុះបណ្ដាល ការបញ្ជូន ពលករខ្មែរទៅតាមប្រភេទ និងចំនួនពលករ ។ល។ ទៅធ្វើការ នៅបរទេស ។

រាល់ពលករទាំងអស់ដែលត្រូវបានជ្រើសរើសសំរាប់ទៅធ្វើការនៅឯបរទេស ត្រូវតែបានបណ្តុះបណ្តាលជាមុននូវវិជ្ជាជីវៈកំរិតបឋម ព្រមទាំងចំណេះដឹង ភាសា របៀបរបបរស់នៅ ប្រពៃណីរបស់គេ ។ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា នឹងធ្វើតេស្ត និងផ្តល់ប័ណ្ណបញ្ជាក់មុននឹងអនុញ្ញាត ឲ្យចេញទៅធ្វើការនៅ ឯបរទេស ។

ប្រការ ៨ : រាល់ការរៀបចំ ដែលជាប់ទាក់ទងទៅនឹងការជ្រើសរើស ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការបញ្ជូនពលករខ្មែរជាបន្ទុកចំណាយផ្ទាល់របស់ក្រុមហ៊ុនខេមបូឌាលេប័រ ស៊ីបប្លាយ ភីធីវ៉ាយ អិលធីឌី ( Cambodia Labour Supply Pty. Ltd. ) ។

ប្រការ ៩ : ក្រុមហ៊ុនខេមបូឌាលេប័រ ស៊ីបប្លាយ ភីធីវ៉ាយ អិលធីឌី ( Cambodia Labour Supply Pty. Ltd. ) ត្រូវធ្វើសំណើជាលាយលក្ខអក្សរ ដើម្បីពន្យារពេលប្រើប្រាស់ ឬរៀបចំប្រកាសអនុញ្ញាតថ្មី ក្នុងរយៈពេលពីរខែ មុនប្រកាសអនុញ្ញាតអស់សុពលភាព ។

ប្រការ ១០ : ក្នុងករណីដែលក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ពិនិត្យឃើញថាក្រុមហ៊ុនខេមបូឌាលេប័រ ស៊ីបប្លាយ ភីធីវ៉ាយ អិលធីឌី ( Cambodia Labour Supply Pty. Ltd. ) មិនបានអនុវត្តតាម ឬផ្ទុយនឹងច្បាប់អនុក្រឹត្យ និងវិធាននានា នាប្រកាសនេះនឹងត្រូវបដិសេធទាំងស្រុងដោយក្រសួង សង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា តាមករណីជាក់ស្តែង ។

ប្រការ ១១ : ប្រកាសនេះមានសុពលភាពចាប់ពីថ្ងៃចុះហត្ថលេខា រហូតដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០០៥ ។

រដ្ឋមន្ត្រី
ហត្ថលេខា និង ត្រា
**អ៊ីត សំហេង**

★★★